# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អង្គកាអយ្យការ

ស្រាវជ្រាវពីរថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

ឈ្មោះ **ក. វ៉ាន់ សូលីតា**

**ក. សុខ គីមហួរ**

សាស្ត្រាចារ្យណែនាំនិស្សិត

លោក **ហ៊ាង ឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំទាំងពីនាក់ឈ្មោះ **ទ៉ាន់ សូលីតា** នឹង **សុខ គីមឃួរ** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្ត ឆ្នាំទី៤ ជំនាន់ទី ២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨ -២០២២ ។

**យើងខ្ញុំសូមថ្លែងនូវកត្តញ្ញូតាធម៌ និងអំណរគុណដ៏ខ្ពង់ខ្ពស់បំផុត ជូនចំពោះ៖**

- លោកឪពុក **រស់ រីម** និង អ្នកម្តាយ **សខ គីមស្រៀន**
- លោកឪពុក **សុខ អឿន** និង អ្នកម្តាយ **លី ចេខ**

នាងខ្ញុំទាំងពីរនាក់សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ដល់ លោកទាំងពីរដែលបានផ្តល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សាកូនដោយក្តីមេត្តា ករុណា ចំពោះរូបកូនតាំងពីតូចរហូតដល់ធំពេញ វ័យដែលរូបលោកទាំងពីរបាន លះបង់គ្រប់យ៉ាងនូវកម្លាំងកាយចិត្ត ថវិការ អប់រំ ទូន្មានប្រៀបប្រដៅ ព្រមទាំង ផ្គត់ផ្គង់នូវតម្រូវជា ថវិកា សម្ភារៈប្រើប្រាស់ក្នុងការសិក្សា លោកទាំងពីរផ្តល់ឲ្យ គ្រប់យ៉ាងនូវកម្លាំងកាយចិត្ត ផ្នែកបញ្ញាស្មារតី លើកទឹកចិត្ត ក្នុងការខិតខំប្រឹង ប្រែងរៀនសូត្រ ក្រេបយកនូវចំណេះដឹងតាំងពីរូបកូននៅតូចរហូតកូនបានបញ្ចប់ ថ្នាក់បរិញ្ញាបត្រនេះ ។ គុណូបការៈ និងព្រហ្មវិហាធម៌របស់លោកអ្នកមានគុណ ទាំងពីរចំពោះយើងខ្ញុំពិតជាមានទំហំធំធេងរកអ្វីប្រៀបផ្ទឹមពុំបានឡើយ ដែលធ្វើ ឲ្យកូនមិនអាចបំភ្លេចបាននូវ គុណធម៌ និង ព្រហ្មវិហាធម៌ទាំងនេះនឹងស្ថិតនៅក្នុង ចិត្តកូនជានិច្ចដរាប។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្ត សេដ្ឋកិច្ច ដែលបានផ្តល់ឱកាសឲ្យយើងខ្ញុំបានចូលសិក្សា និងបានផ្ទេរនូវចំណេះដឹង បទពិសោទន៍ ឯកសារ សិក្សាស្រាវជ្រាវដែលជាប្រទីបបំភ្លឺផ្លូវដល់យើងខ្ញុំក្នុងការសិក្សារៀនសូត្រកន្លងមក ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់លោកសាស្ត្រាចារ្យ **ហ៊ាន ឡេខ** ដែលបានទទួលយកនូវការដឹកនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ ជាពិសេសបានណែនាំ និងកែសម្រួលនូវរចនាបទនៃប្រធានបទមួយនេះឲ្យកាន់តែមានអត្ថន័យនឹងខ្លឹមសារល្អឡើងលោកសាស្ត្រាចារ្យ បានចំណាយនូវពេលវេលាដ៏មមាញឹកនិងមានតម្លៃក្នុងការបង្ហាត់បង្ហាញយើងខ្ញុំ ។

ជាចុងក្រោយយើងខ្ញុំសូមគោរពជូនពរ និង លើកហត្ថបួងសួងដល់គុណ ព្រះរតនត្រៃយ៍ គុណកែវទាំងបីអស់វត្ថុស័ក្តិសិទ្ធិក្នុងលោក ជួយតាមថែរក្សា លោកឪពុក អ្នកម្តាយ ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ ឲ្យជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងជួបប្រកប តែសុខសួរស្តីគ្រប់ប្រការកុំបីឃ្លាតឃ្លាឡើយ ។

# **អារម្ភកថា**

ជាកិច្ចចាប់ផ្តើម នាងខ្ញុំ **ក. ទ៉ាន់ សូលីតា** និង **ក. សុខ គីមឃួរ** ជានិស្សិតកំពុងសិក្សានៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ។ នាងខ្ញុំសូមធ្វើការស្វាគមន៍យ៉ាងកក់ក្តៅដល់មិត្តអ្នកអានទាំងអស់គ្នា ជាពិសេសសិស្សនិស្សិតជាទីរាប់អាន ព្រមទាំងសាស្ត្រាចារ្យជាទីគោរព ។

យើងខ្ញុំពិតជារីករាយជាខ្លាំងដែលមានកិត្តិយសបានចូលរួមក្នុងការចងក្រងសរសេរសារណាបញ្ចប់ការសិក្សានេះ ។ ដោយការសិក្សារបស់យើងមានការទាក់ទងជាមួយផ្នែកច្បាប់ ដូចនេះយើងខ្ញុំបានជ្រើសយកប្រធានបទស្តីពី " អង្គការអយ្យការ " ក្នុងគោលបំណងបង្ហាញអំពីអំណាចឯករាជ្យរបស់ អង្គការអយ្យការ ដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ ។ ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយដែលមាននៅអមគ្រប់សាលាជម្រះក្តី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាអ្នកតំណាងឲ្យសង្គម និងជាអ្នកតំណាងការពារផលប្រយោជន៍សាធារណៈ និង ធ្វើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌទៅលើជនដែលបានប្រព្រឹត្តបទល្មើស ។ ហើយស្ថាប័នអយ្យការក៏ជាស្ថាប័នមួយដែលមាន សារៈសំខាន់ណាស់នៅក្នុងការដំណើរការរឿងក្តីព្រហ្មទណ្ឌ ព្រោះថា អំពើគំរាមកំហែងតែងតែកើតមានឡើងនៅគ្រប់សង្គមទាំងអស់លើពិភពលោកយើងនេះ និង ជះឥទ្ធិពលដល់សណ្តាប់ធ្នាប់សាធារណៈ ដែលធ្វើឲ្យរាំខាន់ដល់ការអភិវឌ្ឍន៍ប្រទេស ។

យើងខ្ញុំសង្ឃឹមថា សារណាដែលយើងខ្ញុំបានសរសេរនេះនឹងក្លាយជាឯកសារផ្នែកច្បាប់មួយដែលមានអត្ថប្រយោជន៍ទៅដល់មិត្តអ្នកអានទាំងអស់គ្នា ក្នុងការពង្រឹងនឹងលើកស្ទួយវិស័យផ្នែកច្បាប់ឲ្យកាន់តែរឹងមាំ ។ ជាមួយគ្នានេះដែលយើងខ្ញុំក៏សង្ឃឹមថាឯកសារមួយច្បាប់ដែលយើងខ្ញុំបានរៀបរៀងឡើងមកនេះ និងក្លាយជាជំនួយអាចជួយពង្រឹងដល់មុខវិជ្ជា ទាំងឡាយណាដែលទាក់ទងនឹងផ្នែកច្បាប់ឲ្យកាន់តែបានយល់ច្បាស់ពីស្ថាប័នមួយនេះ ។

ការសិក្សា ចងក្រងសារណាមួយនេះឡើង ពិតណាស់ថានឹងមានចំណុចខ្វះខាតនូវរាល់ពាក្យពេចន៍ ខ្លឹមសារ ក៏ដូចជាកំហុសអក្ខរាវិរុទ្ធជាក់ជាពុំខាន់ ។ យើងខ្ញុំជានិស្សិតធ្វើការចងក្រងនេះនឹងរងចាំទទួល និងស្វាគមន៍ចំពោះមតិយោបល់ ការរិះគន់ សម្រាប់កែលម្អបន្ថែមដើម្បីបំពេញបន្ថែមរាល់ចំណុចខ្វះខាតពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ សិស្សនិស្សិត នឹងមិត្តអ្នកអានដោយក្តីគោរព ។ ជាមួយគ្នានេះផងដែរ យើងខ្ញុំសូមការអភ័យទោសចំពោះកំហុសឆ្គងដោយ អចេតនាដែលកើតមានឡើងក្នុងកិច្ចការមួយនេះផង ។

ជាចុងក្រោយសូម លោក លោកស្រី សាស្ត្រាចារ្យ សិស្សនិស្សិត នឹងមិត្តអ្នកអានទាំងអស់ជួបប្រទះតែនឹង ពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ដោយក្តីគោរពអរគុណ!!

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................................ ១

## ជំពូកទី១
## សញ្ញាណទូទៅនៃអង្គការអយ្យការ

**ផ្នែកទី១៖ ការរៀបចំនៃអង្គការអយ្យការ** ........................................ ២

**កថាខណ្ឌទី១៖ រចនាសម្ព័ន្ធនៃអង្គការអយ្យការ** ........................................ ២

១. អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ........................................ ៣

២. អង្គការមហាអយ្យការអមតុលាការជាន់ខ្ពស់ ........................................ ៣

**កថាខណ្ឌទី២៖ គោលការណ៍នៃការរៀបចំអង្គការអយ្យការ** ........................................ **៥**

១.គោលការណ៍ឋានានុក្រម ........................................ ៥

២.គោលការណ៍អវិភាគយភាព ........................................ ៧

៣. គោលការណ៍ឯករាជ្យរវាងអង្គការអយ្យការ និង តុលាការ ........................................ ៨

**ផ្នែកទី២៖ តំណាងអយ្យការ** ........................................ **៨**

**កថាខណ្ឌទី១៖ ការចូលបម្រើការជាតំណាងអយ្យការ** ........................................ **៩**

១.ការចុះកម្មសិក្សា និង ការទទួលបានអត្ថប្រយោជន៍ ........................................ ៩

២. ការតំឡើងថ្នាក់ និង ឋានន្តរស័ក្តិ ........................................ ១០

**កថាខណ្ឌទី២៖ ការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈក្នុងនាមជាតំណាងអយ្យការ** ........................................ **១១**

១. កាតព្វកិច្ចដែលត្រូវបំពេញ ........................................ ១១

២. ទណ្ឌកម្មផ្នែកវិន័យ ........................................ ១៣

## ជំពូកទី២
## តួនាទីរបស់អង្គការអយ្យការ

**ផ្នែកទី១៖ មុខការនៃអង្គការអយ្យការ** ........................................ ១៦

**កថាខណ្ឌទី១៖ អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត** ........................................ **១៦**

១. អំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត ........................................ ១៦

២. សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា ........................................ ១៧

**កថាខណ្ឌទី២៖ អង្គការមហាអយ្យការអមតុលាការជាន់ខ្ពស់** ........................................ **១៧**

១. មហាអយ្យការអមសាលាឧទ្ធរណ៍ ........................................ ១៧
២. មហាអយ្យការអមតុលាការកំពូល ........................................ ១៩
**ផ្នែកទី២៖ ការអនុវត្តបណ្តឹងអាជ្ញាដោយតំណាងអយ្យការ ........................................ ២០**
**កថាខណ្ឌទី១៖ បណ្តឹងអាជ្ញា ........................................ ២០**
១. ភាពខុសគ្នារវាងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី ........................................ ២១
២. ការរលត់បណ្តឹងអាជ្ញា ........................................ ២២
**កថាខណ្ឌទី២៖ សេចក្តីសម្រេចនៃតំណាងអយ្យការក្នុងការចោទប្រកាន់ ........................................ ២៥**
១. ការតម្កល់រឿងទុកឥតចាត់ការ ........................................ ២៦
២. ជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការ ........................................ ២៨
ក. ការបើកការស៊ើបសួរ ........................................ ២៨
ខ. ការជំនុំជម្រះផ្ទាល់ ........................................ ២៩
គ. ការបង្ហាញខ្លួនភ្លាមៗ ........................................ ៣០

## **ជំពូកទី៣.**

## **ស្ថាប័នអយ្យការក្នុងកិច្ចនីតិវិធីរឿងក្តីព្រហ្មទណ្ឌ**

**ផ្នែកទី១៖ ការដឹកនាំការស៊ើបអង្កេតរបស់អយ្យការ ........................................ ៣៣**
**កថាខណ្ឌទី១៖ ការស៊ើបអង្កេតករណីជាក់ស្តែង ........................................ ៣៤**
១. លក្ខខណ្ឌនៃការបើកការស៊ើបអង្កេតករណីជាក់ស្តែង ........................................ ៣៤
២. ការចុះទៅកន្លែងកើតហេតុ ........................................ ៣៦
៣.ការឆែកឆេរ និងការប្រមូលភស្តុតាង ........................................ ៣៧
៤. ការស្តាប់ចម្លើយ ........................................ ៣៩
៥. ការត្រួតពិនិត្យផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ ........................................ ៤០
៦. ការឃាត់ខ្លួន និងការបញ្ជូនខ្លួន ........................................ ៤១
៧. ការស្តាប់ការសន្ទនាតាមប្រព័ន្ធបច្ចេកវិទ្យា ........................................ ៤៥
**កថាខណ្ឌទី២៖ ការស៊ើបអង្កេតបឋម ........................................ ៤៦**
១. ការបើកការស៊ើបអង្កេតបឋម ........................................ ៤៧
២. ការឆែកឆេរ ........................................ ៤៧
៣. ការបញ្ជាឲ្យចូលខ្លួន ........................................ ៤៨

**ផ្នែកទី២៖ អយ្យការក្នុងដំណើរការនៃការជំនុំជម្រះ**........................................................៤៩
**កថាខណ្ឌទី១៖ នីតិវិធីមុនពេលកិច្ចពិភាក្សាដេញដោល** ...........................................................៤៩
**កថាខណ្ឌទី២៖ អំឡុងពេល និងការបញ្ចប់កិច្ចពិភាក្សាដេញដោល** ...........................................៥០
**ផ្នែកទី៣៖ អយ្យការក្នុងដំណើរការនៃការអនុវត្តទោស**..................................................៥០
**កថាខណ្ឌទី១៖ វិធានទាក់ទងនឹងការឃុំខ្លួន** ..........................................................................៥១
១. ការគ្រប់គ្រងពន្ធនាគារ ......................................................................................................៥២
២. ការធ្វើអធិការកិច្ចពន្ធនាគារ.................................................................................................៥២
**កថាខណ្ឌទី២៖ ការដោះលែងដោយមានលក្ខខណ្ឌ**.................................................................. ..៥៣
១. លក្ខខណ្ឌផ្សេងៗក្នុងការដោះលែងទណ្ឌិត ..............................................................................៥៤
២. សេចក្តីសម្រេចទាក់ទងទៅនឹងការដោះលែងដោយមានលក្ខខណ្ឌ.................................................៥៥
**កថាខណ្ឌទី៣៖ ការបង្ខំដល់រូបកាយ**..........................................................................................៥៥
១. ថិរវេលានៃការបង្ខំដល់រូបកាយ ...........................................................................................៥៦
២. ការរួចផុតពីការបង្ខំដល់រូបកាយ ..........................................................................................៥៧
**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ..............................................................................................៥៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ចាប់តាំងពីសម័យបុរាណរហូតមកដល់សម័យបច្ចុប្បន្ននេះ យើងសង្កេតឃើញថាប្រព័ន្ធច្បាប់សម្រាប់គ្រប់គ្រងទៅលើរដ្ឋនីមួយៗ ត្រូវបានបង្កើតឡើងមានលក្ខណៈខុសប្លែកពីគ្នា ។ ក្នុងនោះដែរ មានតែប្រព័ន្ធច្បាប់ពីរប្រភេទតែប៉ុណ្ណោះ ដែលនិយមយកមកអនុវត្តដោយរដ្ឋផ្សេងៗគឺ ប្រព័ន្ធច្បាប់ Common Law និងប្រព័ន្ធច្បាប់ Civil Law ។ ចំណែកឯប្រទេសកម្ពុជាវិញ ដោយសារការទទួលរងនូវឥទ្ធិពលនៃការដាក់អាណានិគមពីប្រទេសបារាំងអស់រយៈពេលជាច្រើនទសវត្សរ៍ ដែលជាហេតុធ្វើឲប្រទេសកម្ពុជាត្រូវ កសាងនូវប្រព័ន្ធច្បាប់ Civil Law ។ ហេតុនេះហើយ ទើបប្រទេសកម្ពុជាបានជ្រើសរើស និងកសាងប្រព័ន្ធច្បាប់របស់ខ្លួន និងបន្សល់ទុកដល់បច្ចុប្បន្ននេះ គឺប្រព័ន្ធច្បាប់ Civil Law ។

នៅក្នុងសារណាបញ្ចប់ការសិក្សាដែលផ្តោតទៅលើប្រធានបទ «**អង្គការអយ្យការ**» នេះនឹងធ្វើការបកស្រាយ និង ប្រមូលឯកសារដោយការរួមបញ្ចូលគ្នាទាំងអស់ទៅលើឯកសារណាដែល ទាក់ទងទៅនឹងអង្គអយ្យការ ដែលនៅក្នុងសារណាបញ្ចាប់ការសិក្សានេះ និង ធ្វើការពន្យល់និងលើកឡើងនូវចំណុចជាច្រើនដែលទាក់ទងទៅ នឹងឋានានុក្រមនៃអយ្យការ និងគោលការណ៍សំខាន់ៗនៃអង្គការអយ្យការផងដែរ។ មិនតែប៉ុណ្ណោះពួកយើងក៏បានលើកឡើងនូវចំណុចដែលទាក់ទងទៅ នឹង ការជ្រើសរើសព្រះរាជអាជ្ញានៅក្រោយពេលបញ្ចប់ការចុះកម្មសិក្សាពេញលេញ ។ ជាពិសេសជាងនេះទៅទៀតនោះគឺ សារណានេះក៏បានធ្វើការបង្ហាញពីតួនាទីនិងអំណាចរបស់ព្រះរាជអាជ្ញា ដែលនៅអមសាលាជម្រះក្តីទាំងបីជាន់ថ្នាក់ដែលនៅសាលាដំបូងបានបែងចែកជាច្រើនដូចជា អំណាចក្នុងការធ្វើបណ្តឹងអាជ្ញា អំណាចក្នុងការធ្វើការស៊ើបអង្កេតបឋម អំណាចក្នុងការឃាត់ខ្លួន អំណាចក្នុងការបញ្ជូនខ្លួន និងអំណាចក្នុងការឆែកឆេរផងដែរ ។ ទាក់ទងផងដែរទៅលើអំណាចរបស់ព្រះរាជអាជ្ញាផងដែរ ដែលមានដូចជាសិទ្ធិក្នុងការតម្កល់រឿងឥតចាត់ការ អំណាចក្នុងការចោទប្រកាន់ ការបើកការស៊ើបសួរ ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និងការបង្ហាញខ្លួនផងដែរ ក៏ដូចជាអំណាចដ៏ទៃទៀតនៅក្នុងសាលាឧទ្ធរណ៍ និងកំពូលនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងនេះ ។ ជាចុងក្រោយនេះពួកយើងក៏បានធ្វើការដាក់បញ្ចូលនូវអយ្យការក្នុងដំណើរការនៃការអនុវត្តទោស ដែលមានវិធានទាក់ទងនិងការឃុំខ្លួន ការដោះលែងដោយមានលក្ខខណ្ឌ នឹងការបង្ខំដល់រូបកាយផងដែរ។

# ជំពូកទី១

# សញ្ញាណទូទៅនៃអង្គការអយ្យការ

ពាក្យថា « **អយ្យការ** » គឺជាស្ថាប័នមួយនៅដាច់ដោយឡែកពីតុលាការថ្វីត្បិតតែស្ថាប័ននេះនៅក្នុងបរិវេណតុលាការក៏ពិតមែន តែស្ថាប័នអយ្យការនេះ មានអ្នកដឹកនាំផ្សេងពីតុលាការ ដូចនេះយើងត្រូវបែងចែកឲ្យដាច់ពីតួនាទីអយ្យការ និង មុខងារតុលាការ ។[1] នៅអមសាលាក្ដីគ្រប់ជាន់ថ្នាក់រួមមាន តុលាការខេត្ត- រាជធានី តុលាការយោធា សាលាឧទ្ធរណ៍ និង តុលាការកំពូល តែងតែមានអយ្យការ ឬ មហាអយ្យការមួយជានិច្ច ដែលជាអ្នកមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា ។[2] អង្គការអយ្យការនេះមានភារកិច្ចស្វែងរកជនល្មើសប្រមូលភស្តុតាងចោទប្រកាន់ជនល្មើសបញ្ជូនជនល្មើសទៅតុលាការកាត់ទោស និង តាមដានការអនុវត្តសាលក្រមរបស់តុលាការ ។ នៅក្នុងកាបំពេញ ភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការ មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ ។[3] អង្គការអយ្យការ មិនមែនជាស្ថាប័នដែលទទួលបន្ទុកក្នុងការជម្រះក្ដីដូចតុលាការឡើយ តែអយ្យការគឺជាភាគីនៃរឿងក្ដីព្រហ្មទណ្ឌដែលជាអ្នកតំណាងឲ្យផលប្រយោជន៍ទូទៅដល់ជនរងគ្រោះ ។ ដូចនេះ ដើម្បីអាចបំពេញនូវតួនាទីរបស់ខ្លួនក្នុងនាមជាភាគីនៃរឿងក្ដីអយ្យការ ត្រូវមានអ្នកតំណាងរបស់ខ្លួននៅគ្រប់សាលាជម្រះក្ដី ដែលអ្នកតំណាងនោះគឺជាមន្ត្រីក្នុងស្ថាប័នអយ្យការ ដែលគេហៅថា "**តំណាងអយ្យការ**" ។ ដើម្បីងាយស្រួលដល់ការសិក្សាស្វែងយល់បន្ថែមអំពីអង្គការអយ្យការ យើងត្រូវការរៀបចំនៃអង្គការអយ្យការ (**ផ្នែកទី១**) នឹងត្រូវដឹងបន្ថែមអំពីតំណាងអយ្យការមួយទៀត (**ផ្នែកទី២**) ។

## ផ្នែកទី១៖ ការរៀបចំនៃអង្គការអយ្យការ

អង្គការអយ្យការត្រូវបានរៀបចំឡើងដោយមាន រចនាសម្ព័ន្ធនៃអង្គការអយ្យការ (**កថាខណ្ឌទី១**) និង គោរពទៅតាមគោលការណ៍នៃការរៀបចំអង្គការអយ្យការ (**កថាខណ្ឌទី២**) ។

### កថាខណ្ឌទី១៖ រចនាសម្ព័ន្ធនៃអង្គការអយ្យការ

ដើម្បីយល់កាន់តែច្បាស់អំពីសមាសភាពនិងភារកិច្ចរបស់អង្គការអយ្យការ យើងត្រូវដឹងអំពីរចនាសម្ព័ន្ធរបស់អង្គការអយ្យការធំៗចំនួន ២ ជាមុនសិនគឺ អង្គការអយ្យការដែលនៅអមសាលាដំបូងរាជធានី-ខេត្ត (**១**) និង អង្គការអយ្យការដែលនៅអមតុលាការជាន់ខ្ពស់ (**២**) ។

---

[1] សូមមើល ចំនុចទី១០ នៃគោលការណ៍ណែនាំស្ដីពីតួនាទីរបស់ព្រះរាជអាជ្ញា ដែលអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ស្ដីពីការបង្ការបទឧក្រិដ្ឋ និង ការគ្រប់គ្រងជនល្មើសនាទីក្រុង ហាវ៉ាហា នៃប្រទេសគុយបា នៅថ្ងៃទី ២៧ ខែ សីហាដល់ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០។

[2] សូមមើល មាត្រា ១៣១ថ្មី (មាត្រា ១១២ ចាស់) នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ត្រូវបានសភាធម្មនុញ្ញអនុម័តនៅថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ ។

[3] សូមមើល មាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

**១. អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត**

នៅអមសាលាដំបូងរាជធានី-ខេត្ត ត្រូវមានអង្គការអយ្យការមួយ ហៅថា " **អយ្យការអមសាលាដំបូង** " ។ អយ្យការអមសាលាដំបូង ត្រូវដឹងនាំដោយព្រះរាជអាជ្ញា ១ រូប និងអមដោយព្រះរាជ្ញារងមួយចំនួនតាមការចាំបាច់ ។[4] ព្រះរាជអាជអាជ្ញា និង ព្រះរាជអាជ្ញារងអយ្យការអមសាលាដំបូង ជាតំណាងអយ្យការអមសាលាដំបូង ដែលខ្លួនបំពេញការងារ ។[5]

សមាសភាពអយ្យការអមសាលាដំបូង រួមមាន ៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និង អាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅអយ្យការអម សាលាដំបូង ។[6]

**២. អង្គការមហាអយ្យការអមតុលាការជាន់ខ្ពស់**

នៅសាលាជម្រះក្តីជាន់ខ្ពស់ ត្រូវបានបែងចែកជាពីរ គឺសាលាឧទ្ធរណ៍ និងតុលាការកំពូល ។ ដូចនេះ អង្គការអយ្យការដែលនៅអមតុលាការជាន់ខ្ពស់ ត្រូវបានបែកចែកចេញជា មហាអយ្យការអមតុលាការកំពូល (**ក**) និង មហាអយ្យការអមសាលាឧទ្ធរណ៍( **ខ** ) ។

**ក.មហាអយ្យការអមតុលាការកំពូល**

នៅអមតុលាការកំពូល ត្រូវមានអង្គការអយ្យការមួយហៅថា **មហាអយ្យការអមតុលាការកំពូល** ។ បើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ មហាអយ្យការអមតុលាការកំពូល មានតំណាងនៃអង្គការអយ្យការអមតុលាការនេះដូចជា៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង និង
- ព្រះរាជអាជ្ញា ។[7]

---

[4] សូមមើល មាត្រា ៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

[5] សូមមើល មាត្រា ៣០ កថាខណ្ឌទី២ នៃច្បាប់ស្តីការរៀបចំអង្គការតុលាការ, នស/រកត/០៧១៤/០១៥, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤។

[6] សូមមើល មាត្រា ២៩ នៃច្បាប់ស្តីការរៀបចំអង្គការតុលាការ, នស/រកត/០៧១៤/០១៥, ប្រកាសឲ្យប្រើនាថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

[7] សូមមើល មាត្រា ៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

បើយោងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មហាអយ្យការអមតុលាការកំពូលមានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និង អាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមតុលាការកំពូល ។[8]

**ខ. មហាអយ្យការអមសាលាឧទ្ធរណ៍**

នៅអមសាលាឧទ្ធរណ៍ ត្រូវមានអង្គការអយ្យការមួយហៅថា **មហាអយ្យការអមសាលាឧទ្ធរណ៍** ។ បើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ មហាអយ្យការអមសាលាឧទ្ធរណ៍ មានតំណាងនៃអង្គការអយ្យការអមតុលាការនេះដូចជា៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង និង
- ព្រះរាជអាជ្ញា ។[9]

បើយោងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មហាអយ្យការអមសាលាឧទ្ធរណ៍មានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍ ។[10]

---

[8] សូមមើល មាត្រា ៦៨ នៃច្បាប់ស្តីការរៀបចំអង្គការតុលាការ, នស/រកត/០៧១៤/០១៥, ប្រកាសឲ្យប្រើនាថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

[9] សូមមើល មាត្រា ៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

[10] សូមមើល មាត្រា ៤៩ នៃច្បាប់ស្តីការរៀបចំអង្គការតុលាការ, នស/រកត/០៧១៤/០១៥, ប្រកាសឲ្យប្រើនាថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

## កថាខណ្ឌទី២៖ គោលការណ៍នៃការរៀបចំអង្គការតុលាការ

គោលការណ៍នៃការរៀបចំអង្គការតុលាការ ឡើងដើម្បីធានាឲ្យបាននូវឯករាជ្យនៃអំណាចតុលាការ ដោយចៅក្រមអាសនៈត្រូវទទួលបានឯករាជ្យភាពពេញលេញពីគ្រប់មជ្ឈដ្ឋាន ក្នុងអំឡុងពេលនៃការវិនិច្ឆ័យរឿងក្តីរបស់ ខ្លួន ។ មួយវិញទៀត " ចៅក្រមទាំងឡាយត្រូវសម្រេចសេចក្តីដោយមិនលំអៀង ដោយឈរលើគោលការណ៍គោរពច្បាប់ដោយមិនទទួលការគាប់សង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីភាគីណាមួយក្នុងរឿងក្តី ឬពីបុគ្គលណាមួយឡើយ ។[11] ប៉ុន្តែចៅក្រមអយ្យការ គឺមិនទទួលបានឯករាជ្យពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឡើយ ព្រោះរដ្ឋមន្ត្រីជានាដល់ការអនុវត្តនៃគោលនយោបាយទាំងនោះហើយ ទើបចៅក្រមអយ្យការត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ជាទូទៅ ការរៀបចំអង្គការអយ្យការ ត្រូវបានគោរពគោលការណ៍ចំនួន ៣ គឺ គោលការណ៍ឋានានុក្រម (**១**), គោលការណ៍អវិភាគីយភាព (**២**), គោលការណ៍ឯករាជ្យរវាងអង្គការអយ្យការ និងតុលាការ (**៣**) ។

### ១.គោលការណ៍ឋានានុក្រម

គោលការណ៍នេះត្រូវបានមជ្ឈដ្ឋានមួយចំនួនបានហៅថា គោលការណ៍ឋានានុក្រម ហើយបើទៅតាមការយល់ឃើញផ្ទាល់ខ្លួនថាជា "**គោលការណ៍ឯករាជ្យ**" ។ គោលការណ៍នេះបានកំណត់អង្គការអយ្យការជាអង្គភាពមួយ ដែលតំណាងអយ្យការត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យដោយនាយឋានានុក្រមរបស់ខ្លួន ដែលមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជានាយឋានានុក្រមខ្ពស់ជាងគេក្នុងអង្គការអយ្យការ និងអាចធ្វើអធិបញ្ជាជាលាយលក្ខណ៍អក្សរបញ្ជាទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់លើកលែងតែមហាអយ្យការអមតុលាការកំពូល ។ ចំពោះឋានានុក្រមនៅតាមអង្គការអយ្យការវិញត្រូវបានបែងចែកដូចតទៅ ៖[12]

- **មហាអយ្យការអមតុលាការកំពូល**
  - អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយកឋានានុក្រមនៃមហាអយ្យការអមតុលាការកំពូល។
  - អគ្គព្រះរាជអាជ្ញារង និង ព្រះរាជអាជ្ញា ត្រូវធ្វើការក្រោមការដឹកនាំ និងូមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

[11] សូមមើលមាត្រា ៨ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស /រកម /០៧១៤ /០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ ។

[12] សូមមើល មាត្រា ៧៥, កថាខណ្ឌទី១, នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

- **មហាអយ្យការអមសាលាឧទ្ធរណ៍**
  - អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានាយកឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍។
  - អង្គព្រះរាជអាជ្ញារង និង ព្រះរាជអាជ្ញា ត្រូវធ្វើការក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់អង្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន ។
- **មហាអយ្យការអមសាលាដំបូងរាជធានី-ខេត្ត**
  - ព្រះរាជអាជ្ញាអមសាលដំបូង គឺជានាយកឋានានុក្រមនៃអយ្យការអមសាលាដំបូង ។
  - ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូង ត្រូវធ្វើការក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន ។

ក្រៅពីនេះ នៅក្នុងក្របខណ្ឌនៃដំណើរការរឿងក្ដីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាត្រូវគោរពអធិបញ្ញារបស់នាយឋានានុក្រម ដែលមានអង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចប្ដឹងបរិហារ ឬធ្វើអធិបញ្ញាទៅកាន់អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង ដើម្បីឲ្យអង្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាតាមការយល់ឃើញរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ទោះជាអង្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាមិនចង់ធ្វើការបើកបណ្ដឹងអាជ្ញានៅក្នុងរឿងហេតុនោះក៏ដោយ ។ ប៉ុន្តែការធ្វើអធិបញ្ញាទាំងនេះ ពុំអាចមានកម្មវត្ថុក្នុងការបញ្ជាឲ្យអ្នកស្ថិតក្រោមឋានានុក្រមទៅតម្កល់រឿងទុកឥតចាត់ការឡើយ គឺអាចធ្វើអធិបញ្ញា បញ្ជាឲ្យធ្វើការចោទប្រកាន់ ឬ ធ្វើសេចក្ដីសន្និដ្ឋានតាមការយល់ឃើញរបស់ខ្លួនតែប៉ុណ្ណោះ ។ មួយវិញទៀត រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចធ្វើអធិបញ្ញាដល់អង្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាឲ្យធ្វើការតម្កល់រឿងទុកឥតចាត់ការនូវរឿងក្ដីព្រហ្មទណ្ឌណាមួយបានឡើយ ។ អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។ អង្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឲ្យចោទប្រកាន់ ឬ ក៏ចាត់ឲ្យចោទប្រកាន់ ឬ ក៏ធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណា ដែលខ្លួនយល់ឃើញថាជាការគួរ ។[13]

គួរបញ្ជាក់ផងដែលថា ក្នុងករណីដែលព្រះរាជអាជ្ញា បានប្រគល់រឿងទៅឲ្យព្រះរាជអាជ្ញារងណាមួយនោះការសម្រេចយ៉ាងណារបស់ព្រះរាជអាជ្ញារងនោះគឺធ្វើឡើងតំណាងឲ្យអយ្យការនោះទាំងមូល ដោយយោងទៅតាមគោលការណ៍អវិភាគីយភាព ដែលអយ្យការគឺជាតួរអង្គឯកភាពតែមួយ ។ ដូច្នេះ បើព្រះរាជអាជ្ញារងបានសម្រេចធ្វើការតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញានៃដែនសមត្ថកិច្ចមិនអាចធ្វើអធបញ្ញា បញ្ជាមកព្រះរាជអាជ្ញារងឲ្យធ្វើការចោទប្រកាន់វិញបានឡើយ ទោះមានបណ្ដឹងពីជនរងគ្រោះក៏ដោយ ។

[13] សូមមើល មាត្រា២៩, វាក្យខណ្ឌទី១នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

នៅក្នុងករណីនេះ មានតែអង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តែមួយគត់ដែលអាចធ្វើអធិបញ្ញា បញ្ជាឲ្យតម្កល់រឿងទុកឥតចាត់ការនោះ មានន័យថាសើរើរឿងក្តីឡើងវិញក្នុងគោលបំណងដាក់ឲ្យដំណើរការបណ្តឹងអាជ្ញា ។

ដូចនេះ ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារងទាំងឡាយត្រូវគោរពនូវគោលការណ៍ឋានានុក្រម ឬ អធិបញ្ញារបស់ថ្នាក់លើ ។ ទោះយ៉ាងណាក៏ដោយ ជាអញ្ញត្រកម្មពេលសវនាការ[14] ចៅក្រមអយ្យការមានសេរីភាពខាងយោបល់របស់ខ្លួន មានន័យថា ចៅក្រមអយ្យការអាចធ្វើបណ្តឹងដោយផ្ទាល់មាត់ទៅតាមការយល់ឃើញរបស់ខ្លួនក្នុងពេល សវនាការ គឺគាត់មានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ស្របតាមសតិសម្បជញ្ញៈរបស់ខ្លួនបាន ។[15] ការធ្វើសេចក្តីសន្និដ្ឋាននេះ អាចមានលក្ខណៈមិនស្របនឹងអធិបញ្ញារបស់នាយឋានុក្រម។ ការធ្វើបណ្តឹងដោយផ្ទាល់មាត់នេះ មិនមែនជាមូលដ្ឋានក្នុងការចោទប្រកាន់ពីបទវិន័យណាមួយឡើយ។ គោលការណ៍នេះក៏បានកំណត់ក្នុងនីតិខ្មែរកាលពីសម័យមុនដែរ ដែលគេបានដាក់ឈ្មោះថា " ប៉ាកកាជាទាសី សម្តីដោយសេរី " ។[16]

សូមគូសបញ្ជាក់ផងដែរថា រាល់ការធ្វើអធិបញ្ញា គឺមិនមានកាតទាក់ទងទៅនឹងអង្គព្រះរាជអាជ្ញាអមតុលាការកំពូលនោះឡើយ ដោយហេតុថា នៅតុលាការកំពូលគឺចៅក្រមកាត់សេចក្តីតែលើអង្គច្បាប់នោះទេ មិនកាត់សេចក្តីទៅលើអង្គហេតុឡើយ ដែលផ្ទុយទៅនឹងការធ្វើអធិបញ្ញាដែលសុទ្ធសឹងតែជានីតិវិធីដោយផ្អែកទៅលើអង្គហេតុទាំងស្រុង ដើម្បីអាចធ្វើអធិបញ្ញាបាន។

### ២.គោលការណ៍អវិភាគីយភាព

គោលការណ៍អវិភាគីយភាព ត្រូវបានអ្នកច្បាប់មួយចំនួនហៅថា " **គោលការណ៍នៃភាពមិនអាចចែកដាច់ពីគ្នារបស់អង្គការអយ្យការ ឬ គោលការណ៍អវិភាគ** ។ គោលការណ៍នេះដែលសំដៅដល់ការកំណត់ឲ្យអង្គការអយ្យការក្លាយជាអង្គអវិភាគមួយ មានន័យថាព្រះរាជអាជ្ញាមានកាតព្វកិច្ចរួមក្នុងមុខងាដូចគ្នាក្នុងស្ថាប័នអយ្យការរបស់ខ្លួន ព្រោះសកម្មភាពនៃការបំពេញមុខងារនោះធ្វើឡើងក្នុងក្របខណ្ឌនៃអយ្យការដែលខ្លួនកំពុងឈរជើង ។ យោងតាមអង្គអវិភាគនេះ ការបំពេញមុខងារនៃតំណាងអយ្យការនីមួយៗ អាចជំនួសគ្នាទៅវិញទៅមកបានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

---

14 "សវនាការ" គឺជាការបើកកិច្ចជំនុំជម្រះដែលក្នុងឱកាសនោះចៅក្រមសួរដេញដោល និង ស្តាប់ការចោទប្រកាន់របស់ក្រុមអយ្យការ ហើយវិនិច្ឆ័យសេចក្តី ។ (ដកស្រង់ចេញពី «សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែកច្បាប់»ដែលត្រូវបានរៀបចំឡើងដោយ គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, រក្សាសិទ្ធិ បោះពុម្ពលើកទី១ ដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០១១ ។

15 សូមមើល មាត្រា៣០, កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

16 សូមមើលទូរទស្សន៍ជាតិកម្ពុជា (ទទក), កម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៨ ។

" គោលការណ៍នេះ តំណាងអយ្យការច្រើនរូបអាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម ។[17] ជាដំបូង ព្រះរាជអាជ្ញាជាអ្នកធ្វើសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងចេញសេចក្តីសន្និដ្ឋានស្ថាពរ ប៉ុន្តែគាត់ក៏អាចបញ្ជាឲ្យព្រះរាជអាជ្ញារងណាម្នាក់មកជំនួសគាត់នៅក្នុងដំណាក់កាលជំនុំជម្រះបានដែរ ។

### ៣.គោលការណ៍ឯករាជ្យរវាងអង្គការអយ្យការនិងតុលាការ

នៅក្នុងគោលការណ៍នេះ អំណាចត្រូវបានបែងចែកជាបីដាច់ពីគ្នាគឺ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ ។ ចំពោះស្ថាប័នអយ្យការដែលស្ថិតនៅក្រោមគោលការណ៍ឋានានុក្រមនៃរដ្ឋមន្រ្តីក្រសួងយុត្តិធម៌ក្នុងអំណាចនីតិប្រតិបត្តិ ត្រូវតែឯករាជ្យគ្នាពីអំណាចតុលាការផងដែរ ។

មួយវិញទៀត អយ្យការដែលនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ គឺមិនស្ថិតនៅក្រោមចំណុះឲ្យស្ថាប័នជម្រះក្តីដែលខ្លួននៅអមឡើយ ទោះបីជាខ្លួនស្ថិតក្នុងបរិវេណតែមួយជាមួយនឹងសាលាជម្រះក្តីនោះក៏ដោយ ។ ហេតុនេះចៅក្រមអាសនៈ ឬប្រធានតុលាការគ្មានសិទ្ធិអំណាចក្នុងការត្រួតពិនិត្យទៅលើកិច្ចការរបស់ចៅក្រមអយ្យការឡើយ និងគ្មានសិទ្ធិក្នុងការស្តីបន្ទោសដោយប្រយោល ឬដោយផ្ទាល់ណាមួយឡើយ ទោះបីជាក្នុងករណីដែល ព្រះរាជអាជ្ញាមានកំហុសខុសឆ្គងណាមួយក្នុងការបំពេញមុខងារក៏ដោយ ។ " ការហាមឃាត់នេះត្រូវអនុវត្តទាំងក្នុងរឿងក្តីព្រហ្មទណ្ឌ និង រឿងក្តីផ្សេងទៀត" ។[18] ប៉ុន្តែក្នុងករណីដែលចៅក្រមអាសនៈយល់ឃើញថា ចៅក្រមអយ្យការបានប្រព្រឹត្តកំហុសណាមួយ ចៅក្រមអាសនៈអាចលើកសំណើទៅនាយកឋានានុក្រមណាមួយនៃចៅក្រមអយ្យការ ដែលប្រព្រឹត្តកំហុសខុសឆ្គងនោះតែប៉ុណ្ណោះ ។

## ផ្នែកទី២៖ តំណាងអយ្យការ

តំណាងអយ្យការ គឺជាមន្ត្រីដែលបម្រើការនៅតាមស្ថាប័នអយ្យការនីមួយៗ ហើយតំណាងអយ្យការជាបុគ្គលមានតួនាទីសំខាន់បំផុតនៅក្នុងស្ថាប័នរបស់ខ្លួន ។ ដើម្បីឈានទៅដល់ការសិក្សាពីតំណាងអយ្យការ យើងត្រូវដឹងពី ការចូលបម្រើការជាតំណាងអយ្យការ (**កថាខណ្ឌទី១**) និង ការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈក្នុងនាមជាតំណាងអយ្យការ (**កថាខណ្ឌទី២**)។

### កថាខណ្ឌទី១៖ ការចូលបម្រើការជាតំណាងអយ្យការ

ដើម្បីឈានទៅដល់ការបម្រើការងារជាតំណាងអយ្យការបាន ព្រះរាជអាជ្ញាត្រូវធ្វើការចុះកម្មសិក្សា និង

---

[17] សូមមើលមាត្រា ៧៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ ។

[18] សូមមើលមាត្រា ៧៥ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ ។

ទទួលបានអត្ថប្រយោជន៍ពីការចុះកម្មសិក្សានោះ (១) និងបន្ទាប់មកទៀតទើបឈានទៅដល់ការតំឡើងថ្នាក់ និង ឋានន្តរស័ក្តិ (២) ។

### ១.ការចុះកម្មសិក្សា និង ទទួលបានអត្ថប្រយោជន៍ពីការចុះកម្មសិក្សា

បន្ទាប់ពីបានធ្វើការប្រលងប្រជែងជ្រើសរើស នឹងទទួលបានការបណ្តុះបណ្តាល វិជ្ជាជីវៈនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការរួចរាល់ហើយ " សិស្សព្រះរាជអាជ្ញាដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដោយជោគជ័យ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ជាព្រះរាជអាជ្ញាកម្មសិក្សាក្នុងឋានន្តរស័ក្តិ ជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ ។ ព្រះរាជអាជ្ញាកម្មសិក្សា ត្រូវធ្វើកម្មសិក្សារយៈពេលមួយឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេតនៃការតែងតាំង " ។[19]

"ការធ្វើកម្មសិក្សារបស់ព្រះរាជអាជ្ញាកម្មសិក្សា ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ការតែងតាំងជាព្រះរាជអាជ្ញាកម្មសិក្សា មានអានុភាពដល់ការរៀបចំប្រាក់បៀវត្ស និងការគិតអំពីអតីតភាពការងារ " ។[20]

ចំណែកឯអត្ថប្រយោជន៍ដែលទទួលបានពីការចុះកម្មសិក្សាវិញនោះគឺ បន្ទាប់ពីព្រះរាជអាជ្ញាកម្មសិក្សាបានបំពេញកម្មសិក្សាចប់ដោយជោគជ័យហើយនោះ ព្រះរាជអាជ្ញាកម្មសិក្សាត្រូវបានតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា នឹង មានឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ ។[21] ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញានេះ តាមសំណើររដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ប៉ុន្តែចំពោះព្រះរាជអាជ្ញាកម្មសិក្សា ដែលធ្វើកម្មសិក្សាពុំបានជោគជ័យ ឬដោយមានការអាក់ខានមិនបានធ្វើកម្មសិក្សាសរុបទាំងអស់លើសពី ៣០ ថ្ងៃ នោះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចសម្រេចឲ្យព្រះរាជអាជ្ញាកម្មសិក្សាបន្តធ្វើកម្មសិក្សាក្នុងរយៈពេល ១ ឆ្នាំបន្ថែមទៀត ។

ម្យ៉ាងវិញទៀត " ប្រសិនបើព្រះរាជអាជ្ញាកម្មសិក្សាឈប់ដោយគ្មានការអនុញ្ញាតច្បាប់លើសពី ៣០ ថ្ងៃ ឬមិនបានទទួលជោគជ័យជាថ្មីម្តងទៀត ក្នុងការធ្វើកម្មសិក្សាបន្ថែមត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា "[22] ដោយអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ៨៩ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ។[23]

---

[19] សូមមើលមាត្រា ៨៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

[20] សូមមើលមាត្រា ៨៣ កថាខណ្ឌទី ២ នឹងទី ៣ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

[21] សូមមើលមាត្រា ៨៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

[22] សូមមើលមាត្រា ៨៤ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

អនុលោមតាមបញ្ញត្តិនៃមាត្រា ៨៥ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា បានចែងថា " ព្រះរាជអាជ្ញាកម្មសិក្សាដែលពុំមានសម្បទាគ្រប់គ្រាន់ ឬសុខភាពមិនគ្រប់គ្រាន់ដើម្បីបំពេញមុខងាររបស់ខ្លួនតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ឬមានការខុសឆ្គងក្នុងការបម្រើការងារដោយមិនមានភាពពេញលេញ នោះអាចនឹងត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញាបានគ្រប់ពេលវេលា ។[24] " ការលុបឈ្មោះចេញ ឬការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ត្រូវធ្វើឡើងក្នុងរយៈពេល ៣ ខែ យ៉ាងយូរ ក្រោយពីបញ្ចប់កម្មសិក្សា " ។[25]

**២.ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ**

បន្ទាប់ពីព្រះរាជអាជ្ញា ធ្វើការចុះកម្មសិក្សាតាមរយៈពេលដែលត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ " ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវធ្វើឡើងតាមវេនជ្រើសរើស និងតាមវេនអតីតភាព ស្របតាមតារាងនៃថ្នាក់ និងឋានន្តរស័ក្តិនីមួយៗ ។ លក្ខខណ្ឌនៃការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិតាមវេនជ្រើសរើស និងតាមអតីតភាពត្រូវបានកំណត់ដោយព្រះរាជក្រឹត្យ " ។[26] ដើម្បីអាចចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់បាន ចៅក្រម ឬព្រះរាជអាជ្ញាត្រូវបំពេញកាតព្វកិច្ចចំនួន ២ គឺ ទី១ គាត់ត្រូវបម្រើការងារក្រោយទទួលបានការតាំងស៊ប់ក្នុងក្របខណ្ឌ នឹងទី ២ គាត់ត្រូវស្ថិតក្នុងឋានន្តរស័ក្តិ ឬថ្នាក់របស់ខ្លួនយ៉ាងតិចពីរឆ្នាំ គិតទល់ថ្ងៃទី ១៣ ខែ មេសា នៃឆ្នាំនីមួយៗ ។

ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់ចៅក្រមត្រូវផ្អែកលើមូលដ្ឋាន ជាអាទិ៍ ៖

- ការគោរពវិន័យការងារបានត្រឹមត្រូវ
- ការសម្រេចភារកិច្ចបានល្អ
- កិរិយាមាយាទ និងសីលធម៌ល្អមិនប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម
- ឆ្លងកាត់វគ្គបណ្តុះបណ្តាលនានា ឬបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា។[27]

---

[23] សូមមើលមាត្រា ៨៩ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, នស / រកម / ០៧១៤/ ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០១៤ បានចែងថា "ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រពីការតែងតាំង ការផ្លាស់ប្តូរការផ្តាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញាទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានពិគ្រោះយោបល់ជាចាំបាច់ចំពោះសំណើរខាង លើ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ អំពីកិច្ចការខាងលើនេះ " ។

[24] សូមមើលមាត្រា ៨៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

[25] សូមមើលមាត្រា ៨៥ កថាខណ្ឌទី2 នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

[26] សូមមើលមាត្រា២៧ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, នស/ រកម/០៧១៤ /០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ ។

[27] សូមមើលមាត្រា២៨ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, នស/រកម /០៧១៤/០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០១៤ ។

គណៈកម្មការដោះឡើងថ្នាក់ និងឋានន្តរស័ក្តិត្រូវរៀបចំតារាងទៅតាមជំនាន់ព្រះរាជអាជ្ញាដែលដំឡើងថ្នាក់ និងឋានន្តរស័ក្តិ និងតាមលំដាប់ថ្នាក់ក្នុងតារាងចុះឈ្មោះ ដើម្បីដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យ នឹងផ្តល់ យោបល់ ។ អង្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវរៀបចំតារាងចុះឈ្មោះព្រះរាជអាជ្ញាដែលត្រូវដោះឡើងថ្នាក់ និងឋានន្តរស័ក្តិទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ ។[28]

## កថាខណ្ឌទី២៖ ការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈក្នុងនាមជាតំណាងអយ្យការ

ក្នុងនាមជាតំណាងអយ្យការ " ព្រះរាជអាជ្ញា ត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឲ្យ និងគោរពឲ្យបានម៉ឺងម៉ាត់នូវក្រមសីលធម៌របស់ខ្លួន " ។[29] មានន័យថា ព្រះរាជអាជ្ញា ត្រូវតែអនុវត្តកិច្ចការទាំងឡាយដែលខ្លួនត្រូវបំពេញ ដោយមានទំនួលខុសត្រូវខ្ពស់ចំពោះកិច្ចការទាំងនោះ។ ដើម្បីសិក្សាពីការទទួលខុសត្រូវរបស់តំណាងអយ្យការ យើងត្រូវសិក្សាស្វែងយល់បន្ថែមថាតើព្រះរាជអាជ្ញាត្រូវបំពេញកាតព្វកិច្ចអ្វីខ្លះ (១) នឹងជាពិសេស ត្រូវទទួលទណ្ឌកម្មផ្នែកវិន័យអ្វីខ្លះនៅពេលដែលបានប្រព្រឹត្តកំហុស ក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈរបស់ខ្លួន (**២**) ?

### ១. កាតព្វកិច្ចដែលត្រូវបំពេញ

ព្រះរាជអាជ្ញាត្រូវតែបំពេញតួនាទី ក៏ដូចជាភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវយ៉ាងម៉ឺងម៉ាត់ នឹងមានភាពឆាប់រហ័ស ដោយស្របទៅតាមច្បាប់កំណត់ និងដើម្បីការពារសេចក្តីថ្លៃថ្នូរបស់មនុស្ស ក៏ដូចជាការលើកកំពស់សិទ្ធិមនុស្ស ដោយរួមជាវិភាគទានក្នុងការធានាដល់កិច្ចដំណើរការនៃប្រព័ន្ធយុត្តិធម៌ឲ្យបានត្រឹមត្រូវ ។

ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវ ៖

- អនុវត្តតួនាទីរបស់ខ្លួនដោយមិនលំអៀង និងជៀសវាងរាល់ការរើសអើងភេទ វប្បធម៌ ជាតិសាសន៍ ឋានៈសង្គម នយោបាយ ឬការរើសអើងណាមួយឡើយ ។
- ការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះដោយមិនលំអៀង និងត្រូវមានការប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធទាំងអស់ ទោះជាស្ថានភាពនោះមានប្រយោជន៍ ឬចតប្រយោជន៍ដល់ជនសង្ស័យក៏ដោយ ។
- រក្សារឿងក្តីជាសម្ងាត់ លើកលែងតែក្នុងករណីត្រូវបំពេញភារកិច្ច ឬករណីដើម្បីស្វែងរកយុត្តិធម៌ ។

[28] សូមមើលមាត្រា ៨៨ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, នស/ រកម/០៧១៤/០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ ។

[29] សូមមើលមាត្រា ៥៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, នស/ រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ ។

– ពិនិត្យមើលពីទិដ្ឋភាពទូទៅ និងក្តីបារម្ភរបស់ជនរងគ្រោះ នៅពេលដែលមានការប៉ះពាល់ដល់ប្រយោជន៍របស់ពួកគេ និងបញ្ជាក់ប្រាប់ពីសិទ្ធិរបស់ជនរងគ្រោះដើម្បីឲ្យស្របតាម សេចក្តីប្រកាសស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានរបស់ជនរងគ្រោះនៅក្នុងរឿងព្រហ្មទណ្ឌ និងការរំលោភអំណាច។[30]

លើសពីនេះទៅទៀត ក្នុងនាមជាតំណាងអយ្យការ ព្រះរាជអាជ្ញាមានកាតព្វកិច្ចទាំងក្នុងជីវភាពរស់នៅប្រចាំថ្ងៃផងដែរ ដូចជាពួកគាត់ "មិនត្រូវប្រព្រឹត្តិអំពើណាមួយដែលនាំឲ្យអាប់ឱន កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងដល់កិត្យានុភាពនៃអង្គអយ្យការឡើយ" ។[31] បន្ថែមពីនេះទៅទៀត ព្រះរាជអាជ្ញាដែលកំពុងតែបំពេញមុខងារ នៅតាមអយ្យការសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដែលមានបំណងនូវអត្ថបទ ឬការសរសេរសំណៅឯកសារ ក៏ដូចជាមតិផ្សេងៗដែលអាចប៉ះពាល់ដល់កិត្យានុភាពនៃស្ថាប័នអយ្យការ ឬស្ថាប័នតុលាការ នោះត្រូវតែសុំការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមុនសិន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវបានអនុវត្តឡើយ ចំពោះការធ្វើសេចក្តីថ្លែងការជាសាធារណៈរបស់ព្រះរាជអាជ្ញា ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។[32] ក្នុងករណីនេះដែលព្រះរាជអាជ្ញាត្រូវប្រកាន់ដាច់ខាតនូវឥរិយាបទអព្យាក្រឹត្យក្នុងវិស័យនយោបាយ ។

ព្រះរាជអាជ្ញាទាំងអស់ មិនត្រូវបោះបង់ការងាររបស់ខ្លួន ឬអវត្តមានដោយគ្មានការអនុញ្ញាតពីថ្នាក់លើផ្ទាល់របស់ខ្លួនជាមុនឡើយ ។ ព្រះរាជអាជ្ញាអមសាលាដំបូង អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងអង្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវធ្វើសំណើសុំអនុញ្ញាតអវត្តមានជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីធ្វើការសម្រេចអំពីការស្នើសុំនេះ ។

ក្រៅពីនេះក្នុងវិជ្ជាជីវៈព្រះរាជអាជ្ញា មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈដូចជា មុខងារជាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយបោះឆ្នោតដទៃទៀត ឬមុខងារជាទីប្រឹក្សាគ្រប់ឋានានុក្រមជាដើម ។ បន្ថែមពីលើសនេះ ព្រះរាជអាជ្ញា មិនអាចបំពេញមុខងារជាមេធាវី មុខរបរពាណិជ្ជកម្ម ឬធ្វើសកម្មភាពណាមួយផ្សេងទៀត ដែលនាំឲ្យមានទំនាស់ផលប្រយោជន៍ ឬប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម ។ ចំពោះព្រះរាជអាជ្ញាដែលត្រូវបានអនុញ្ញាតឲ្យនៅទំនេរ

---

[30] សូមមើល គោលការណ៍ណែនាំស្តីពី តួនាទីរបស់ព្រះរាជអាជ្ញា, អនុម័តដោយ សមាជអង្គការសហប្រជាជាតិលើកទី៨ ស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា នៃប្រទេសគុយបា, នៅថ្ងៃទី ២៨ ខែ សីហា ដល់ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ១៩៩០, ចំណុចទី១៣ ។

[31] សូមមើលមាត្រា ៩៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

[32] សូមមើលមាត្រា ៩៦ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

ហើយមានបំណងចង់ប្រកបការងារឯកជន នោះត្រូវធ្វើការជូនដំណឹងទៅដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីធ្វើការថ្លឹងថ្លែងថាគួរអនុញ្ញាតឲ្យ ឬយ៉ាងណា ក្នុងករណីនេះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើការជំទាស់ទៅនឹងការមិនឲ្យប្រកបការងារបាន ឬធ្វើសេចក្តីទៀងត្រង់ ឬធ្វើឲ្យខូចកិត្យានុភាពនៃមុខងារព្រះរាជអាជ្ញា ។ ក្នុងករណីដែលមានការបំពាននូវកាតព្វកិច្ចវិជ្ជាជីវៈណាមួយ ព្រះរាជអាជ្ញានឹងត្រូវទទួលទណ្ឌកម្ម វិន័យដែលសម្រេចដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

**២. ទណ្ឌកម្មផ្នែកវិន័យ**

យោងតាមច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៅពេលដែលព្រះរាជអាជ្ញាបានប្រព្រឹត្តអំពើដែលផ្ទុយពីកាតព្វកិច្ចវិជ្ជាជីវៈ ព្រះរាជអាជ្ញាត្រូវតែទទួលទណ្ឌកម្មផ្នែកវិន័យដូចនឹងចៅក្រមដែរ ។[33] យោងតាមមាត្រា ៥៤ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា បានបញ្ញត្តិថា "កំហុសរបស់ចៅក្រមក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ នឹងការធ្វើឲ្យប៉ះពាល់ដល់កិត្តិយសសីលធម៌ស្អាតស្អំ និងសេចក្តីថ្លៃថ្នូរប្រាសចាកពីក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា នាំឲ្យមានទណ្ឌកម្មខាងវិន័យតាមបទបញ្ញត្តិនៃច្បាប់នេះ ។ ប៉ុន្តែការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ចៅក្រម និង ព្រះរាជអាជ្ញាក្នុងការអនុវត្តច្បាប់មិនត្រូវចាត់ទុកថាជាកំហុសខាងវិន័យឡើយ " ។[34]

យោងតាមច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា បានកំណត់ថា " ទណ្ឌកម្មវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើបទល្មើសណាមួយត្រូវបានប្រព្រឹត្ត "[35] ក្នុងន័យនេះ ប្រសិនបើអំពើដែលព្រះរាជអាជ្ញាបានប្រព្រឹត្តិនោះ គឺជាបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌហើយក៏ជាអំពើដែលផ្ទុយប្រាកចាសនឹងកាតព្វកិច្ចវិជ្ជាជីវៈ នោះឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចធ្វើការដាក់ទណ្ឌកម្មវិន័យទៅលើព្រះរាជអាជ្ញានោះបាន ប៉ុន្តែការដាក់ទណ្ឌកម្មវិន័យនេះមិនបានធ្វើឲ្យបណ្តឹងអាជ្ញារលត់ឡើយ គឺព្រះរាជអាជ្ញានៅតែត្រូវទទួលទណ្ឌកម្មផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តិ ។ ចំពោះការទទួលទណ្ឌកម្មវិន័យវិញព្រះរាជអាជ្ញាអាចត្រូវបានផ្អាកពីមុខងារជាបណ្តោះអាសន្ន ដោយប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពេលដំណើរការនីតិវិធីវិន័យបានចាប់ផ្តើម ។

---

[33] សូមមើលមាត្រា ៥៩ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ ។

[34] សូមមើលមាត្រា ៥៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ ។

យោងតាមមាត្រា ៥៥ នៃច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា បានកំណត់អំពីទណ្ឌកម្មវិន័យ ដែលត្រូវបានបែងចែកជា ២ (ពីរ) ថ្នាក់ គឺះ

- **ទណ្ឌកម្មថ្នាក់ទី១**
  - ការស្តីបន្ទោសដោយផ្ទាល់មាត់
  - ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន
  - ការផ្អាកមិនឲ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈ តែមិនត្រូវឲ្យលើសពី ២ ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញក្នុងករណីដែលមានចុះឈ្មោះរួចហើយ។
- **ទណ្ឌកម្មថ្នាក់ទី២**
  - ការផ្លាស់ប្តូរដោយបង្ខំ អាចតម្រូវឲ្យទទួលការបណ្តុះបណ្តាលបន្ថែម
  - ការព្យួរពីការងារមិនឲ្យមានបៀវត្សរ ក្នុងរយៈពេលមិនឲ្យលើសពី ១ឆ្នាំ
  - ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ
  - ការដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំដោយបង្ខំ
  - ការបណ្តេញចេញពីក្របខណ្ឌ ។

ចំពោះទណ្ឌកម្មទី២ នេះត្រូវធ្វើឡើងព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

[35] សូមមើលមាត្រា ៥៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, នស / រកម / ០៧១៤ / ០១៦, ប្រកាសឲ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ ។

# ជំពូកទី២
# តួនាទីរបស់អង្គការអយ្យការ

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា « មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា »[36] និងយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌក៏បានកំណត់បន្ថែមទៀតថា « បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ » ។[37] ព្រះរាជអាជ្ញា គឺជាម្ចាស់នៃបណ្តឹងអាជ្ញាដែលជាភាគីតំណាងឲ្យផលប្រយោជន៍ទូទៅនៅក្នុងរឿងក្តីព្រហ្មទណ្ឌចំពោះមុខតុលាការ។

គោលការណ៍នេះត្រូវបានកំណត់ក្នុងគោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា ដោយបានកំណត់ថា « ព្រះរាជអាជ្ញាត្រូវដើរតួយ៉ាងសកម្មក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ដោយតំណាងឲ្យផលប្រយោជន៍សាធារណៈ » ។[38] ដើម្បីជាការធានាអាចដល់ការអនុវត្តគោលការណ៍នេះ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់នូវតួនាទីរួមរបស់អង្គការអយ្យការយ៉ាងច្បាស់លាស់ថា ៖

« អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និង សន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់ ។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌព្រម ទាំងយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន ។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួនចៅក្រមអយ្យការ មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ ។ ចៅក្រមអង្គការអយ្យការត្រូវមានវត្តមាននៅក្នុងពេលសវនការរឿងព្រហ្មទណ្ឌ »។[39]

យោងតាមមាត្រាខាងលើ យើងអាចធ្វើការបំបែកតួនាទីរួមរបស់តំណាងអង្គការអយ្យការទាំងឡាយដូចតទៅ ៖[40]

- ជាអ្នកទទួលបណ្តឹងពីគ្រប់មជ្ឈដ្ឋាន និងធ្វើការថ្លឹងថ្លែង តើគាត់គួរធ្វើការចោទប្រកាន់ ឬ អត់ ?[41]
- ជាអ្នកធ្វើការដឹកនាំ និង សម្របសម្រួលនគរបាលយុត្តិធម៌ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ។[42]

---

[36] សូមមើល មាត្រា ១៣១ នៃរដ្ឋធម្មនុញ្ញ, ប្រកាសឲ្យប្រើនាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ។

[37] សូមមើល មាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[38] សូមមើល ចំណុចទី១១ នៃគោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា, អនុម័តដោយសាមជអង្គការសហប្រជាជាតិលើកទីប្រាំបី ស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាថ្ងៃទី ២៧ ខែ សីហា ដល់ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០ ។

[39] សូមមើល មាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[40] សូមមើល ទូរទស្សន៍ជាតិកម្ពុជា(ទទក), កម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ, ឆ្នាំ ២០០៨ ។

[41] សូមមើល មាត្រា ៤០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[42] សូមមើល មាត្រា ៥៨ កថាខណ្ឌទី២ និងទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

– ជាអ្នកចោទប្រកាន់បទល្មើស និងស្នើសុំឲ្យយុត្តាធិការ[43] ស៊ើបសួរ និងយុត្តាធិការជំនុំជម្រះអនុវត្តច្បាប់។[44]

– ជាអ្នកអនុវត្តទោសនូវសេចក្តីសម្រេច ឬសាលក្រមស្ថាពរ ។[45]

បន្ទាប់មកទៀត យើងត្រូវសិក្សាបន្ថែមពីមុខការនៃអយ្យការ (**ផ្នែកទី១**) ដែលជាតួនាទីផ្សេងពីគ្នារបស់អយ្យការដែលនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងសិក្សាអំពីការអនុវត្តបណ្តឹងអាជ្ញាដោយតំណាងអយ្យការ (**ផ្នែកទី២**)។

## ផ្នែកទី១៖ មុខការនៃអង្គការអយ្យការ

នៅក្នុងមុខការនៃអង្គការអយ្យការ គឺយើងនិងត្រូវសិក្សាអំពីមុខការនៃអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត(**កថាខណ្ឌទី១**) និងសិក្សាអំពីមុខការនៃអង្គការមហាអយ្យការអមតុលាការជាន់ខ្ពស់(**កថាខណ្ឌទី២**)។

### កថាខណ្ឌទី១៖ អង្គការអយ្យការអមសាលាដំបូងរាជធានីខេត្ត

#### ១.អំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត

នៅអង្គការអយ្យការអមសាលាដំបូង មានតែព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងទេដែលជាតំណាងស្ថាប័ន អយ្យការ ។ ដូចដែរបានបញ្ជាក់ពីខាងលើមក ព្រះរាជអាជ្ញា គឺជានាយឋានានុក្រមនៃព្រះរាជអាជ្ញារងក្នុងដែលសមត្ថកិច្ចរបស់ខ្លួន ។ « ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និង ការចោទប្រកាន់បទល្មើស »។[46]

អង្គការអយ្យការ គឺអយ្យការអមសាលាដំបូងគឺជាអ្នកដែលបើកការស៊ើបអង្កេតជាបឋម ឬដំបូងទៅលើរឿងក្តីព្រហ្មទណ្ឌដែលខ្លួនទទួលបាន ។ ចំពោះការស៊ើបអង្កេត ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានទទួលស្គាល់ដើម្បីដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់នគរបាលយុត្តិធម៌ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ។ ពេលព្រះរាជអាជ្ញាចុះទៅកាន់កន្លែងស៊ើបអង្កេត និងអាចធ្វើការណែនាំដែលមានប្រយោជន៍ដល់នគរបាលយុត្តិធម៌ ។ ក្នុងករណីចាំបាច់ គាត់ក៏អាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីដែលកំពុងស៊ើបអង្កេត ដែលមានមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារសាធារណៈ ដែលស្ថិតនៅក្រោមអំណាចរបស់

[43] "យុត្តាធិការ (Jurisdiction) គឺជាតុលាការ ឬស្ថាប័នទទួលបន្ទុកចាត់ការរឿងក្តី", សូមមើល ទំព័រទី៦២, នៃសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ, រៀបចំដោយ គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, បោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី, បោះពុម្ពលើកទី១ ឆ្នាំ ២០១១ ។

[44] សូមមើល មាត្រា ៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[45] សូមមើល មាត្រា ៤៩៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[46] សូមមើល មាត្រា ៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

ព្រះរាជអាជ្ញា និងរៀបចំជំនួសវិញដោយមន្ត្រីមានសិទ្ធិស៊ើបអង្កេតដទៃទៀតក៏បាន ។

**២.សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា**

សមត្ថកិច្ចដែនដី គឺជាភារកិច្ច ឬអំណាចស្របច្បាប់ដែលគ្រប់គ្រងរដ្ឋ រដ្ឋបាល និងបច្ចេកទេស ។ ភារកិច្ច ឬអំណាចស្របច្បាប់ដែលអាជ្ញាធរតុលាការមានសម្រាប់ចាត់ការបទល្មើស ។[47]

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពី «ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ច »គឺ ៖[48]

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តិបទល្មើស ។

**ដូចជា៖** បទល្មើសត្រូវបានប្រព្រឹត្តនៅខេត្តត្បូងឃ្មុំ ដូចនេះជាសមត្ថកិច្ចរបស់អយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ។

- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស ។

**ដូចជា៖** ជនល្មើសបានប្រព្រឹត្តបទលួចម៉ូតូនៅរាជធានីភ្នំពេញតែគេដឹងថាជនល្មើសមានទីលំនៅក្នុងខេត្តកំពុងចាម ដូចនេះជនរងគ្រោះអាចដាក់បណ្តឹងនៅអយ្យការសាលាដំបូងខេត្តកំពង់ចាមបាន ក្នុងករណីនេះអយ្យការអមសាលាដំបូងខេត្តកំពង់ចាមក៏ជាអ្នកមានសមត្ថកិច្ចដែរ ។

- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើស ។

**ដូចជា៖** ជនល្មើសបានប្រព្រឹត្តបទកំហែងយក(ប្លន់)នៅរាជធានីភ្នំពេញ ។ ប៉ុន្តែជនល្មើសត្រូវបានចាប់ខ្លួននៅខេត្តបាត់ដំបង ដូចនេះអយ្យការអមសាលាដំបូងខេត្តបាត់ដំបងក៏មានសមត្ថកិច្ចដូចគ្នាដែរ ។ ក្នុងករណីនេះអយ្យការទាំងពីរគួរសម្របសម្រួលគ្នា ហើយសមត្ថកិច្ចគួរត្រូវបានប្រគល់ជូនអយ្យការអមសាលាដំបូងខេត្តបាត់ដំបងព្រោះដើម្បីជាការសម្រួលដល់នីតិវិធីរឿងក្តី។

**កថាខណ្ឌទី២៖ អង្គការមហាអយ្យការអមតុលាការជាន់ខ្ពស់**

**១.មហាអយ្យការអមសាលាឧទ្ធរណ៍**

ដូចដែលបានលើកឡើងពីខាងដើមមកគឺ នៅក្នុងមហាអយ្យការអមសាលាឧទ្ធរណ៍មានមហាអយ្យការគឺមានសមាសភាពអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមសាលាក្នុងស្ថាប័ននោះ ។

[47] សូមមើល ទំព័រ ១៩២ និង ៤៦៧, ភូឡាយស៊ុន និង ភូ វួចចេង "វចនានុក្រមច្បាប់ខ្មែរ-អង់គ្លេស", ត្រួតពិនិត្យ និង អធិប្បាយពាក្យច្បាប់ជាភាសាខ្មែរដោយ ហ៊ីង ធិឫទ្ធិ, ត្រួតពិនិត្យ និងផ្តល់យោបល់ដោយ លោក ភូ លីវុឌ្ឍ [...], បោះពុម្ពលើកទី១ ឆ្នាំ ២០១២ ។

[48] សូមមើល មាត្រា ៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់មកថា ៖

- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ ។
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិការកិច្ចនៅអង្គការអយ្យការទាំងឡាយដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។
- ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[49]

ដូចនេះមហាអយ្យការអមសាលាឧទ្ធរណ៍ មានតួនាទីដោយឡែក ដែលត្រូវដើរតួជាអ្នកឃ្លាំមើលទៅលើអយ្យការទាំងឡាយដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងអាចប្រើអំណាចតាមគោលការណ៍ឋានានុក្រមទៅតាមការយល់ឃើញរបស់ខ្លួន ។ ដើម្បីធានាដល់ការឃ្លាំមើលរបស់ខ្លួនអគ្គព្រះរាជអាជ្ញាមានសិទ្ធិក្នុងការធ្វើអធិការកិច្ចទៅតាមអយ្យការរាជធានី-ខេត្ត និងក្នុងករណីគាត់ពិនិត្យឃើញថាមានបទល្មើសធ្ងន់ធ្ងរប៉ះពាល់ដល់សន្តិសុខជាតិ ដែលមិនមែនជាវិវាទរវាងបុគ្គលនិងបុគ្គល គាត់ត្រូវរាយការណ៍ជូនដល់រដ្ឋមន្ត្រីក្រសួនយុត្តិធម៌ដែលជានាយឋានានុក្រមរបស់ខ្លួន ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរបាលយុត្តិធម៌ដើម្បីពិភាក្សាអំពីបញ្ហាដែលទាក់ទងនឹងការប្រព្រឹត្តទៅរបស់អង្គភាពនគរបាលទាំងនេះ និងអាចប្រគល់ភារកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ឲ្យបំពេញកិច្ចទាំងឡាយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការគ្រប់គ្រង ឬដំណើរការដ៏នៃនគរបាលយុត្តិធម៌ ។ អគ្គព្រះរាជអាជ្ញានេះអាចធ្វើអធិការកិច្ចគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ និងចូលរួមស្តាប់ចម្លើយ ឬត្រួតពិនិត្យការគោរពតាមទម្រង់ច្បាប់នៃការឃាត់ខ្លួនរបស់នគរបាលយុត្តិធម៌ ឬការគ្រប់គ្រងកន្លែងឃាត់ខ្លួន ។

គួរកត់សម្គាល់ដែរថា ក្នុងករណីមានការយល់ឃើញពីសភាពធ្ងន់ធ្ងរនៃកំហុសដែលប្រព្រឹត្តដោយមន្ត្រីនគរបាលណាម្នាក់ដែលមានវិសមិតភាពជាមួយនឹងការបំពេញមុខងារ នោះអគ្គព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិក្នុងការចាត់វិធានការ ហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្តោះអាសន្នក្នុងរយៈពេល ៥ ឆ្នាំ ឬហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ ។[50] ប៉ុន្តែមុននឹងចេញជាចេញ

[49] សូមមើល មាត្រា ៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[50] សូមមើល មាត្រា ៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

ជាសេចក្តីសម្រេចនេះ អគ្គព្រះរាជអាជ្ញាត្រូវកោះហៅដោយធ្វើការកត់ត្រានូវសេចក្តីអង្កេតនៃមន្រ្តីនគរបាលយុត្តិធម៌នោះ ហើយមន្រ្តីនគរបាលយុត្តិធម៌នោះអាចរកជំនួយពីមេធាវី ឬ អ្នកប្រឹក្សាច្បាប់ណាម្នាក់ទៅតាមការជ្រើសរើសរបស់ខ្លួន និង ត្រូវមានបញ្ជាក់សំអាងហេតុដែលនាំឲ្យមានការហាមឃាត់មិនឲ្យបំពេញមុខងារផង ហើយសេចក្តីសម្រេចនេះត្រូវជូនជាដំណឹងទៅរដ្ឋមន្រ្តីក្រសួងមហាផ្ទៃ ឬរដ្ឋមន្រ្តីក្រសួងការពារជាតិ ដែលជាក្រសួងសាមីនៃនគរបាលយុត្តិធម៌នោះ ។[51]

ក្នុងករណីមន្រ្តីនគរបាលយុត្តិធម៌ មិនសុខចិត្តនឹងសេចក្តីសម្រេចហាមឃាត់មិនឲ្យបំពេញមុខងារ មន្រ្តីនគរបាលយុត្តិធម៌នោះអាចប្តឹងតវ៉ាដោយមានសំអាងហេតុទៅកាន់រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ ក្នុងអំឡុងពេល ១៥ ថ្ងៃគិតចាប់ពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចហាមឃាត់នោះ ។[52] ដូចនេះ សេចក្តីសម្រេចនោះ គឺជាកម្មវត្ថុនៃបណ្តឹងតវ៉ាទៅកាន់រដ្ឋមន្រ្តីកក្រសួងយុត្តិធម៌ ដើម្បីអាចទទួលបានការប្រកាសបដិសេធចោលការសម្រេចហាមឃាត់មិនឲ្យបំពេញមុខងារ ឬកាត់បន្ថយរយៈពេលហាមឃាត់។[53] ក្នុងករណីនេះ រដ្ឋមន្រ្តីក្រសួងយុត្តិធម៌អាចត្រឹមតែបន្ថយទោសវិន័យ តែមិនអាចបន្ថែមទោសវិន័យបានឡើយ ព្រោះកម្មវត្ថុនៃបណ្តឹងតវ៉ាមិនមែនប្តឹងសុំឲ្យមានការបន្ថែមទោសនោះឡើយ គឺប្តឹងសុំឲ្យមានការកាត់បន្ថយទោស ឬបដិសេធចោលសេចក្តីសម្រេចក្តីសម្រេចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តែម្តង ។ រដ្ឋមន្រ្តីក្រសួងយុត្តិធម៌នឹងសម្រេចបណ្តឹងតវ៉ាខាងលើយ៉ាងយូរបំផុតក្នុងរយៈពេល ១ ខែ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹង ហើយសេចក្តីសម្រេចរបស់រដ្ឋមន្រ្តីក្រសួងយុត្តិធម៌គឺជាសេចក្តីបិទផ្លូវតវ៉ា ។[54] ក្នុងអំឡុងពេលនៃការធ្វើបណ្តឹងតវ៉ា និងការសម្រេចបណ្តឹងតវ៉ានោះ មន្រ្តីនគរបាលយុត្តិធម៌ដែលត្រូវបានហាមឃាត់នោះ មិនអាចបំពេញមុខងាររបស់ខ្លួនបានឡើយ ហើយកិច្ចទាំងឡាយដែលមន្រ្តីនគរបាលយុត្តិធម៌នោះបានបំពេញត្រូវចាត់ទុកជាមោឃៈ ។[55]

### ២.មហាអយ្យការអមតុលាការកំពូល

មហាអយ្យការអមតុលាការកំពូល គឺជាស្ថាប័នមួយ ដែលមានអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និង ព្រះរាជអាជ្ញាដែលជាតំណាងអយ្យការនៅអមតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជាសមាសភាពមួយរូបក្នុងចំណោមសមាជិកទាំង ១១ រូបនៃសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[56] ដែលមានព្រះមហាក្សត្រ

[51] សូមមើល មាត្រា ៦៦ កថាខណ្ឌទី៣, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[52] សូមមើល មាត្រា ៦៦ កថាខណ្ឌទី៥, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[53] សូមមើល មាត្រា ៦៦ កថាខណ្ឌទី៤, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[54] សូមមើល មាត្រា ៦៦ កថាខណ្ឌទី៦, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[55] សូមមើល មាត្រា ៦៦ កថាខណ្ឌទី៨, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[56] សូមមើល មាត្រា ៤ នៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, នស/រកម/០៧១៤/០១៧, ប្រកាសឲ្យប្រើនាថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

ជាព្រះប្រធានហើយស្ថាប័ននេះមានតួនាទីចម្បងក្នុងការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ ការលុបឈ្មោះ និងការដាក់វិន័យទាំងចៅក្រមអាសនៈ និង ចៅក្រមអយ្យការទាំងអស់ ។[57]

ចំណែកនៅក្នុងតួនាទីជំនុំជម្រះវិញ អយ្យការអមតុលាការកំពូល ជាអ្នកចូលរួមស្នើសុំឲ្យមានការគោរពច្បាប់នៅក្នុងពេលដែលមានបណ្តឹងសាទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀត ដែលបានដាក់ជូនតុលាការកំពូល ពិនិត្យ ។[58]

## ផ្នែកទី២៖ ការអនុវត្តបណ្តឹងអាជ្ញាដោយតំណាងអយ្យការ

ជាទូទៅបណ្តឹងអាជ្ញាគឺជាបណ្តឹងព្រហ្មទណ្ឌដែលមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើសបង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើសនិងផ្តន្ទាទោសជនដែលបានប្រព្រឹត្តិបទល្មើសតាមកំណត់ច្បាប់ ។ បណ្តឹងអាជ្ញាត្រូវអនុវត្តលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ ។ ព្រះរាជអាជ្ញា គឺជាម្ចាស់នៃបណ្តឹងអាជ្ញា មានតែព្រះរាជអាជ្ញាទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។ ដើម្បីអាចចាប់ផ្តើមដំណើរការបណ្តឹងអាជ្ញាបាន ព្រះរាជអាជ្ញាត្រូវស៊ើបអង្កេតដើម្បីប្រមូលព័ត៌មាន និងភស្តុតាង[59] ដាក់បន្ទុកឲ្យមានលក្ខណៈគ្រប់គ្រាន់ និងអាចជឿជាក់បានថាបទល្មើសពិតជាត្រូវបានប្រព្រឹត្តពិតមែន ហើយជនដែលបានប្រព្រឹត្តបទល្មើស គឺជាជនល្មើសដែលព្រះរាជអាជ្ញាកំពុងសង្ស័យពិតមែន ។ ក្រោយពីការស៊ើបអង្កេត ព្រះរាជអាជ្ញាត្រូវធ្វើការសម្រេចថា តើគួរធ្វើការដាក់ឲ្យដំណើរការបណ្តឹងអាជ្ញា ឬ ធ្វើការតម្កល់រឿងទុកឥតចាត់ការ ?

អាស្រ័យហេតុនេះដើម្បីស្វែងយល់ឲ្យកាន់តែស៊ីជំម្រៅទៀតនោះ យើងគួរតែដឹងសិនថា បណ្តឹងអាជ្ញាជាអ្វី(**កថាខណ្ឌទី១**) និង យល់ដឹងបន្ថែមអំពីសេចក្តីសម្រេចនៃតំណាងអយ្យការក្នុងការចោទប្រកាន់ (**កថាខណ្ឌទី២**) ។

### កថាខណ្ឌទី១៖បណ្តឹងអាជ្ញា

នៅពេលមានបទល្មើសមួយកើតឡើង អាចមានបណ្តឹងពីរផ្សេងគ្នាតែងតែកើតឡើង គឺបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី ហើយបណ្តឹងទាំងពីប្រភេទនេះក្នុងនោះមានបណ្តឹងរដ្ឋប្បវេណីដែលជាបណ្តឹងធ្វើឡើងដើម្បី

---

[57] សូមមើល មាត្រា ១៨ និង ២០ នៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, នស/រកម/០៧១៤/០១៧, ប្រកាសឲ្យប្រើនាថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

[58] សូមមើល មាត្រា ៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[59] សូមមើល ទំព័រ ៣៨៨, ភូឡាយស៊ុន និង ភូ វួចចេង "វចនានុក្រមច្បាប់ខ្មែរ-អង្គគ្លេស", ត្រួតពិនិត្យ និង អធិប្បាយពាក្យច្បាប់ជាភាសាខ្មែរដោយ ហ៊ីង ធិឫទ្ធិ, ត្រួតពិនិត្យ និងផ្តល់យោលបល់ដោយ លោក ភូ លីវុឌ្ឍ [...], បោះពុម្ពលើកទី១ ឆ្នាំ ២០១២ ។

ដោះស្រាយនូវវិវាទរវាងបុគ្គលឯកជន និង បុគ្គលឯកជន ដោយតម្រូវឲ្យមានការសងជាសំណងព្យសនកម្មរីឯ បណ្តឹងមួយទៀតគឺបណ្តឹងអាជ្ញាដែលត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញាដែលជាអ្នកតំណាងឲ្យសង្គម ដើម្បីកំណត់ថា តើមានការប្រព្រឹត្តបទល្មើសទេ បើមានការប្រព្រឹត្តមែន ជនល្មើសត្រូវទទួលទោសពិន័យ ឬ ទោសដាក់ពន្ធធនាគារទៅតាមទោសបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ។

ចំពោះបណ្តឹងទាំងពីរនេះ ទោះជាមានបណ្តឹងណាមួយត្រូវរលត់ទៅតាមលក្ខខណ្ឌណាមួយរបស់វាក៏ដោយក៏បណ្តឹងមួយទៀតមិនរលត់នោះដែរ ។ មានន័យថា នៅក្នុងរឿងព្រហ្មទណ្ឌ ព្រះរាជអាជ្ញាគឺជាម្ចាស់នៃបណ្តឹងអាជ្ញា ក្នុងករណីជនបង្កបានសងជាសំណងព្យសនកម្មទៅជនរងគ្រោះផ្នែករដ្ឋប្បវេណីអស់ហើយក៏ដោយក៏ព្រះរាជអាជ្ញានៅតែអាចធ្វើការចោទប្រកាន់ ឬដាក់ឲ្យដំណើរការបណ្តឹងអាជ្ញាបានដែរ ព្រោះវាជា បណ្តឹងពីរផ្សេងគ្នា។ ឧទាហរណ៍៖ ករណីគ្រោះថ្នាក់ចរាចរណ៍មួយដែលបានបង្កឲ្យបុកមនុស្សស្លាប់ជាដើម ។ ជាទូទៅក្រុមគ្រួសារសព ឬជនរងគ្រោះតែងតែមានការសម្របសម្រួលពីជនបង្កហេតុ តាមរយៈការសងសំណងជំងឺផ្លូវចិត្តដើម្បីបញ្ចប់រឿង ដែលជាការដោះស្រាយក្រៅប្រព័ន្ធតុលាការ ដូចនេះបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានរលត់ ។ ប៉ុន្តែបណ្តឹងអាជ្ញាដែលជាបណ្តឹងការពារផលប្រយោជន៍ទូទៅ ផលប្រយោជន៍នៃសង្គមមិនអាចរលត់ឡើយព្រោះការបង្កហេតុនេះធ្វើឲ្យប៉ះពាល់ដល់ជីវិតមនុស្ស និងសណ្តាប់ធ្នាប់សង្គម ដូចនេះភាគីរងគ្រោះអាចប្តឹងដើម្បីទាមទារឲ្យមានការដាក់ទោសទណ្ឌបាន ។ ដោយក្នុងករណីនេះ ព្រះរាជអាជ្ញាជាអ្នកតំណាងឲ្យជនរងគ្រោះមានតួនាទីធ្វើបណ្តឹងអាជ្ញា ។

បន្តទៅទៀតនេះយើងនឹងធ្វើការសិក្សាទៅលើភាពខុសគ្នារវាង បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី (១) និងការរលត់បណ្តឹងអាជ្ញា (២) ។

### ១.ភាពខុសគ្នារវាងបណ្តឹងអាជ្ញា និង បណ្តឹងរដ្ឋប្បវេណី

បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងពីផ្សេងគ្នា។[60]

បណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់ ។ រីឯបណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឲ្យបានជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះឲ្យអ្នករងគ្រោះបានទទួលសំណងជំងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល ។[61] ដោយទៅតាមមាត្រានេះ យើងអាចធ្វើការបែងចែកនូវចំណុចខុសគ្នារវាងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីដែលមានដូចជា ៖

---

[60] សូមមើល មាត្រា ២ កថាខណ្ឌទី១, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[61] សូមមើល មាត្រា ២ កថាខណ្ឌទី២ និងទី៣, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

➢ **គោលបំណង**

- បណ្តឹងអាជ្ញា៖ ជួសជុលនូវព្យសនកម្ម ដែលកើតចេញពីបទល្មើស ដើម្បីប្រយោជន៍សម្រាប់សង្គម
- បណ្តឹងរដ្ឋប្បវេណី៖ ជួសជុលព្យសនកម្មពីការប្រព្រឹត្តបទល្មើស ដើម្បីជាផលប្រយោជន៍ដល់ជនរងគ្រោះ។

➢ **មូលដ្ឋានច្បាប់**

- បណ្តឹងអាជ្ញា៖ ផ្អែកលើច្បាប់ព្រហ្មទណ្ឌ ដោយយោងទៅតាមគោលការណ៍នីត្យានុកូលភាព ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ
- បណ្តឹងរដ្ឋប្បវេណី៖ ផ្អែកលើអំពើនីត្យានុកូល ដែលមានចែងក្នុងក្របរដ្ឋប្បវេណី។

– **ទណ្ឌកម្ម ៖**

- បណ្តឹងអាជ្ញា៖ ទោសពិន័យ និងទោសដាក់ពន្ធនាគារដោយយោងទៅតាមកំហុសនៃជនល្មើស
- បណ្តឹងរដ្ឋប្បវេណី៖ សងសំណងដោយយោងទៅតាមព្យសនកម្មដែលកើតលើជនរងគ្រោះ។

– **ភាគី ៖**

- បណ្តឹងអាជ្ញា៖ អយ្យការ និង ជនល្មើស
- បណ្តឹងរដ្ឋប្បវេណី៖ សិទ្ធិវ័ន្ត ឬ ជនរងគ្រោះផ្នែករដ្ឋប្បវេណី។

– **សាលាជម្រះក្តី ៖**

- បណ្តឹងអាជ្ញា៖ ធ្វើបានតែចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌតែប៉ុណ្ណោះ
- បណ្តឹងរដ្ឋប្បវេណី៖ ជនរងគ្រោះអាចធ្វើបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌក៏បាន ឬ សាលាជម្រះក្តីរដ្ឋប្បវេណីក៏បាន។[62]

**២. ការរលត់បណ្តឹងអាជ្ញា**

ការរលត់បណ្តឹងអាជ្ញា គឺជាមូលហេតុដែលធ្វើឲ្យព្រះរាជអាជ្ញាមិនអាចដាក់ឲ្យដំណើរការបណ្តឹងអាជ្ញា ឬ ត្រូវបញ្ឈប់ការអូដំណើរការបណ្តឹងអាជ្ញា។

[62] សូមមើល មាត្រា ២២, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៧ បានចែងថា " មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅ ៖

- មរណភាពនៃជនល្មើស
- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ
- ការនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ។"

➢ **មរណភាពនៃជនល្មើស ៖** ក្នុងករណីដែលជនល្មើសដែលទទួលមរណភាព មុនពេលមានបណ្តឹងអាជ្ញា ឬ ស្លាប់មុនពេលប្រកាសសេចក្តីសម្រេចស្ថាពរក្នុងការផ្តន្ទាទោសជនល្មើស នោះបណ្តឹងអាជ្ញាត្រូវរលត់។ មានន័យថាព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់ និង អនុវត្តទោសចំពោះមនុស្សដែលបានទទួលមរណភាពឡើយ ប៉ុន្តែករណីនេះដើមបណ្តឹងរដ្ឋប្បវេណីអាចសុំឲ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវន្តនៃជនជាប់ចោទបាន ហើយតុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ចលើបណ្តឹងរដ្ឋប្បវេណីនោះ។[63]

➢ **ការផុតអាជ្ញាយុកាល ៖** អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមាន ១៥ ឆ្នាំ ចំពោះបទឧក្រិដ្ឋ, ៥ ឆ្នាំ ចំពោះបទមជ្ឈិម និង ១ ឆ្នាំ ចំពោះបទលហុ ។ ចំណែក បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និង បទឧក្រិដ្ឋសង្គ្រាម មិនមានអាជ្ញាយុកាលឡើយ។ ដូចគ្នានេះដែរ ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីដែលជាអំពើនីត្យានុកូលគឺ(ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៣ឆ្នាំ បានកន្លងហួសបន្ទាប់ពីពេលដែលជនរងគ្រោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះ បានដឹងថា អាចទាមទារសំណងការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬ ប្រើអំឡុងពេល ១០ ឆ្នាំ បានកន្លងហួសបន្ទាប់ពី អំពើនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង)។[64] ដោយឈរលើគោលការណ៍បែងចែកបណ្តឹងទាំងពីរជាបណ្តឹងផ្សេងគ្នានោះការផុតអាជ្ញាយុកាលនៃបណ្តឹងណាមួយ មិនមែនជាឧបសគ្គសម្រាប់ការធ្វើបណ្តឹងមួយទៀតឡើយ ។

បទល្មើសមួយចំនួនដែលយើងអាចធ្វើការរាប់អាជ្ញាយុកាលបានដូចជា ៖[65]

➢ **បទល្មើសភ្លាមៗ**

បទល្មើសភ្លាមៗ គឺជាបទល្មើសដែលការប្រព្រឹត្តបានកើតឡើងភ្លាមៗមិនអូសបន្លាយ បានសេចក្តីថាបទល្មើស

---

[63] សូមមើល មាត្រា ២៤, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[64] សូមមើល មាត្រា ៧៦៥, នៃក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០, ប្រកាសឲ្យប្រើនាថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ។

[65] សូមមើល ទំព័រទី៤៧ និង ៤៨ នៃមេរៀននីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រាចារ្យ ហ៊ាង ឡេង ។

ដែលប្រតិបត្តិស្ថិតក្នុងរយៈពេលយ៉ាងខ្លីបំផុត ។ **ឧទាហរណ៍៖** បទឃាតកម្ម ( មាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ), បទហិង្សាដោយចេតនា ( មាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ), បទលួច ( មាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌ )។ អាជ្ញាយុកាល នៃបទល្មើសត្រូវគិតចាប់ពីថ្ងៃដែលបានប្រព្រឹត្តបទល្មើស។

➢ **បទល្មើសនិរន្តរ៍**

បទល្មើសនិរន្តរ៍ គឺជាបទល្មើសដែលអូសបន្លាយ ដោយសារតែគំនិតទុច្ចរិតរបស់ជនល្មើស ឬ អាចនិយាយបានម្យ៉ាងទៀតថា ជាបទល្មើសដែលសំដែងឡើងដោយអំពើនៃការប្រព្រឹត្តបទល្មើសអាចអូសអាចអូសបន្លាយក្នុងកាល ដោយស្ថិតនៅក្នុងអំឡុងពេលយូរ ឬ ឆាប់អាស្រ័យលើឆន្ទៈប្រព្រឹត្តបទល្មើសរបស់ចារី។ **ឧទាហរណ៍៖** បទប្រើប្រាស់ដោយខុសច្បាប់នូវសំលៀកបំពាក់ជាអាទិ៍សម្រាប់អាជ្ញាធរសាធារណៈ (មាត្រា៦១២ នៃក្រមព្រហ្មទណ្ឌ), បទផិត (មាត្រា៧ នៃច្បាប់ស្តីពីឯកពន្ធភាព) និង បទរក្សាទុកគ្រឿងផ្ទុះខុសច្បាប់ (មាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ) ។ អាជ្ញាយុកាលនៃបទល្មើសនិរន្តរ៍នេះ ត្រូវគិតចាប់ពីថ្ងៃដែលរកឃើញបទល្មើសនោះ។

➢ **បទល្មើសជាទម្លាប់ ឬដដែល**

បទល្មើសជាទម្លាប់ ឬ ដដែល គឺជាបទល្មើសមួយ ដែលសំដៅដល់ការប្រព្រឹត្តដដែលៗ នូវអំពើតែមួយដូចគ្នា ។ ដោយមានន័យថា អំពើទាំងនោះមានលក្ខណៈដូចគ្នាៗ ហើយត្រូវបានប្រព្រឹត្តឡើងម្តងហើយម្តងទៀតដោយដាច់ដោយឡែកពីគ្នា ។ **ឧទាហរណ៍៖** បទយល់ព្រមធ្វើសកម្មភាពពេស្យាចារនៅក្នុងគ្រឹះស្ថាន (មាត្រា២៩២ នៃក្រមព្រហ្មទណ្ឌ), បទគំរាមកំហែង (មាត្រា២៣១ នៃក្រមព្រហ្មទណ្ឌ) និង បទរុកកួនផ្លូវភេទ (មាត្រា២៥០ នៃក្រមព្រហ្មទណ្ឌ)។ សម្រាប់បទល្មើសជាទម្លាប់នេះ អាជ្ញាយុកាលរាប់ចាប់ពីថ្ងៃប្រព្រឹត្តបទល្មើសចុងក្រោយគេ ។

❖ **ការលើកលែងទោសទូទៅ** ៖ ការលើកលែងទោសទូទៅនេះ ត្រូវបានអនុវត្តទៅតាមច្បាប់ស្តីពីការលើកលែងទោស ដែលបានកំណត់នៅក្នុងមាត្រា៩០ នៃរដ្ឋធម្មនុញ្ញ ។ ការលើកលែងទោសទូទៅ អាចធ្វើការកំណត់ពីដែនអនុវត្តផ្សេងៗដូចជា ប្រភេទបទល្មើស រយៈពេលនៃទោស អាយុរបស់ទណ្ឌិត ជាដើម។

❖ **ការនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ** ៖ បណ្តឹងអាជ្ញាត្រូវរលត់ទៅតាមបទល្មើសមួយចំនួន ដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌចាស់ ដែលត្រូវបាននិរាករណ៍ដោយច្បាប់ព្រហ្មទណ្ឌថ្មី ។

❖ **អាជ្ញាអស់ជំនុំ៖** ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេ ចំពោះអំពើដដែល ទោះបីក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ ។[66] ដូចនេះផលវិបាក ក្រោយសេចក្តីសម្រេចស្ថាពរ ទោះជាមានលេច

ឡើងនូវភស្តុតាងថ្មី ដែលអាចបញ្ជាក់បានជាពិតជាមានបទល្មើសបានប្រព្រឹត្តមែនក៏ដោយក៏បណ្តឹងអាជ្ញាមិនអាចដាក់ឲ្យដំណើរការបានដែរ ព្រោះវាមានអាជ្ញាអស់ជំនុំ ។

ក្រៅពីមូលហេតុខាងលើនេះ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានកំណត់បន្ថែមអំពីមូលហេតុ ៣ ផ្សេងទៀត ដែលអាចធ្វើឲ្យបណ្តឹងអាជ្ញាយុកាលផុតរលត់បានដែរមានដូចជា ៖[67]

- **ការដកពាក្យបណ្តឹង** ៖ អាចធ្វើឲ្យបណ្តឹងអាជ្ញារលត់បាន ប្រសិនបើពាក្យប្តឹងដោយជនរងគ្រោះ គឺជាលក្ខខណ្ឌចាំបាច់មួយក្នុងការដាក់ឲ្យបណ្តឹងអាជ្ញាមានចលនា មានន័យថាក្នុងបទល្មើសមួយចំនួនព្រះរាជអាជ្ញាមិនអាចធ្វើបណ្តឹងអាជ្ញាឲ្យមានចលនា ដោយគ្មានពាក្យពាក្យប្តឹងរបស់ជនរងគ្រោះឡើយ ដូចជាបទបរិហាកេរ្តិ៍ និងបទជេរប្រមាថ ។[68] ក្នុងករណីនេះព្រះរាជអាជ្ញាត្រូវការពាក្យប្តឹងជូនរងគ្រោះដើម្បីធ្វើបណ្តឹងអាជ្ញា ហើយការដកពាក្យប្តឹងរបស់ជនរងគ្រោះក៏អាចធ្វើឲ្យបណ្តឹងអាជ្ញាផុតរលត់ផងដែរព្រោះជនរងគ្រោះគឺជាអ្នកដែលទទួលរងគ្រោះខ្លាំងបំផុតក្នុងនាក់ទំនងបទល្មើសនេះ ទើបច្បាប់ព្រហ្មទណ្ឌបានកំណត់សិទ្ធិអំណាចឲ្យជនរងគ្រោះជាអ្នកសម្រេចពីការធ្វើបណ្តឹងអាជ្ញានេះ ។
- **ការសម្របសម្រួលជាមួយរដ្ឋ** ៖ ក៏ជាមូលហេតុអាចធ្វើឲ្យបណ្តឹងផុតរលត់បានដែរ តាមរយៈការបង់ពិន័យអន្តរកាលេជូនរដ្ឋ ។ **ឧទាហរណ៍** ៖ ពិន័យពេលបំពានវិធានចរាចរណ៍ផ្លូវគោក ។
- **ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល** ៖ អាចធ្វើឲ្យបណ្តឹងអាជ្ញាផុតរលត់បានលុះត្រាតែមានការទទួលស្គាល់ជាមុនដោយជនសង្ស័យ អំពីការចូលរួមប្រព្រឹត្តបទល្មើសរបស់ខ្លួន ហើយត្រូវមានការព្រមព្រៀងធ្វើឲ្យរលត់បណ្តឹងអាជ្ញា ។[69]

### កថាខណ្ឌទី២៖ សេចក្តីសម្រេចនៃតំណាងអយ្យការក្នុងការចោទប្រកាន់

នៅក្នុងសំណុំរឿងព្រហ្មទណ្ឌនោះ តំណាងអយ្យការមានសិទ្ធិក្នុងការមិនចោទប្រកាន់ ឬ ចោទប្រកាន់ដែលក្នុងនោះសិក្សាអំពី ការតម្កល់រឿងទុក្ខតតចាត់ការ (១) ជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការ (២) ។

[66] សូមមើល មាត្រា ១២, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[67] សូមមើល មាត្រា ៨, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[68] សូមមើល មាត្រា ៣០៩, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[69] សូមមើល សហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ និងរាជបណ្ឌិតវិជ្ជាជីវៈតុលាការ, មេរៀននីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, ទំព័រទី ៣៤ ។

### ១. ការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុក្ខឥតចាត់ការ គឺជានីតិវិធីមួយដែលកើតចេញពីគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ដែលគោលការណ៍នេះបានផ្តល់នូវអំណាចសម្រាប់ព្រះរាជអាជ្ញាអាចធ្វើការថ្លឹងថ្លែងក្នុងនាមជានិយ័តករនៃសង្គម ដើម្បីធ្វើការតម្កល់រឿងទុកឥតចាត់ការ ឬដាក់ឲ្យដំណើរការបណ្តឹងអាជ្ញា ។ យើងគួររំលឹកផងដែលថា ប្រទេសកម្ពុជាជាប្រទេសធ្លាប់អនុវត្តនូវគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់នាសម័យអន្តរកាល តាមរយៈគោលការណ៍នេះតម្រូវឲ្យតំណាងអយ្យការត្រូវចោទប្រកាន់គ្រប់រឿងក្តីព្រហ្មទណ្ឌ ។ គោលការណ៍ទាំងពីរនេះមាន លក្ខណៈមិនដូចគ្នានោះទេ ។ យោងតាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ តើតំណាងអយ្យការអាចធ្វើការតម្កល់រឿងទុក្ខឥតចាត់ការបានតាមរយៈអ្វីខ្លះ ?

ករណីមានរឿងហេតុដែលមិនបង្កើតបានជាបទល្មើសព្រហ្មទណ្ឌ ដោយសារគ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីបំពេញនូវសញ្ញាណនៃធាតុផ្សំបទល្មើសតំណាងអយ្យការអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបាន ។ ក្នុងការអនុវត្តខ្លះយើងសង្កេតឃើញថា មានវិវាទរដ្ឋប្បវេណីមួយចំនួនដែលមានលក្ខណៈស្រដៀង ឬ ប្រហាក់ប្រហែលទៅនឹងបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានគេបកស្រាយឲ្យមានលក្ខណៈច្រឡំថា វាគឺជាបទល្មើសព្រហ្មទណ្ឌក្នុងគោលបំណងដើម្បីដាក់ឲ្យបណ្តឹងអាជ្ញាមានចលនា ដូចជាក្នុងករណី អំពើឆបោក (មាត្រា៣៤៧ នៃក្រមរដ្ឋប្បវេណី) និង បទល្មើសឆបោក (មាត្រា៣៧៧ នៃក្រមព្រហ្មទណ្ឌ)។

នៅក្នុងករណីខ្លះដែលអង្គហេតុបានបញ្ជាក់ច្បាស់តាមរយៈភស្តុតាងដាក់បន្ទុកផ្សេងៗថា ពិតជាមានបទល្មើសកើតឡើង ឬយ៉ាងណាក៏ដោយ ក៏តំណាងអយ្យការនៅតែអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបាន ប្រសិនបើតំណាងអយ្យការយល់ឃើញថាបទល្មើសនោះជារឿងក្តីដែលមិនគួរឲ្យចោទប្រកាន់ (**ក**) ឬជារឿងក្តីដែលមិនអាចចោទប្រកាន់បាន (**ខ**) ។[70]

#### ក.រឿងក្តីមិនគួរឲ្យចោទប្រកាន់

ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មិនបានកំណត់នូវមូលហេតុណាមួយសម្រាប់ការតម្កល់រឿងទុកឥតចាត់ការនោះឡើយ ។ ប៉ុន្តែក្នុងរឿងក្តីព្រហ្មទណ្ឌតំណាងអយ្យការនៅតែអាចតម្កល់រឿងទុក្ខឥចាត់ការបាន ប្រសិនតំណាងអយ្យការយល់ឃើញថា " បទល្មើសនោះតូចតាច មិនជះឥទ្ធិពលដល់តម្លៃការពារសង្គម ចំណែកឯព្យសនកម្ម ចំពោះជនរងគ្រោះទាំងផ្នែកសីលធម៌ និងសេដ្ឋកិច្ច ក៏មានភាពស្តួចស្តើង ហើយពេលខ្លះជនរងគ្រោះគ្មានការអើពើអ្វីសោះ " ។[71] ក្នុងករណីនេះ តើសង្គមដែលមិនមែនជាភាគីរងគ្រោះដោយផ្ទាល់ពីបទល្មើស គួរ

---

[70] សូមមើល "ការតម្កល់រឿងទុកឥតចាត់ការ" របស់ ផុន វណ្ណា ដែលផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ ខែ កក្កដា ឆ្នាំ ២០១៧, ទំព័រទី ២ ។

[71] សូមមើល "ការតម្កល់រឿងទុកឥតចាត់ការ" របស់ ផុន វណ្ណា ដែលផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ ខែ កក្កដា ឆ្នាំ ២០១៧, ទំព័រទី ៣ ។

មានវិធានការណាមួយទៅលើអំពើដែលជនរងគ្រោះដោយផ្ទាល់ពីបទល្មើស មិនមានការអើពើ ឬ មានវិធានការណាមួយសោះផងនោះ ? ដូចនេះការស្រាវជ្រាវទៅលើអំពើនេះ ហាក់បីដូចជាគ្មានប្រយោជន៍ ឬចាំបាច់សម្រាប់សង្គមទាល់តែសោះ ។ ការតម្កល់រឿងទុកឥតចាត់ការក៏អាចជាមូលហេតុនៃអវត្តមាននៃអត្តសញ្ញាណចារីផងដែរ ដែលនេះ គឺជាការបង្កនូវផលលំបាក និងការប៉ះពាល់ប្រសិទ្ធិភាពក្នុងការដំណើរការរឿងក្តី ឬ ការប្រកាសស្រាវជ្រាវរឿងក្តីនោះ ។ ក្នុងករណីបើស្គាល់ពីអត្តសញ្ញាណនៃជនល្មើស « ចៅក្រមអយ្យការចាំបាច់ត្រូវផ្តល់ជាសារដល់ជននេះ តាមរយៈការពន្យល់ណែនាំដើម្បីគេពន្យល់ណែនាំដើម្បីគេបានដឹងពីផលលំបាកនៃការផ្តន្ទាទោសហើយចេះកែប្រែខ្លួនឈប់ពីការប្រព្រឹត្តអំពើល្មើសច្បាប់តទៅទៀត » ។[72]

### ខ.រឿងក្តីមិនអាចចោទប្រកាន់បាន

ចំពោះករណីមួយចំនួន ច្បាប់បានកំណត់បានយ៉ាងជាក់លាក់ក្នុងការហាមមិនឲ្យធ្វើការចោទប្រកាន់តែម្តងដែលនេះគឺជាឧបសគ្គក្នុងការធ្វើបណ្តឹងអាជ្ញា ។ ជាក់ស្តែងដូចមានចែងក្នុងអនុសញ្ញាក្រុងវីយែនស្តីអំពីទំនាក់ទំនងការទូតបានកំណត់ថា « ភ្នាក់ងារទូតមានអភ័យឯកសិទ្ធិ ចំពោះអំណាចយុត្តាធិការព្រហ្មទណ្ឌរបស់ម្ចាស់ផ្ទះ »។[73] ក្នុងករណីនេះតំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់ណាមួយបានឡើយ ។

### គ.បច្ច័យនៃការតម្កល់រឿងទុកឥតចាត់ការ

ការអនុវត្តការតម្កល់រឿងទុកឥតចាត់ការ អាចបង្កើតជាភាពវិជ្ជមានជាច្រើនទៀតសម្រាប់សង្គមជាតិដូចជា ការកាត់បន្ថយនូវការកកស្ទះរឿងក្តីនៅតុលាការ ការកាត់បន្ថយភាពណែនស្ទះនៅក្នុងពន្ធនាគារ និងជាពិសេស វា ជួយជម្រុញការបំពេញការងាររបស់តំណាងអយ្យការឲ្យក្លាយជានិយ័តករដ៏រស់រវើកក្នុងសង្គម ដែលមិនមែនជាតួម៉ាស៊ីនសម្រាប់ការចោទប្រកាន់ដូចមុនឡើយ ។ ការអនុវត្តនេះក៏ជានយោបាយព្រហ្មទណ្ឌក្នុងការលុបបំបាត់ការបង្ក្រាបតាមបែបសងសឹកជាបណ្តើរៗដោយជំនួសមកវិញនូវនយោបាយព្រហ្មទណ្ឌ បង្ក្រាបតាមបែបអប់រំ ។[74]

ក្រៅពីភាពវិជ្ជមានក្នុងចំណុចខាងលើនេះ ការអនុវត្តនេះបានផ្តល់ផលអវិជ្ជមានមួយចំនួនទៀតដែលអាចកើតចេញពីការអនុវត្តគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់នេះ ដូចជា " ចៅក្រមអយ្យការមានអំណាចធំធេង ហើយគាត់អាចប្រើប្រាស់អំណាចនេះដើម្បីការពារផលប្រយោជន៍ និងបក្សពួករបស់ខ្លួនប្រសិនបើគាត់គ្មានមនសិការជាតិនឹងវិជ្ជាជីវៈ " ។[75] ក្នុងករណីនេះភាពយុត្តិធម៌នៅក្នុងប្រព័ន្ធតុលាការនឹងត្រូវ

---

[72] សូមមើល ទំព័រទី ៣ នៃ "ការតម្កល់រឿងទុកឥតចាត់ការ" របស់ ផុន វណ្ណា ដែលផ្សព្វផ្សាយរបស់សមាគមសាលាក្រាជូ ខែ កក្កដា ឆ្នាំ ២០១៧ ។

[73] សូមមើល ប្រការ ៣១ នៃអនុសញ្ញាក្រុងវីយ៉ែនស្តីពីទំនាក់ទំនងការទូត, អនុម័តដោយ សន្និសិទអង្គការសហប្រជាជាតិស្តីពីការប្រាស្រ័យទាក់ទងការទូត និងអភ័យឯកសិទ្ធិការទូត, នាថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៦១ ។

[74] សូមមើល ទំព័រទី ៤ នៃ "ការតម្កល់រឿងទុកឥតចាត់ការ" របស់ ផុន វណ្ណា ដែលផ្សព្វផ្សាយរបស់សមាគមសាលាក្រាជូ ខែ កក្កដា ឆ្នាំ ២០១៧ ។

[75] សូមមើល ទំព័រទី ៤ នៃ "ការតម្កល់រឿងទុកឥតចាត់ការ" របស់ ផុន វណ្ណា ដែលផ្សព្វផ្សាយរបស់សមាគមសាលាក្រាជូ ខែ កក្កដា ឆ្នាំ ២០១៧ ។

កាត់បន្ថយ ដែលជាហេតុធ្វើឲ្យប្រជាពលរដ្ឋគ្មាន ឬបាត់បង់នូវទំនុកចិត្តលើប្រពន្ធ័យុត្តិធម៌ទៅទៀត ។ ទោះបីជាយ៉ាងណាកដោយ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់នូវនីតិវិធីមួយចំនួនដើម្បីរាំងខ្ទប់នូវផលអវិជ្ជមានខាងលើ តាមរយៈការបើកផ្លូវឲ្យមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំពោះមុខចៅក្រមស៊ើបសួរ និងការសើរើដោយឯកឯងដោយតំណាងអយ្យការ ក្នុងករណីដែលបទល្មើសមិនទាន់ផុតអាជ្ញាយុកាល ។ សូមបញ្ជាក់បន្ថែមផងថា ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចដែលមានសំអាងច្បាប់ និង សំអាងហេតុដោយព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់ភាគីប្តឹងក្នុង រយៈពេលយ៉ាងខ្លីបំផុត ហើយភាគីប្តឹងក៏អាចធ្វើការប្តឹងតវ៉ា អំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការនេះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងរយៈពេល ២ ខែគិតចាប់ពីថ្ងៃទទួលដំណឹងពីការសម្រេចនោះ។[76]

**២.ជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការ**

ការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ គឺជាការធ្វើបណ្ដឹងអាជ្ញារបស់តំណាងអយ្យការដែលជាម្ចាស់នៃបណ្ដឹងអាជ្ញា ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌណ បានកំណត់ថាការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាមរយៈការបើកការស៊ើបសួរ (**ក**) ការបញ្ជូនទៅជំនុំជម្រះផ្ទាល់(**ខ**) ឬ តាមនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម(**គ**) ។[77]

**ក.ការបើកស៊ើបសួរ**

ការបើកការស៊ើបសួរ គឺជាជម្រើសមួយនៃការធ្វើបណ្ដឹងអាជ្ញារបស់តំណាងអយ្យការ ។ ការបើកការស៊ើបសួរត្រូវធ្វើឡើងតាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ ។ " ក្នុងករណីបទឧក្រិដ្ឋព្រះរាជអាជ្ញាត្រូវតែបើការស៊ើបសួរ "[78] ទោះបីជាបទល្មើសនោះជាបទឧក្រិដ្ឋជាក់ស្តែងក៏ដោយ ។ ដូចនេះព្រះរាជអាជ្ញាគ្មានជម្រើសណាផ្សេងក្រៅពីនេះឡើយ ចំនុចនេះស្តែងបង្ហាញឲ្យឃើញពីភាពដាច់ខាតនៃការចោទប្រកាន់របស់តំណាងអយ្យការ ។ ភាពដាច់ខាតនេះមិនបានស្តែងឡើងក្នុងករណីបទល្មើសជាបទមជ្ឈិមមិនជាក់ស្តែង ឬបទលហុទេ មានន័យថាតំណាងអយ្យការអាចធ្វើការចោទប្រកាន់ក្រៅពីជម្រើសផ្សេងក្រៅពីស៊ើបសួរ ។ ទោះជាយ៉ាងណា តំណាងអយ្យការនៅតែអាចធ្វើការចោទប្រកាន់តាមរយៈការស៊ើបសួរ ក្នុងករណីសំណុំរឿងមិនអាចធ្វើការជំនុំជម្រះបានដោយសារកត្តាផ្សេងៗដូចជាក្នុងករណីតំណាងអយ្យការយល់ឃើញថា ភស្តុតាងដែលប្រមូលបានពុំមានលក្ខណៈគ្រប់គ្រាន់ ដើម្បីជំនុំជម្រះ ឬ តំណាងអយ្យការមិនស្គាល់នូវអត្តសញ្ញាណចារី ដែលជាហេតុមិនអាចយកសំណុំរឿងទៅជំនុំជម្រះបាន ព្រោះចារី ជាអញ្ញាតជន ។ ដូចនេះ ព្រះរាជអាជ្ញាអាចនឹងបើកការ

[76] សូមមើល មាត្រា ៤១, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[77] សូមមើល មាត្រា ៤៣, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[78] សូមមើល មាត្រា ៤៣ កថាខណ្ឌទី១, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

ស៊ើបសួរដើម្បីកំណត់អំពីអត្តសញ្ញាណនៃចារីសិនឬក៏ប្រមូលនូវភស្តុតាងបន្ថែមទៀតសម្រាប់ដំណើរការនីតិវិធី។

ចំណែកឯចៅក្រមស៊ើបសួរ មានសិទ្ធិអំណាចក្នុងការស៊ើបសួរតែអង្គហេតុដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ ។ ក្នុងករណីព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរទទួលបានអង្គហេតុថ្មីនោះ ការស៊ើបសួរទៅលើអង្គហេតុថ្មីអាចប្រព្រឹត្តទៅបាន លុះត្រាតែមានដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញា ។ តែប្រសិនបើអង្គហេតុថ្មីនោះ គ្រាន់តែជាស្ថានទម្ងន់ទោសនៃអង្គហេតុ ដែលបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីមុននោះ ចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរតាមផ្លូវច្បាប់ដោយពុំចាំបាច់ជូនដំណឹងឲ្យតំណាងអយ្យការឡើយ ។ ក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវតែមានចែងនូវ[79] សេចក្តីសង្ខេបនៃអង្គហេតុការកំណត់ឈ្មោះនៃបទល្មើស ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និងឈ្មោះបុគ្គលដែលរងការស៊ើបសួរប្រសិនបើអាចកំណត់បាន ។

ក្នុងការសង្ខេបអង្គហេតុ ត្រូវមានកំណត់នូវកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើស ដើម្បីឲ្យចៅក្រមស៊ើបសួរអាចធ្វើការកំណត់អំពីអាជ្ញាយុកាលនៃបទល្មើស ។ ក្នុងដីកានេះទៀតសោត ត្រូវចុះកាលបរិច្ឆេទ និងការចុះហត្ថលេខានៃតំណាងអយ្យការ ដើម្បីបញ្ជាក់ពីឆន្ទៈក្នុងការចោទប្រកាន់ ។

### ខ.ការជំនុំជម្រះផ្ទាល់

ការជំនុំជម្រះផ្ទាល់ អាចធ្វើទៅបានតាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ។ ដែលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឲ្យជនជាប់ចោទ ចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ។ ក្នុងករណី បទលហុ ជម្រើសនៃការចោទប្រកាន់ គឺមានតែការជំនុំជម្រះផ្ទាល់តែប៉ុណ្ណោះ ។ ការជំនុះជម្រះផ្ទាល់អាចអនុវត្តបានតែចំពោះតុលាការជាន់ដំបូងទេ[80] ព្រោះមិនអាចប្រើនៅតុលាការជាន់ខ្ពស់ ដែលជាតុលាការទទួលបណ្តឹងតវ៉ាឡើយ ដោយសារការប្តឹងតវ៉ា គឺសុទ្ធសឹងតែមានការស៊ើបសួរដើម្បីរកភស្តុតាងបន្ថែម ដើម្បីបំពេញនូវចំណុចខ្វះចន្លោះនៃកម្មវត្ថុនៃបណ្តឹងតវ៉ានោះ ដែលផ្ទុយទៅនឹងនីតិវិធីនៃការជំនុំជម្រះផ្ទាល់ ដែលជានីតិវិធីមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់រួចហើយ ។

ការជំនុំជម្រះផ្ទាល់ គឺអាចអនុវត្តបានក្នុងករណីបទមជ្ឈិម ឬបទលហុ ដែលជាបទល្មើសមានលក្ខណៈស្រាល ហើយបទល្មើសនោះត្រូវមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ។ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ត្រូវមានកំណត់នូវអត្តសញ្ញាណនៃជនជាប់ចោទ សេចក្តីសង្ខេបនៃអង្គហេតុ ឈ្មោះបទល្មើស និង អត្ថបទច្បាប់ដែលកំណត់និងបង្ក្រាបបទល្មើស ជាពិសេសត្រូវមានការចង្អុលបង្ហាញប្រាប់ពីតុលាការដែលត្រូវជំនុំជម្រះ ព្រម

[79] សូមមើល មាត្រា ៤៣ កថាខណ្ឌទី៣, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[80] សូមមើល មាត្រា ៤៦ កថាខណ្ឌទី១, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

ទាំង ទីកន្លែង កាលបរិច្ឆេទ និងពេលវេលានៃសវនសការ ។ម្យ៉ាងវិញទៀត ដីកានោះត្រូវបានបញ្ជាក់ថាជនជាប់ចោទអាចរកមេធាវីដើម្បីអមខ្លួនបាន។ ចិរវេលានៃការបញ្ជូនដីកាកោះហៅ និង ថ្ងៃកំណត់ឲ្យចូលបង្ហាញខ្លួនជនជាប់ចោទនៅចំពោះមុខតុលាការ ៖

- មានរយៈពេល ១៥ថ្ងៃប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់ តុលាការជាន់ដំបូង
- មានរយៈពេល ២០ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា
- មានរយៈពេល ២ ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននឹងកម្ពុជា
- មានរយៈពេល ៣ ខែ ប្រសិនបើជនជាប់ចោទរស់នៅកន្លែងផ្សេង ក្រៅពីករណីខាងលើ ។[81]

ការគិតរយៈពេលនេះ នឹងត្រូវគិតម្តងទៀតរាល់ពេលកោះហៅនៅពេលក្រោយៗ ។ ការប្រគល់លិខិតនេះត្រូវប្រគល់ដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា ឬអាជ្ញាសាលា ។ ចំពោះការប្រគល់ដោយអាជ្ញាសាលា អាជ្ញាសាលនោះត្រូវតែចាសេចក្តីលើដើមដីកាថា បានប្រគល់ចុងដីកាដល់ជនជាប់ចោទ ឬបុគ្គលមានវត្តមានក្នុងផ្ទះជនជាប់ចោទដោយផ្ទាល់ដៃ ដើម្បីបង្ហាញថាពិតជាបានប្រគល់ដល់ដៃជនជាប់ចោទ ឬបុគ្គលមានវត្តមានក្នុងផ្ទះជនជាប់ចោទ ។ បើករណីមានការមិនព្រមទទួលលិខិត ឬគ្មានវត្តមានបុគ្គលណាមួយក្នុងលំនៅឋាន នោះត្រូវប្រគល់ជូនមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង ។ ក្រៅពីព្រះរាជអាជ្ញា និងអាជ្ញាសាលានោះ លិខិតនេះក៏អាចត្រូវប្រគល់ដោយប្រធានពន្ធនាគារឬប្រធានមណ្ឌលឃុំខ្លួន ដោយក្រឡាបញ្ជី ដោយនគរបាលយុត្តធម៌ ឬតាមផ្នែករដ្ឋបាល ។

សូមបញ្ជាក់ផងដែរថា រាល់ការប្រគល់ដីកាកោះហៅបញ្ជូលទៅជំនុំជម្រះផ្ទាល់ ត្រូវមានចុះបញ្ជាក់ពី ឋានៈរបស់បុគ្គលដែលប្រគល់ដោយចុះនិទ្ទេស និង មានហត្ថលេខារបស់បុគ្គលនោះ ។

**គ.ការបង្ហាញខ្លួនភ្លាម**

ជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការ តាមរយៈការជំនុំជម្រះផ្ទាល់ គឺជានីតិវិធីឆាប់រហ័ស មានន័យថា ជនល្មើសអាចត្រូវយកទៅជំនុំជម្រះភ្លាមក្រោយការឃាត់ខ្លួន ។ នីតិវិធីនេះមិនអាចយក មកអនុវត្តចំពោះបទឧក្រិដ្ឋដែលជាកម្មវត្ថុនៃការស៊ើបសួរ និងបទលហុ ដែលជាកម្មវត្ថុនៃការជំនុំជម្រះផ្ទាល់បានឡើយ ។

ដើម្បីអនុវត្តនូវនីតិវិធីនេះបានត្រូវគោរពនូវលក្ខខណ្ឌមួយចំនួនដូចជា ៖

- បទល្មើសនោះត្រូវតែជាបទមជ្ឈិមជាក់ស្តែង តាមបញ្ញត្តិមាត្រា ៨៦ ឬមាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[81] សូមមើល មាត្រា ៤៥៧ កថាខណ្ឌទី១, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

- បទល្មើសនោះត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារយ៉ាងតិច ១ ឆ្នាំ និង យ៉ាងច្រើន ៥ ឆ្នាំ
- នីតិវិធីនេះត្រូវអនុវត្តចំពោះតែចារីជានីតិជន
- ជាពិសេសរឿងក្តីនោះត្រូវតែមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ។[82]

ចំពោះពាក្យថា « គ្រប់គ្រាន់ល្មមជំនុំជម្រះបាន » មានន័យថា មានភស្តុតាងគ្រប់គ្រាន់ធួនល្មមដែលអាចបំពេញគ្រប់សញ្ញាណនៃធាតុផ្សំបទល្មើសដែលប្រព្រឹត្តដោយជនជាប់ចោទ ហើយដែលមានលក្ខណៈអាចជឿជាក់បានថាជនជាប់ចោទពិតជាចារីបានប្រព្រឹត្តបទល្មើសពិតមែន ។

ជានីតិវិធីជាក់ស្តែង ក្រោយការឃាត់ខ្លួនជនល្មើស នឹងត្រូវបានបញ្ជូនទៅបង្ហាញខ្លួនចំពោះតំណាងអយ្យការដើម្បីធ្វើការសាកសួរអំពីអត្តសញ្ញាណ ប្រាប់ពីការចោទប្រកាន់ ប្រាប់ពីបញ្ញត្តិច្បាប់ដែលត្រូវចោទ និងប្រាប់ពីសិទ្ធិមួយចំនួនដែលជននោះត្រូវដឹង ហើយតំណាងអយ្យការត្រូវទទួលចម្លើយរបស់ជននោះប្រសិនបើគាត់ចង់និយាយ និងត្រូវធ្វើកំណត់ហេតុអំពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ។[83] ជាពិសេស តំណាងអយ្យការត្រូវឲ្យជនជាប់ចោទដឹងថារឿងក្តីនេះអាចនឹងត្រូវយកមកជំនុំជម្រះនៅថ្ងៃនេះភ្លាមតែម្តង ហើយតើជនជាប់ចោទត្រូវការមេធាវីតាមការចាត់តាំង ឬការជ្រើសរើសមេធាវីដោយខ្លួនឯង ។ ការបង្ហាញខ្លួនភ្លាមនេះនឹងត្រូវអនុវត្តតាមរយៈកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម ។

នៅពេលសំណុំរឿងបានមកដល់តុលាការ តុលាការនោះត្រូវធ្វើការពិនិត្យជាថ្មីដើម្បីធ្វើការផ្ទៀងផ្ទាត់មើលព័ត៌មានដែលមានក្នុងកំណត់ហេតុ ហើយតុលាការក៏ត្រូវប្រាប់ជនជាប់ចោទអំពីរយៈពេលនៃថ្ងៃរៀបចំខ្លួនដើម្បីចូលការពារ ។ ក្នុងករណីនេះ សវនាការអាចត្រូវបានលើកទៅពេលក្រោយប្រសិនបើមានការស្នើសុំរយៈពេលរៀបចំការពារខ្លួន ។ ការលើកសវនាការនេះក៏ត្រូវអនុវត្តផងដែរ បើតុលាការយល់ឃើញថាមិនទាន់អាចជំនុំជម្រះបាន ។ ការលើកឡើងសវនាការនេះ តម្រូវឲ្យ " តុលាការបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន តាមសាលក្រមដែលមានសំអាងហេតុ "។[84] តុលាការត្រូវចេញដីកាបង្គាប់ឲ្យឃុំខ្លួន ដែលការឃុំខ្លួននេះត្រូវអនុវត្តតាមបញ្ញត្តិមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានកំណត់ពីរយៈពេលដែលត្រូវបើកសវនាការឡើយ ប៉ុន្តែបានកំណត់ថា "សាលក្រមលើអង្គសេចក្តីត្រូវបានប្រកាសក្នុងរយៈពេល ២ សប្តាហ៍ គិតចាប់ពីថ្ងៃចូលទៅបង្ហាញខ្លួនចំពោះមុខតុលាការ " ។[85] បើមិនដូច្នេះទេ ការឃុំខ្លួនបណ្តោះអាសន្ននឹងត្រូវបញ្ឈប់ដោយពេញច្បាប់ មានន័យថាត្រូវតែដោះលែងជនជាប់ចោទវិញដែលផ្តោតលើការឃុំខ្លួនមិនគួរត្រូវបាន

[82] សូមមើល មាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[83] សូមមើល មាត្រា ៤៨ កថាខណ្ឌទី១, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[84] សូមមើល មាត្រា ៣០៤ កថាខណ្ឌទី៩, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[85] សូមមើល មាត្រា ៤៨ កថាខណ្ឌទី១០, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

អនុវត្តក្នុងរយៈពេលដ៏យូរនោះទេ ព្រោះការបង្ហាញខ្លួនភ្លាមអនុវត្តបានតែក្នុងករណីបទមជ្ឈិមជាក់ស្តែង ដែលជាបទល្មើសមានលក្ខណៈមិនសូវធ្ងន់ធ្ងរដូចបទ -ឧក្រិដ្ឋ និង មានភាពងាយស្រួលក្នុងការប្រមូលភស្តុតាង ។ ក្នុងការជ្រើសរើសយកនីតិវិធីនៃការបង្ហាញខ្លួនភ្លាមមកអនុវត្ត តំណាងអយ្យការគួរតែពិនិត្យឲ្យបានម៉ឺងម៉ាត់ និងគួរតែមានភាពជឿជាក់លើការចោទប្រកាន់របស់ខ្លួនថា ជនជាប់ចោទពិតជាមានពិរុទ្ធភាពពិតមែន មុននឹងសម្រេចដាក់ឲ្យមានការបង្ហាញខ្លួនភ្លាម ។

ក្នុងករណីដែលតុលាការយល់ឃើញថា ការអនុវត្តនីតិវិធីបង្ហាញខ្លួនភ្លាមមិនអាចអនុវត្តតទៅទៀតទេ ឬលក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាមមិនបានបំពេញគ្រប់គ្រាន់ទេ ឬក៏សំណុំរឿងមានលក្ខណៈសាំញ៉ាំដោយសាការខ្វះភស្តុតាងផ្សេងៗនោះចៅក្រមអាចបញ្ជូនសំណុំរឿងទៅតំណាងអយ្យការវិញ ដើម្បីបើកការស៊ើបសួរ ។ ក្នុងករណីនេះ ជនជាប់ចោទត្រូវបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរក្នុងថ្ងៃដដែលនៃថ្ងៃបញ្ជូនសំណុំរឿងទៅតំណាងអយ្យការ បើមិនដូចច្នេះទេជនជាប់ចោទត្រូវតែបានទទួលការដោះលែងដោយឯកឯង ។

# ជំពូកទី៣
# ស្ថាប័នអយ្យការក្នុងកិច្ចនីតិវិធីរឿងក្ដីព្រហ្មទណ្ឌ

ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយដែលមានតួនាទីសំខាន់នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ព្រោះអយ្យការ គឺជាអ្នកការពារផលប្រយោជន៍សាធារណៈ ជានិយ័តករមួយនៃសង្គម ជាអ្នកការពារផងប្រយោជន៍ច្បាប់ព្រហ្មទណ្ឌ និងជាម្ចាស់នៃបណ្ដឹងអាជ្ញា ។ ដូចនេះតំណាងអយ្យការត្រូវតែមានវត្តមានរាល់ដំណើរការនីតិវិធីព្រហ្មទណ្ឌ ដូចជាការដឹកនាំក្នុងការស៊ើបអង្កេតដែលជាសមត្ថកិច្ចរបស់ខ្លួន ដើម្បីប្រមូលភស្តុតាងដាក់បន្ទុក និងសិក្សាអំពីបទល្មើស ( **ផ្នែកទី១** ) ។ ក្រៅពីនេះតំណាងអយ្យការក៏អាចចូលរួមគ្រប់កិច្ចស៊ើបសួរផងដែរ ទោះបីជាកិច្ចស៊ើបសួរជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរក៏ដោយ ។ នៅក្នុងការបើកការស៊ើបសួរ តំណាងអយ្យការមានតួនាទីកំណត់នូវដែន ឬទំហំនៃអង្គហេតុនៃបទល្មើស ដើម្បីឲ្យចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរបានតាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ( **ផ្នែកទី២** ) ។ ចំពោះនីតិវិធីជំនុំជម្រះ អយ្យការត្រូវចូលរួមក្នុងសវនការដើម្បីធ្វើការស្នើសុំឲ្យមានការអនុច្បាប់ ឬទោសតាមរយៈសេចក្ដីសន្និដ្ឋានរបស់ខ្លួនចំពោះមុខយុត្តាធិការជំនុំជម្រះ ប៉ុន្តែអំណាចក្នុងការវិនិច្ឆ័យសម្រេចដើម្បីបន្ថែម ឬបន្ថយទោស គឺទៅតាមឆន្ទានុសិទ្ធិរបស់តុលាការ(**ផ្នែកទី៣**) ។ ជាចុងក្រោយ អយ្យការក៏ជាអ្នកអនុវត្តសេចក្ដីសម្រេចស្ថាពររបស់តុលាការ និងជាអ្នកធានាដល់ការអនុវត្តទោសឲ្យបានជោគជ័យ ( **ផ្នែកទី៤** ) ។

## ផ្នែកទី១៖ ការដឹកនាំការស៊ើបអង្កេតរបស់អយ្យការ

នៅក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត គោលការណ៍នៃភាពអាថ៌កំបាំងត្រូវបានយកមកអនុវត្តមានន័យថា "ការស៊ើបអង្កេត ត្រូវតែជាការសម្ងាត់ " ។[86] មានន័យថា រាល់ព័ត៌មានដែលតំណាងអយ្យការទទួលបាន តំណាងអយ្យការត្រូវតែថែរក្សាការសម្ងាត់នៃវិជ្ជាជីវៈជាដាច់ខាត ដោយជៀសវាងឲ្យបានរាល់ការផ្សព្វផ្សាយនូវព័ត៌មានទាំងនោះទៅដល់សាធារណៈ ។ ប៉ុន្តែ ការគោរពនូវការរក្សាការសម្ងាត់មិនមែនជាឧបសគ្គសម្រាប់តំណាងអយ្យការក្នុងការការពារខ្លួន នៅពេលមានការចោទប្រកាន់ចំពោះខ្លួនឡើយ ។

សរុបមកការស៊ើបអង្កេត គឺជានីតិវិធីមួយដែលត្រូវបានដឹកនាំដោយតំណាងអយ្យការ ។ នៅក្នុងដំណាក់កាលស៊ើបអង្កេត ជនល្មើសមានឈ្មោះត្រឹមជនសង្ស័យក្នុងការប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ ដូចនេះតំណាងអយ្យការត្រូវតែស្វែងរកភស្តុតាងដាក់បន្ទុកឲ្យបានគ្រប់គ្រាន់តាមរយៈការស៊ើបអង្កេត ដើម្បីធ្វើការចោទប្រកាន់ទៅលើជនសង្ស័យ ហើយបញ្ជូនសំណុំរឿងទៅតុលាការ ។ ការស៊ើបអង្កេត ត្រូវបានបែងចែកជាពីរប្រភេទ គឺការស៊ើបអង្កេតករណីជាក់ស្ដែង (**កថាខណ្ឌទី១**) និងការស៊ើបអង្កេតបឋម (**កថាខណ្ឌទី២**) ។

[86] សូមមើល មាត្រា ៨៣ កថាខណ្ឌទី១, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

## កថាខណ្ឌទី១៖ ការស៊ើបអង្កេតករណីជាក់ស្តែង

ការស៊ើបអង្កេតករណីជាក់ស្តែង ត្រូវបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពី មាត្រា ៨៥ ដល់ មាត្រា ១០១ ។ ការស៊ើបអង្កេតករណីជាក់ស្តែង នេះត្រូវបានយកមកអនុវត្តដើម្បីប្រមូលភស្តុតាងក្នុងស្ថានភាពបន្ទាន់ ចំពោះបទល្មើសដែលទើបប្រព្រឹត្តហើយថ្មីៗ ។ ហេតុនេះហើយ ទើបគេបង្កើតឲ្យមានការស៊ើបអង្កេតករណីជាក់ស្តែង ដែលជាវិធានដែរមានលក្ខណៈបែបហ័ស និងផ្តល់អំណាចទូលំទូលាយដល់អាជ្ញាធរ ដើម្បីងាយស្រួលក្នុងការប្រមូលភស្តុតាងទាំងនោះ ។ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង ក៏អាចត្រូវអនុវត្តដើម្បីធានាការពារបង្ការ និងស្តារឡើងវិញឲ្យបានឆាប់រហ័សនូវការខូចខាតនៃសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ អាយុជីវិតមនុស្ស រូបរាងកាយ ឬទ្រព្យសម្បត្តិដែលបង្កឡើងដោយបល្មើស ។[87] ដូចនេះ ពេលវេលាជាកត្តាសំខានបំផុតសម្រាប់ការស៊ើបអង្កេតករណីជាក់ស្តែង ព្រោះភស្តុតាងអាចត្រូវបានបាត់ដានតាមភាពចេតនា ឬអចេតនាណាមួយ ដែលនេះតម្រូវឲ្យកម្លាំងនគរបាលយុត្តិធម៌ត្រូវធ្វើការឲ្យលឿនបំផុតតាមដែលអាចធ្វើបាន និងប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុតដើម្បីធានាដល់ការប្រមូលភស្តុតាង ។ ក្នុងការសិក្សាអំពីការស៊ើបអង្កេតករណីជាក់ស្តែង យើងនឹងសិក្សាអំពីលក្ខខណ្ឌនៃការបើកការស៊ើបអង្កេតករណីជាក់ស្តែង និងនីតិវិធីមួយចំនួននៃការស៊ើបអង្កេតជាក់ស្តែង ដើម្បីធានាដល់ការបង្ហាញពិរុទ្ធភាពនៃជនល្មើស ។

### ១. លក្ខខណ្ឌនៃការបើកការស៊ើបអង្កេតករណីជាក់ស្តែង

ដើម្បីបើកការស៊ើបអង្កេតករណីជាក់ស្តែង យើងត្រូវដឹងជាមុនសិនអំពីដែនអនុវត្តក្នុងការបើកការស៊ើបអង្កេតនេះថា តើការបើកការស៊ើបអង្កេតនេះអាចអនុវត្តបានក្នុងលក្ខខណ្ឌណាខ្លះ(ក)? ហើយតើស្ថានភាពបែបណាទើបហៅថាជាស្ថានភាពជាក់ស្តែងនៃបទល្មើស (ខ) ?

#### ក. ដែនអនុវត្ត

ការស៊ើបអង្កេតករណីជាក់ស្តែង មិនមែនអាចអនុវត្តបានដោយសារអំណោយនៃការស៊ើបអង្កេតជាក់ស្តែងឡើយ ប៉ុន្តែដោយសារមានតែការកើតឡើងនូវស្ថានភាពជាក់ស្តែងណាមួយ ដែលអនុញ្ញាតឲ្យនគរបាលយុត្តិធម៌ ឬតំណាងអយ្យការអាចប្រើប្រាស់អំណាចស៊ើបអង្កេតជាក់ស្តែង ។[88] ដូចនេះ ការស៊ើបអង្កេតករណីជាក់ស្តែងនេះ គឺកើតឡើងតាមរយៈស្ថានភាពជាក់ស្តែងមួយដែលបានកើតឡើងទើបបណ្តាលឲ្យមានការស៊ើបអង្កេតករណីជាក់ស្តែងនេះ ។

[87] សូមមើល ទំព័រទី៨, នៃការផ្សព្វផ្សាយរបស់សមាគមសាលាជូ ខែ កញ្ញា ឆ្នាំ ២០១៦, ស្តីពី "បទល្មើសជាក់ស្តែងក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា" របស់ ចក សម្បត្តិ http://salatraju.com/index.php/post?p=162 ។

[88] សូមមើល ការផ្សព្វផ្សាយរបស់សមាគមសាលាជូ ខែ កញ្ញា ឆ្នាំ ២០១៦, ស្តីពី "បទល្មើសជាក់ស្តែងក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា" របស់ ចក សម្បត្តិ http://salatraju.com/index.php/post?p=162 ។

បើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ គេពុំបានកំណត់អំពីការស៊ើបអង្កេតករណីជាក់ស្តែងណាមួយ ដែលត្រូវអនុវត្តនៅក្នុងករណីបទលហុទ្បើយ ។ ផ្ទុយទៅវិញ ការស៊ើបអង្កេតនេះ ត្រូវបានកំណត់ដាក់ឲ្យអនុវត្តតែក្នុងករណីបទឧក្រិដ្ឋជាក់ស្តែង និង បទមជ្ឈឹមជាក់ស្តែងតែប៉ុណ្ណោះ ។[89] ការស៊ើបអង្កេតនេះអាចត្រូវបានអនុវត្តដែរ ក្នុងករណីនៃការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋជាក់ស្តែង ឬ បទមជ្ឈឹមជាក់ស្តែង។

### ខ. ស្ថានភាពជាក់ស្តែង

ដូចដែលបានរៀបរាប់ពីខាងលើរួចមក គឺមានតែស្ថានភាពជាក់ស្តែងប៉ុណ្ណោះ ជាអ្នកធ្វើឲ្យមានការបើកការស៊ើបអង្កេតករណីជាក់ស្តែង។ ដូចនេះតើអ្វីទៅជាស្ថានភាពជាក់ស្តែង?

ស្ថានភាពជាក់ស្តែងត្រូវបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌថា"បទឧក្រិដ្ឋឬបទមជ្ឈឹមជាក់ស្តែង"គឺៈ

–បទល្មើសដែលកំពុងតែប្រព្រឹត្ត

–បទល្មើសដែលទើបតែប្រព្រឹត្តរួចភ្លាមៗ ។

❖ ត្រូវចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក ៖

–ជនដែលគេសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រកីង

–បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬស្លាក់ស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាផ្សេងទៀត ដែលនាំឲ្យមានគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬ បានចូលរួមប្រព្រឹត្តបទល្មើស" ។[90] ដូចនេះការកំណត់ពីស្ថានភាពជាក់ស្តែងត្រូវយោងទៅលើស្ថានភាពដែលបានរៀបរាប់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះ ។

ការកំណត់ពីអត្ថិភាពនៃស្ថានភាពជាក់ស្តែង អាចត្រូវបានកំណត់តាមរយៈការសម្គាល់វត្ថុវិស័យ ឬការសង្កេតផ្សេងៗ តាមរយៈវិញ្ញាណណាមួយនៃអ្នកស៊ើបអង្កេតដោយភ្នែក ត្រចៀក អណ្តាត រូបរាងកាយ ឬច្រមុះ។[91] អាជ្ញាធរមានសមត្ថកិច្ចអាចស្វែងយល់បានភ្លាមៗតាមរយៈការគិតត្រិះរិះពិចារណារបស់ខ្លួនថា តើមានស្ថានភាពជាក់ស្តែងកំពុងកើតឡើងទេ? ដូចនេះស្ថានភាពជាក់ស្តែងមួយ អាចកើតឡើងដោយសារតែមានភាវៈខាងក្រៅណាមួយបានស្តែងឡើង បង្កើតទៅជាកត្តាសត្យានុម័ត ទើបអាជ្ញាធរមានសមត្ថកិច្ចអាចចូលរួមអន្តរាគមន៍បាននៅក្នុងស្ថានភាពនោះដោយប្រើប្រាស់អំណាចស៊ើបអង្កេតក្នុងករណីជាក់ស្តែងដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។ ដូចនេះ អាជ្ញាធរត្រូវកំណត់ឲ្យបានជាមុនសិនថា ពិតជាមានស្ថានភាពជាក់ស្តែងកើតឡើងមែន បើពុំដូច្នេះទេ គ្រប់កិច្ចទាំងឡាយដែលបានធ្វើឡើងដោយអាជ្ញាធរនោះត្រូវទុកជាមោឃៈ ។

---

[89] សូមមើល មាត្រា ៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[90] សូមមើល មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[91] សូមមើល ការផ្សព្វផ្សាយរបស់សមាគមសាលាជូ ខែ កញ្ញា ឆ្នាំ ២០១៦, ស្តីពី "បទល្មើសជាក់ស្តែងក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា" របស់ ចក សម្បត្តិ http://salatraju.com/index.php/post?p=162 ។

ចំពោះស្ថានភាពខ្លះ អាជ្ញាធរធ្វើការបើកការស៊ើបអង្កេតបឋមជាមុនសិន ដើម្បីអាចឈានទៅកំណត់ស្ថានភាពជាក់ស្តែង និងបន្ទាប់មកទើបធ្វើការបើកការស៊ើបអង្កេតជាក់ស្តែងក៏បាន ។ ការស៊ើបអង្កេតបទល្មើសជាក់ស្តែងមិនអាចអនុវត្តលើសពី ៧ ថ្ងៃ នោះទេ គិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស ។[92] ប្រសិនជាក្រោយការបើកការស៊ើបអង្កេតជាក់ស្តែង ហើយនៅតែពុំអាចស្វែងរកភស្តុតាងជាក់បន្ទុកគ្រប់គ្រាន់ទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ពីតំណាងអយ្យការ ក្នុងករណីនេះតំណាងអយ្យការអាចសម្រេចបិទការធ្វើស៊ើបអង្កេត ឬបើកការស៊ើបអង្កេតបឋមវិញក៏បាន ។ ឧទាហរណ៍ ៖ ដូចក្នុងករណីស្វែងរកកន្លែងផលិតសារធាតុញៀន ជាដំបូងយើងពុំទាន់អាចកំណត់បានទេ ថាកន្លែងផលិតគ្រឿងញៀននៅទីណា ។ ដូចនេះយើងត្រូវធ្វើការបើកការស៊ើបអង្កេតបឋមជាមុនសិន ។ បន្ទាប់ពីបានរកឃើញថាមានកន្លែងដែលសង្ស័យហើយ យើងអាចធ្វើការបើកការស៊ើបអង្កេតជាក់ស្តែងវិញដើម្បីធានាដល់ការប្រមូលភស្តុតាងនៅកន្លែងកើតហេតុ ប៉ុន្តែប្រសិនជាចូលទៅដល់កន្លែងកើតហេតុ ភស្តុតាងត្រូវបានកម្ទេចចោលអស់ ។ ក្នុងករណីនេះ អាជ្ញាធរនៅតែអាចបើកការស៊ើបអង្កេតបឋមជាថ្មីម្តងទៀត ដើម្បីស្វែងរកប្រមូលភស្តុតាងទាំងនោះឲ្យបាន ។

ក្រៅពីស្ថានភាពដែលបានកំណត់ខាងលើនេះ យើងក៏នៅមានស្ថានភាពខ្លះទៀតដែលអាចឈានទៅដល់ការបើកការស៊ើបអង្កេតជាក់ស្តែងបានដែរ ដោយយោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា " គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះដោយសុំព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ " ។[93] នៅក្នុងស្ថានភាពបែបនេះ អាជ្ញាធរមានសមត្ថកិច្ចក៏អាចបើកការស៊ើបអង្កេតជាក់ស្តែង ដើម្បីឈានទៅប្រមូលភស្តុតាង សម្រាប់បង្ហាញពីអត្ថិភាពនៃការប្រព្រឹត្តបទល្មើស ទោះជាចារីជាអញ្ញាតជនក៏ដោយ ។ ភ្នាក់ងារនគរបាលយុត្តិធម៌អាចបំពេញភារកិច្ចត្រឹមអំណាចខ្លួនដែលជាភ្នាក់ងារនគរបាលយុត្តិធម៌តែប៉ុណ្ណោះ ដែលជាជំនួយការរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺមិនអាចមានសិទ្ធិអំណាចដូចមន្ត្រីនគរបាលយុត្តិធម៌ឡើយ ។

**២.ការចុះទៅកន្លែងកើតហេតុ**

មន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ចត្រូវតែរាយការណ៍ជូនព្រះរាជអាជ្ញា ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ។ ជាទូទៅ ការចុះទៅធ្វើការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌គ្រាន់តែធ្វើការរាយការណ៍ភ្លាមមកព្រះរាជអាជ្ញាតាមរយៈទូរស័ព្ទតែប៉ុណ្ណោះ ដោយសារតែជាស្ថានភាពបន្ទាន់។

---

[92] សូមមើល មាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[93] សូមមើល មាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

នៅពេលចុះទៅកន្លែងកើតហេតុ មន្ត្រីនគរបាលយុត្តិធម៌គឺជាអ្នកធានារ៉ាប់រងរក្សាទុកតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់ ហើយមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការហាមឃាត់គ្រប់បុគ្គល កុំឲ្យទៅណាឆ្ងាយពីកន្លែងកើតហេតុ រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួននេះ ។[94] ដូចនេះទាំងសាក្សី ឬបុគ្គលដែលពាក់ព័ន្ធត្រូវស្ថិតនៅក្រោមការហាមឃាត់របស់មន្ត្រីនគរបាលយុត្តិធម៌ ។ ការចុះទៅកន្លែងកើតហេតុ គឺជារឿងដែលចាំបាច់បំផុតសម្រាប់មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវធ្វើការពិនិត្យកត់ត្រា[95] ដែលជាប្រយោជន៍សម្រាប់ភស្តុតាង និងត្រូវប្រមូលភស្តុតាងឲ្យលឿនបំផុតតាមដែលអាចធ្វើបាន ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន[96] បើពុំដូច្នេះទេ នីតិវិធីត្រូវមោឃៈភាព[97] ។ ព្រះរាជអាជ្ញាអាចចុះទៅកន្លែងកើតហេតុតាមការយល់ឃើញរបស់ខ្លួនថា តើការចុះទៅរបស់ខ្លួននេះមានផលប្រយោជន៍ដល់នីតិវិធី ឬអត់។ ជាទូទៅ ព្រះរាជអាជ្ញាចុះទៅកន្លែងកើតហេតុ តែក្នុងករណីបទល្មើសធ្ងន់ធ្ងរតែប៉ុណ្ណោះ ដើម្បីដឹកនាំនីតិវិធីដោយផ្ទាល់ ។ បើព្រះរាជអាជ្ញាជាអ្នកចុះទៅ ព្រះរាជអាជ្ញា គឺជាអ្នកដឹកនាំ និងសម្របសម្រួលមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត ។ ការស៊ើបអង្កេតលើវិសាលភាពទាំងមូលលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា អាចត្រូវបានអនុញ្ញាតដោយផ្ទាល់ពីព្រះរាជអាជ្ញា ក្នុងករណីចាំបាច់ និងបន្ទាន់ ។

### ៣.ការឆែកឆេរ និងការប្រមូលភស្តុតាង

ការឆែកឆេរ គឺជាសិទ្ធិក្នុងការស្រាវជ្រាវអំពីធាតុនៃវត្ថុតាង និងអំពីការប្រព្រឹត្តបទល្មើសណាមួយ ។[98] ការឆែកឆេរ គឺជាវិធានការបង្ខំមួយដ៏សំខាន់ដើម្បីចាប់យកភស្តុតាងក្នុងការស៊ើបអង្កេតប៉ុន្តែការឆែកឆេរហាក់បីដូចជាវិធានដែលត្រូវប្រុងប្រយ័ត្នផងដែរ ព្រោះការរំលោភបំពានសិទ្ធិលំនៅឋានរបស់អ្នកដទៃអាចកើតមានប្រសិនជាការឆែកឆេរនោះធ្វើខុសនឹងនីតិវិធី ដែលកំណត់ដោយច្បាប់ ។ នៅក្នុងករណីនេះផងដែរ អ្នកដែលត្រូវទទួលខុសត្រូវនូវកំហុសឆ្គងក្នុងការអនុវត្តនីតិវិធី គឺតំណាងអយ្យការអ្នកដែលដឹកនាំ និងសម្របសម្រួលនីតិវិធី ហើយក៏ជាអ្នកចេញបញ្ជាដល់នគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត ។ ការឆែកឆេរនេះត្រូវបានប្រព្រឹត្តឡើងដើម្បីអាចប្រមូលភស្តុតាង

---

[94] សូមមើល មាត្រា ៨៩ កថាខណ្ឌទី២, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[95] សូមមើល មាត្រា ៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[96] សូមមើល មាត្រា ៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[97] សូមមើល មាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[98] សូមមើល ការផ្សព្វផ្សាយរបស់សមាគមសាលាជូ ខែ កញ្ញា ឆ្នាំ ២០១៦, ស្តីពី "ការចុះទៅលំនៅឋាន ការឆែកឆេរ និងការចាប់យកវត្ថុតាង" របស់ ចក សម្បត្តិhttps://salatraju.org/post/35 ។

នៅក្នុងលំនៅឋានរបស់បុគ្គលណាមួយ ។ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរទៅបាន តាមរយៈការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញាជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។[99] ដូចនេះ ការឆែកឆេរអាចអនុវត្តបានដោយមន្ត្រីនគរបាលយុត្តិធម៌តែប៉ុណ្ណោះ ដែលមិនមែនជាភ្នាក់ងារនគរបាលយុត្តិធម៌ ហើយការឆែរឆេរនោះត្រូវទទួលបានការអនុញ្ញាតពីព្រះរាជអាជ្ញាជាមុនសិន ។

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា " ការរក្សាសិទ្ធិមិនឲ្យរំលោភលើលំនៅឋាន [...]ត្រូវបានធានា ។[100] និង " ការឆែកឆេរលំនៅឋាន សម្ភារៈ វត្ថុ និងលើរូបបុគ្គលត្រូវធ្វើស្របនឹងបញ្ញត្តិច្បាប់" ។[101] ដូចគ្នាផងដែរ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញតាមរយៈមាត្រា៣១ បានកំណត់ថា " គ្មានជនណាម្នាក់ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុង [...] លំនៅឋាន [...] ។[102] ហើយ " ជនគ្រប់រូបមានសិទ្ធិឲ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀតជ្រែក ឬប៉ះពាល់បែបនេះ " ។[103] ចំពោះការរំលោភបំពានសិទ្ធិលំនៅឋានក៏ត្រូវបានការពារដោយច្បាប់ព្រហ្មទណ្ឌកម្ពុជាផងដែរ ដោយក្រមព្រហ្មទណ្ឌបានកំណត់ថា "អំពើប្រព្រឹត្តទៅដោយមានហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬឧបាយកលចូលទៅក្នុងលំនៅឋានអ្នកដទៃនោះ ត្រូវផន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ១ ឆ្នាំ [...] ។[104] ដូចនេះសិទ្ធិលំនៅឋានត្រូវបានធានាយ៉ាងតឹងរ៉ឹង ដែលជាហេតុធ្វើឲ្យការឆែរឆេរត្រូវអនុវត្តយ៉ាងតឹងរ៉ឹងផងដែរ ដើម្បីជៀសវាងការរំលោភបំពានដោយប្រការណាមួយ ។

ការឆែកឆេរត្រូវប្រព្រឹត្តទៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ប្រសិនបើគ្មានអ្នកកាន់កាប់ទីកន្លែងនោះទេ គឺត្រូវធ្វើនៅចំពោះមុខសាក្សី ២នាក់ ដែលចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ។ សាក្សីទាំងនោះមិនអាចជានគរបាលយុត្តិធម៌ ឬជាកងរាជអាវុធហត្ថដែលចូលរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការឆែកឆេរតាមម៉ោងដែលច្បាប់កំណត់កំណត់ គឺចាប់ពី ម៉ោង ៦ ព្រឹកដល់ក្រោយម៉ោង ១៨ ល្ងាច

---

[99] សូមមើល មាត្រា ៩១ កថាខណ្ឌទី១, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[100] សូមមើល មាត្រា ៤០ កថាខណ្ឌទី២, នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ។

[101] សូមមើល មាត្រា ៤០ កថាខណ្ឌទី៣, នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ។

[102] សូមមើល មាត្រា ១៧ កថាខណ្ឌទី១, នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, អនុម័តដោយមហាសន្និបាទអង្គការសហប្រជាជាតិ នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ។

[103] សូមមើល មាត្រា ១៧ កថាខណ្ឌទី២, នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, អនុម័តដោយមហាសន្និបាទអង្គការសហប្រជាជាតិ នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ។

[104] សូមមើល មាត្រា ២៥៩ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ប្រកាសឲ្យប្រើនាថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។

ដែលនេះ គឺជាម៉ោងដែលច្បាប់បានកំណត់ ។ ប៉ុន្តែការឆែកឆេរពុំចាំបាច់គោរពតាមម៉ោងដែលច្បាប់បានកំណត់នោះទេ បើក្នុងករណីដូចជា ៖

- មានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងកើតឡើង តាមមាត្រា ៨៦ ឬ ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- មានការស្រែកឲ្យជួយពីក្នុងទីកន្លែងដែលត្រូវឆែកឆេរនោះ
- កន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន និង
- ការឆែកឆេរអនុវត្តនៅទីកន្លែងក្នុងពេលម៉ោងបើកចំហរសម្រាប់សាធារណជន ដូចជាកន្លែងពេស្យាចារជាដើម ។

នៅក្នុងការឆែកឆេរ គឺមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុដោយមានបញ្ជាក់ពីរចំណុច គឺ ទី១ ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយមានបញ្ជាក់ពីថ្ងៃ និងម៉ោងនៃការអនុញ្ញាត ហើយទី២ គឺត្រូវមានបញ្ជាក់ពីអត្តសញ្ញាណនៃអ្នកកាន់កាប់ ឬសាក្សីនីមួយៗ ។ ចំពោះការចាប់យកវត្ថុតាង[105] វិញប្រសិនបើមានឃើញមានវត្ថុតាង មន្ត្រីនគរបាលយុត្តិធម៌ត្រូវបង្ហាញជូនអ្នកកាន់កាប់ ឬសាក្សីបន្ទាប់មកមន្ត្រីនគរបាលយុត្តិធម៌ត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ និងចុងក្រោយត្រូវធ្វើជាកំណត់ហេតុស្តីពីការចាប់យកវត្ថុតាង ដោយមានការចុះហត្ថលេខា ឬផ្តិតម្រាមដៃនៃអ្នកកាន់កាប់ ឬសាក្សី ។

ការឆែកឆេរកាន់តែរឹតត្បិតទៀត ប្រសិនបើការឆែកឆេរនោះត្រូវអនុវត្តនៅទីកន្លែងដែលរក្សាការសម្ងាត់ផ្សេងៗ ដូចជា ការសម្ងាត់ផ្នែកវិជ្ជាជីវៈ ។ ដូចនេះ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរទេដែលអាចធ្វើការឆែកឆេរនៅការិយាល័យមេធាវីបាន ដោយមានការចូលរួមពីប្រធានគណៈមេធាវី ឬ ប្រតិភូគណៈមេធាវី ឬមេធាវីសាមី ។ ចំណែកឯ ការឆែកឆេរនៅតាមបណ្តាលអគារសារព័ត៌មាន សហគ្រាសសារព័ត៌មានសរសេរ ឬសារព័ត៌មានសោតទស្សន៍ អាចប្រព្រឹត្តទៅបានចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់តែប៉ុណ្ណោះ ហើយការធ្វើនេះគឺដើម្បីធានាកុំឲ្យមានការប៉ះពាល់ដល់ការប្រកបមុខរបរអ្នកសារព័ត៌មាន និងធ្វើឲ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាន ។

### ៤. ការស្តាប់ចម្លើយ

ការស្តាប់ចម្លើយ គឺជានីតិវិធីមួយដែលត្រូវអនុវត្តដើម្បីឈានដល់ការទទួលព័ត៌មានទាក់ទងនឹងរឿងហេតុ តាមរយៈការកោះហៅឲ្យចូលបង្ហាញខ្លួន ។ ការកោះហៅឲ្យចូលបង្ហាញខ្លួននេះ អាចត្រូវអនុវត្តចំពោះគ្រប់បុគ្គលទាំងឡាយណាដែលអាចផ្តល់ព័ត៌មានទាក់ទងនឹងរឿងហេតុ ដូចជា សាក្សីជាដើម។ មន្ត្រីនគរបាលយុត្តិធម៌អាចអនុវត្តវិធានការបង្ខំ ក្នុងករណីមានការរឹងទទឹងមិនព្រមបំពេញកាតព្វកិច្ចខ្លួនលក្នុងការបង្ហាញ

---

[105] សូមមើល ទំព័រ ៣៨៨, ភូឡាយស៊ុន និង ភូ វួចចេង "វចនានុក្រមច្បាប់ខ្មែរ-អង់គ្លេស", ត្រួតពិនិត្យ និង អធិប្បាយពាក្យច្បាប់ជាភាសាខ្មែរដោយ ហ៊ីង ធិឫទ្ធិ, ត្រួតពិនិត្យ និងផ្តល់យោបល់ដោយ លោក ភូ លីវុឌ្ឍ [...], បោះពុម្ពលើកទី១ ឆ្នាំ ២០១២ ។

ខ្លួនតាមការកោះហៅនេះ ។ ដូចនេះ មន្ត្រីនគរបាលយុត្តិធម៌អាចជូនដំណឹងដល់ព្រះរាជអាជ្ញាដើម្បីចេញបញ្ជាឲ្យបុគ្គលនោះចូលខ្លួនបាន តាមរយៈដីកាបង្គាប់ឲ្យចូលខ្លួន ។ តាមរយៈដីកានេះមន្ត្រីនគរបាលយុត្តិធម៌អាចប្រើប្រាស់កម្លាំងសាធារណៈ ដើម្បីបង្ខំឲ្យបុគ្គលនោះចូលខ្លួនបាន ។

ក្រៅពីការស្តាប់ចម្លើយបុគ្គលដែលអាចផ្តល់ព័ត៌មាន មន្ត្រីនគរបាលយុត្តិធម៌ក៏អាចធ្វើការកោះហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួនតែម្តងដើម្បីធ្វើការស្តាប់ចម្លើយ ចំពោះគ្រប់បុគ្គលណាដែលស្ថិតនៅក្នុងការសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ។ ដូចនេះយើងអាចយល់បានថាការស្តាប់ចម្លើយទាំងពីរខាងលើ គឺមានលក្ខណៈខុសគ្នា ទី១ គឺជាការស្តាប់ចម្លើយនៃបុគ្គលដែលអាចផ្តល់ព័ត៌មាននៃរឿងហេតុ និងទី២ គឺជាការស្តាប់ចម្លើយនៃបុគ្គលដែលត្រូវបានសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ។[106]

ការស្តាប់ចម្លើយនេះ គឺត្រូវមានការធ្វើកំណត់ហេតុមួយ ដោយដកស្រង់នូវសេចក្តីរាយការណ៍របស់បុគ្គលដែលបានផ្តល់ចម្លើយនោះ ។ បន្ទាប់មក មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានឲ្យខ្លាំងៗ ឬឲ្យបុគ្គលដែលផ្តល់ចម្លើយនោះអានដោយខ្លួនឯងនូវខ្លឹមសារនៃកំណត់ហេតុ ដើម្បីឲ្យបុគ្គលដែលផ្តល់ចម្លើយធ្វើការចុះហត្ថលេខា ឬផ្តិតម្រាមដៃលើគ្រប់ទំព័រនៃកំណត់ហេតុ ។ អ្នកបកប្រែអាចត្រូវបានហៅប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកអានកំណត់ហេតុ ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលដែលផ្តល់ចម្លើយនោះក៏នៅមានសិទ្ធិក្នុងការមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃ ហើយក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុអំពីបញ្ហានេះ ។[107]

សូមបញ្ជាក់បន្ថែមផងថា នៅក្នុងនីតិវិធីនៃការស្តាប់ចម្លើយនេះអ្នកបកប្រែ ដែលអញ្ជើញដោយមន្ត្រីនគរបាលយុត្តិធម៌ មិនមែនជាបុគ្គលជ្រើសរើសចេញពីនគរបាល ឬកងរាជអាវុធហត្ថ ឬបុគ្គលទាក់ទិននឹងរឿងហេតុនេះឡើយ ។[108]ចំពោះអ្នកបកប្រែនោះត្រូវស្បថថា និយាយពាក្យពិតស្របតាមជំនឿ ឬសាសនារបស់ខ្លួន ។

### ៥. ការត្រួតពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ការត្រួតពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ជានីតិវិធីមួយដូចការធ្វើកោសលវិច័យដែរ ។ ការត្រួតពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ គឺធ្វើឡើងដោយអ្នកជំនាញ ដែលមានចែងក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ ។ បញ្ជីនេះត្រូវរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ អ្នកជំនាញទាំងនោះត្រូវធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថានឹងស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌ ។[109] ប៉ុន្តែជាក់

[106] សូមមើល មាត្រា ៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[107] សូមមើល មាត្រា៩៣ កថាខណ្ឌទី៥,វាក្យខណ្ឌទី៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ,នស/រកម/០៨០៧/០២៤,ប្រកាសឲ្យប្រើនាថ្ងៃទី១០ខែសីហាឆ្នាំ២០០៧ ។

[108] សូមមើល មាត្រា ៩៣ កថាខណ្ឌទី៣, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[109] សូមមើល មាត្រា ១៦៣ កថាខណ្ឌទី២, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

ស្តែង បញ្ជីនេះមិនទាន់បានបង្កើតនៅឡើយទេ នាពេញបច្ចុប្បន្ន ។

ជាការអនុវត្តជាក់ស្តែង ការត្រួតពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ឬការធ្វើកោសលវិច័យត្រូវបានធ្វើដោយអ្នកជំនាញដែលមិនទាន់ចុះបញ្ជី តាមការពឹងពីមន្ត្រីនគរបាលយុត្តិធម៌ ។ អ្នកជំនាញដែលមិនទាន់ចុះបញ្ជីទាំងនោះ ត្រូវធ្វើសម្បថតាមសាសនា ឬជំនឿរបស់ខ្លួន ថានឹងជួយដោយភក្តីភាពដល់តុលាការ ។[110]

ក្នុងចំណុចនេះដែរអាចបញ្ជាក់បានថា ច្បាប់ព្រហ្មទណ្ឌមិនជឿជាក់ទៅលើការធ្វើសម្បថអ្វីនោះឡើយ ព្រោះខ្លួនជាអ្នកកំណត់ឲ្យមានការពិនិត្យតាមបែបវិទ្យាសាស្ត្រ ដើម្បីបង្ហាញរឿងហេតុពិតប្រាកដ ។ ប៉ុន្តែ ការកំណត់ឲ្យអ្នកជំនាញធ្វើសម្បថ ឬកំណត់ឲ្យសាក្សីធ្វើសម្បថ គឺគ្រាន់តែជាការបន្លាច ឬបំភ័យផ្នែកសតិអារម្មណ៍តែប៉ុណ្ណោះ ។

### ៦. ការឃាត់ខ្លួន និងការបញ្ជូនខ្លួន

#### ក. អំណាចក្នុងការឃាត់ខ្លួន

ការឃាត់ខ្លួន គឺជាវិធានបង្ខិតបង្ខំក្នុងការដកហូតសេរីភាពបុគ្គលណាមួយ ដូចនេះការឃាត់ខ្លួនត្រូវប្រព្រឹត្តឡើង ដោយផ្អែកទៅលើមូលដ្ឋានច្បាប់ណាមួយ។ នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាបានទទួលស្គាល់និងការពារនូវសិទ្ធិសេរីភាពនេះ ដោយបានបញ្ញត្តិថា " ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនណាមួយ អាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមច្បាប់ " ។[111] ដូចគ្នាផងដែរ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សបានកំណត់ថា "គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួនដោយបំពានឡើយ ។[112] ហើយកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏បានចែងដែរថា " ជនគ្រប់រូបមានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន" ។ គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួន តាមអំពើចិត្តបានឡើយ ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងក្នុងច្បាប់ " ។[113] ជាពិសេសក្នុងក្រមព្រហ្មទណ្ឌកម្ពុជាបានបញ្ញត្តិថា "បុគ្គលដែលចាប់ខ្លួន ដែលឃុំឃាំង ឬដែលបង្ខាំងបុគ្គលផ្សេងទៀត ដោយគ្មានបញ្ជាពីអាជ្ញាធរស្របច្បាប់ ឬក្រៅពីករណីដែលច្បាប់អនុញ្ញាតត្រូវផ្តន្ទាទោស [...] "។[114] ដូចនេះ ការឃាត់ខ្លួនបុគ្គលណាមួយ ត្រូវអនុវត្តដោយបំពេញនូវលក្ខខណ្ឌទាំងឡាយដែលច្បាប់បានបញ្ញត្តិ បើពុំដូច្នេះទេ

---

[110] សូមមើល មាត្រា ៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[111] សូមមើល មាត្រា ៣៨ កថាខណ្ឌទី៣, នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ។

[112] សូមមើល មាត្រា ៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ។

[113] សូមមើល មាត្រា ៩ កថាខណ្ឌទី១, នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ។

[114] សូមមើល មាត្រា ២៥៩ កថាខណ្ឌទី១, នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ប្រកាសឲ្យប្រើនាថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។

សិទ្ធិជាមូលដ្ឋាននៃបុគ្គលដែលត្រូវបានគេឃាត់ខ្លួននឹងត្រូវបានបំពាន ព្រោះគ្រប់បុគ្គលត្រូវមានសេរីភាពក្នុងការធ្វើដំណើរទៅវិញទៅមក ។

ដូចនេះ ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់នូវអំណាចឲ្យមន្ត្រីនគរបាលយុត្តិធម៌តែមួយគត់ ដែលអាចធ្វើការឃាត់ខ្លួនក្នុងលក្ខខណ្ឌជាកំហិតមួយ ហើយការឃាត់ខ្លួននេះត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ព្រះរាជអាជ្ញា ។[115] មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនគ្រប់បុគ្គលដែលសង្ស័យថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស ។ ការឃាត់ខ្លួននេះគឺ " ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត "[116] ដែលជាការធានាឲ្យបាននូវការចាប់ខ្លួនជនល្មើសជាដើម ។ ក្រៅពីសិទ្ធិអំណាចក្នុងការឃាត់ខ្លួនជនសង្ស័យ នោះមន្ត្រីនគរបាលយុត្តិធម៌ ក៏អាចឃាត់ខ្លួនគ្រប់បុគ្គលដែលអាចផ្តល់ជាព័ត៌មានអំពីរឿងហេតុសម្រាប់ការបំភ្លឺការពិតផងដែរ តែការឃាត់ខ្លួនបុគ្គលប្រភេទនេះអាចអនុវត្តបាន លុះត្រាតែបានបំពេញនូវក្នុងលក្ខខណ្ឌចំនួន ២ គឺ ៖

- **ទី១** បុគ្គលនោះមិនព្រមផ្តល់ព័ត៌មាន និង
- **ទី២** មន្ត្រីនគរបាលយុត្តិធម៌ទទួលបានការអនុញ្ញាតយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យ ធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។

វិធានដែលទាក់ទងនិងការឃាត់ខ្លួន គឺជាវិធានដែលមានលក្ខណៈដាច់ខាត ព្រោះការមិនគោរពនូវវិធានទាំងនេះនឹងនាំមកការធ្វើមោឃភាពនៃនីតិវិធី ។[117] ក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់សិទ្ធិអំណាចឲ្យមន្ត្រីរាជការ ឬភ្នាក់ងារសាធារណៈក្នុងការឃាត់ខ្លួនឡើយ ។ ដូចនេះមន្ត្រីរាជការ ឬភ្នាក់ងារសាធារណៈមិនអាចអនុវត្តការឃាត់ខ្លួនបានឡើយ តែអាចចាប់ និងនាំខ្លួនជនល្មើសទៅប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។[118]សមត្ថកិច្ចក្នុងការឃាត់ខ្លួន ព្រះរាជអាជ្ញាក៏មិនអាចអនុវត្តជំនួសមន្ត្រីនគរបាលយុត្តិធម៌បានដែរ ទោះជាព្រះរាជអាជ្ញាជាអ្នកប្រើប្រាស់អំណាចឲ្យមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតក៏ដោយ ។[119] មូលហេតុដែលមន្ត្រីរាជការ ឬ ភ្នាក់ងារសាធារណៈ និងព្រះរាជអាជ្ញាគ្មានអំណាចក្នុងការឃាត់ខ្លួននេះ ព្រោះក្នុងការអនុវត្តអំណាចនេះ ក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់បុគ្គលណាផ្សេងអាចអនុវត្តការឃាត់ខ្លួនឡើយក្រៅពីមន្ត្រីនគរបាលយុត្តិធម៌ ។ ផ្ទុយទៅវិញ បុគ្គលគ្រប់រូបមានសិទ្ធិចាប់ខ្លួនជនល្មើស និងនាំខ្លួនជនល្មើសទៅកាន់អង្គភាពនៃមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។

---

[115] សូមមើល មាត្រា ៩៦ កថាខណ្ឌទី២, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[116] សូមមើល មាត្រា ៩៦ កថាខណ្ឌទី១, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[117] សូមមើល មាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[118] សូមមើល មាត្រា ៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[119] សូមមើល មាត្រា ៣៧ កថាខណ្ឌទី២, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញាអំពីការឃាត់ខ្លួនដោយមិនអាចធ្វើការពន្យារពេលដោយចេតនាណាមួយឡើយ ហើយត្រូវបញ្ជូនទៅព្រមគ្នានូវគ្រប់ភស្តុតាងទាំងអស់ ដែលនាំឲ្យមានការចាប់ខ្លួន ។

❖ ការឃាត់ខ្លួនត្រូវបានកំណត់ក្នុងចិរវេលាយ៉ាងជាក់លាក់ ដូចខាងក្រោមនេះ៖

| ជនត្រូវបានឃាត់ខ្លួន | បទឧក្រិត្យ | បទមជ្ឈិម | ការពន្យារពេលនៃការឃាត់ខ្លួន | រយៈពេលយូរបំផុត |
|---|---|---|---|---|
| នីតិជន | ៤៨ ម៉ោង | | បាន ២៤ ម៉ោង | ៧២ ម៉ោង |
| អនីតិជន(ចាប់ពី ១៦ ក្រោម ១៨ឆ្នាំ) | ៤៨ ម៉ោង | ៣៦ ម៉ោង | មិនអាចពន្យាពេល | -៤៨ ម៉ោងសម្រាប់ បទឧក្រិត្យ<br>-៣៦ ម៉ោងសម្រាប់ បទមជ្ឈិម |
| អនីតិជន(ចាប់ពី ១៤ ក្រោម ១៦ឆ្នាំ) | ៣៦ ម៉ោង | ២៤ ម៉ោង | មិនអាចពន្យាពេល | -៣៦ ម៉ោងសម្រាប់ បទឧក្រិត្យ<br>-២៤ ម៉ោងសម្រាប់ បទមជ្ឈិម |

– តារាងនេះត្រូវបានធ្វើឡើងដោយ យោងតាមមាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
– ចិរវេលានៃការឃាត់ខ្លួន ត្រូវគិតចាប់ពីម៉ោង ដែលបុគ្គលត្រូវបានឃាត់ខ្លួន មកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។
– អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវបានឃាត់ខ្លួនឡើយ។
– ការពន្យារពេលធ្វើ៖ ចាំបាច់សម្រាប់ការស៊ើបអង្កេត, មានតម្រុយពិរុទ្ធភាព, ជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ, ដាក់ចូលក្នុងសំណុំរឿង និងមន្ត្រីនគរបាលយុត្តិធម៌ស្នើសុំទៅព្រះរាជអាជ្ញាដើម្បីផ្ទៀងផ្ទាត់មើលមូលកភាព។
– បើមានការឃាត់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងទៅឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬអ្នកទទួលបន្ទុកអនីតិជន តាមគ្រប់មធ្យោបាយ ។

ក្រោយពេលផុតកំណត់ចិរវេលានៃការឃាត់ខ្លួន ព្រះរាជអាជ្ញាមានជម្រើសពីរក្នុងការធ្វើសេចក្តីសម្រេច ទី១ គឺការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនទៅបង្ហាញខ្លួនភ្លាមៗចំពោះខ្លួនឯង ឬ ទី២ ត្រូវធ្វើការដោះលែងឲ្យមានសេរីភាពឡើងវិញ ។[120] ការបង្ហាញខ្លួនចំពោះមុខព្រះរាជអាជ្ញាតាមជម្រើសទី១ នេះត្រូវធ្វើឡើងក្នុងរយៈពេលដ៏ឆាប់បំផុតតាមដែលអាចធ្វើបាន ។ ជាស្ថានភាពជាក់ស្តែងការបញ្ជូន

[120] សូមមើល មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

ខ្លួនអាចត្រូវជួបនឹងឧបសគ្គផ្សេងៗ ដូចជាស្ថានភាពផ្លូវមានការលំបាក ឬមានចម្ងាយឆ្ងាយជាដើម ដូចនេះ ប្រសិនបើពុំអាចនាំខ្លួនបុគ្គលដែលឃាត់ខ្លួននោះក្នុងថ្ងៃតែមួយនៃការសម្រេចរបស់ព្រះរាជអាជ្ញានោះទេ " រយៈពេលបន្ថែមអាច ផ្តល់ឲ្យដោយព្រះរាជអាជ្ញាបាន "។[121] ប្រសិនបើមានការយឺតយ៉ាវ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះមូលហេតុនៃការយឺតយ៉ាវនោះក្នុងកំណត់ហេតុ ។

**ខ.កំណត់ហេតុនៃការឃាត់ខ្លួន**

ដើម្បីធានាដល់ការឃាត់ខ្លួន នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវផ្តល់ព័ត៌មានភ្លាមៗទៅព្រះរាជអាជ្ញា និងត្រូវបញ្ជូនព្រមគ្នានូវគ្រប់ភស្តុតាងដែលជាហេតុនាំឲ្យមានការឃាត់ខ្លួន ។ ក្រៅពីនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវតាក់តែងនូវកំណត់ហេតុមួយទៅតាមលក្ខខណ្ឌមួយចំនួនដែលមានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌដែលមានដូចជា៖[122]

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យឃាត់ខ្លួន
- អត្តសញ្ញាណ និងអាយុនៃបុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃខែឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន
- ការឲ្យដំណឹងអំពីសិទ្ធិរកជំនួយពីមេធាវី
- ឈ្មោះអ្នកបកប្រែ។

បុគ្គលដែលឃាត់ខ្លួនត្រូវអានកំណត់ហេតុនេះ ឬមន្ត្រីនគរបាលយុត្តិធម៌អានឲ្យស្តាប់ បើបុគ្គលដែលឃាត់ខ្លួនមិនចេះអក្សរ ដើម្បីឲ្យបុគ្គលដែលឃាត់ខ្លួននោះចុះហត្ថលេខា ឬផ្តិតម្រាមដៃ តែបើក្នុងករណីគាត់បដិសេធអំពីការចុះហត្ថលេខាឬផ្តិតម្រាមដៃ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសអំពីការបដិសេធនេះ ។

ក្នុងករណីមានការឃាត់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងកំណត់ហេតុនូវបែបបទនៃការផ្តល់ព័ត៌មានទៅព្រះរាជអាជ្ញា និងបែបបទនៃការផ្តល់ដំណឹងទៅឪពុកម្តាយ អ្នកតំណាងស្របច្បាប់ និងបុគ្គលដែលទទួលបន្ទុកអនីតិជន ។ ក្រៅពីនេះ រាល់កិច្ចដែលបានកើតឡើងក្នុងអំឡុងពេលនៃការឃាត់ខ្លួនត្រូវតែចុះក្នុងកំណត់ហេតុទាំងអស់ ដូចជាអំឡុងពេលឃាត់ខ្លួន ការពិនិត្យរបស់គ្រូពេទ្យ ការជួបជាមួយមេធាវី ឬបុគ្គលណាមួយ ការពន្យារពេលនិងឈ្មោះតំណាងអយ្យការដែលអនុញ្ញាតការពន្យារពេលនេះ រយៈពេលសម្រាកពេលស្តាប់ចម្លើយ និង ហេតុការណ៍ផ្សេងៗជាដើម ។

---

[121] សូមមើល មាត្រា ១០៤ កថាខណ្ឌទី២, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[122] សូមមើល មាត្រា ៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

### គ.សិទ្ធិទទួលបានជំនួយក្នុងពេលឃាត់ខ្លួន

នៅក្នុងអំឡុងពេលនៃការឃាត់ខ្លួន បុគ្គលដែលឃាត់ខ្លួនអាចទទួលបាននូវជំនួយពីមេធាវីនិងពីគ្រូពេទ្យ។ នៅក្នុងការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងជាបន្ទាន់ ដោយប្រាប់ពីមូលហេតុនៃការឃាត់ខ្លួនទៅបុគ្គលដែលត្រូវឃាត់ខ្លួននោះ ។ ក្នុងការជូនដំណឹងនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ពីសិទ្ធិរកជំនួយពីមេធាវីក្នុងអំឡុងពេលនៃការឃាត់ខ្លួន ។ បើមានការចាំបាច់ណាមួយនោះមន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែបាន។សិទ្ធិក្នុងការជួបជាមួយមេធាវី អាចអនុវត្តបានក្រោយពីការឃាត់ខ្លួនបានរយៈពេល ២៤ ម៉ោង។ ការធ្វើដូចនេះ ដើម្បីអាចឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការរបស់ខ្លួនជាមុនសិនក្នុងការស្តាប់ចម្លើយរបស់បុគ្គលដែលឃាត់ខ្លួន ។ ក្រោយពីរយៈពេលនេះ បុគ្គលដែលឃាត់ខ្លួនអាចសន្ទនាជាមួយមេធាវី ឬបុគ្គលណាមួយតាមការជ្រើសរើសរបស់ខ្លួន លើកលែងតែបុគ្គលដែលជាប់ទាក់ទិននឹងរឿងក្តី ព្រោះដើម្បីជៀសវាងនូវការរួមគំនិតបង្កផលលំបាកក្នុងកិច្ចស៊ើបអង្កេត ។ ការសន្ទនានេះ អាចធ្វើបានតែរយៈពេល ៣០ នាទី ដោយគោរពលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ ។

ការទទួលបាននូវជំនួយពីគ្រូពេទ្យអាចត្រូវបានធ្វើឡើងតាមរយៈ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌បានគ្រប់ពេលវេលា ។ កម្មវត្ថុនៃការទទួលបានជំនួយនេះគឺដើម្បីផ្ទៀងផ្ទាត់មើលថា " តើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួនសមស្របនឹងការឃាត់ខ្លួនដែរឬទេ "?[123] គ្រូពេទ្យត្រូវបានចេញវិញ្ញាបនបត្របញ្ជាក់សុខភាពដើម្បីភ្ជាប់ក្នុងសំណុំរឿង ហើយឈ្មោះគ្រូពេទ្យ ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការពិនិត្យសុខភាពត្រូវចុះនិទ្ទេស ។ ក្រៅពីនេះដើម្បីធានាដល់ភាពត្រឹមត្រូវនៃការឃាត់ខ្លួនរបស់ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងនៃការឃាត់ខ្លួន ដើម្បីផ្ទៀងផ្ទាត់ពីលក្ខខណ្ឌនៃការឃាត់ខ្លួននេះ ។

### ៧.ការស្តាប់ការសន្ទនាតាមប្រព័ន្ធបច្ចេកវិទ្យា

ការស្តាប់ការសន្ទនាជាលក្ខណៈឯកជនរបស់អ្នកដទៃដោយឯកឯង ហាក់ដូចជាស្តែងនូវរូបភាពនៃការរំលោភបំពានជ្រៀតជ្រែកទៅក្នុងជីវិតឯកជនរបស់អ្នកដទៃ ។ ការស្តាប់ការសន្ទនានេះត្រូវបានទទួលគាំពារការពារពីច្បាប់ ។ យោងទៅតាមរដ្ឋធម្មនុញ្ញបានកំណត់ថា " ការរក្សាសិទ្ធិមិនឲ្យរំលោភបំពានលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទ ត្រូវបានធានា "។[124] ដូចគ្នានេះដែរ យោងតាមកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏បានទទួលស្គាល់ផងដែរនូវការការពារការរំលោភបំពានតាមរយៈស្តាប់ការសន្ទនាតាមទូរស័ព្ទនេះដែរ " ជនណាម្នាក់ត្រូវទទួលរងការជ្រៀតជ្រែក

[123] សូមមើល មាត្រា ៩៩ កថាខណ្ឌទី២, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[124] សូមមើល មាត្រា ៤០ កថាខណ្ឌទី ២, នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ។

តាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន ” ។[125] យោងតាមក្រមព្រហ្មទណ្ឌបានកំណត់ថា " អំពើប្រព្រឹត្ត ដោយគំនិតទុច្ចរិតស្តាប់ ឬ ធ្វើឲ្យប្រឬកប្របល់ការសន្ទនាតាមទូរស័ព្ទ ត្រូវផន្ទាទោសដាក់ពន្ធនាគារពី ១ ខែទៅ ១ ឆ្នាំ [...]" ។[126] យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិថា មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឲ្យ ស្តាប់ និងថតសំលេងការសន្ទនាតាមទូរស័ព្ទឡើយ ហើយក៏គ្មានអំណាចបង្គាប់ឲ្យចាប់ ឬសារតាមអិនធើណែត ។[127] ដូចនេះការស្តាប់ការសន្ទនារបស់អ្នកដទៃត្រូវបានកម្រិតការការពារយ៉ាងរឹតរឹងដោយច្បាប់ព្រហ្មទណ្ឌ ។ ការស្តាប់ការសន្ទនានេះ គឺមានតែអាជ្ញាធរដែលច្បាប់បានប្រគល់សិទ្ធិអំណាចឲ្យទេ ទើបអាចធ្វើការស្តាប់បាន ហើយការស្តាប់ទាំងនោះត្រូវអនុវត្តក្នុងលក្ខខណ្ឌកំណត់ដោយច្បាប់ផងដែរ ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថា ចៅក្រមអាចបង្គាប់ឲ្យមន្ត្រីនគរបាលយុត្តិធម៌អាចថត និងចាប់ការឆ្លើយឆ្លងគ្នាតាមគ្រប់មធ្យោបាយទូរគមនាគមន៍ ។[128] នេះគឺជាការធ្វើ និយតកម្ម[129] នៃការស្តាប់ការសន្ទនាដោយច្បាប់ព្រហ្មទណ្ឌ ដើម្បីធានាដល់ការស្វែងរកការពិតរបស់ចៅក្រមក្នុងនាមជាអំណាចតុលាការដែមជាអំណាចឯករាជ្យ ខុសពីអយ្យការដែលត្រូវគោរពនូវគោលការណ៍ឋានានុក្រម ។ ដូចជា៖ ការស្តាប់ទូរស័ព្ទជាអាទិ៍ ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ (យោងតាមមាត្រា ១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ), ការតាមដាន (យោងតាមមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន), និងការតាមដាន (យោងតាមមាត្រា ៨៨ នៃច្បាប់ស្តីពីការប្រឆាំងនិងភេរវកម្ម) ជាដើម ។

**កថាខណ្ឌទី២៖ ការស៊ើបអង្កេតបឋម**

ការស៊ើបអង្កេតបឋម គឺជានីតិវិធីស៊ើបអង្កេតធម្មតាមួយ ក្នុងការស្វែងរកភស្តុតាងដាក់បន្ទុកដោយពុំត្រូវបានកំណត់ក្នុងរយៈពេលជាក់លាក់ឡើយ ។ ការស៊ើបអង្កេតបឋមនេះ ក៏ពុំត្រូវបានកំណត់និយមន័យដូចការស៊ើបអង្កេតករណីជាក់ស្តែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែរ ។ ការស៊ើបអង្កេតនេះត្រូវបានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា ១១១ ដល់ មាត្រា ១១៨ ។ ដើម្បីសិក្សា និងស្វែងយល់បន្ថែមឲ្យបានកាន់តែច្បាស់អំពីការស៊ើបអង្កេតបឋម យើងត្រូវដឹងជាមុនសិនអំពី ការបើកការស៊ើបអង្កេតបឋម (**១**) និងនីតិវិធីក្នុងការឆែកឆេរ (**២**) និងចុងក្រោយនីតិវិធីក្នុងការបញ្ជាឲ្យចូលខ្លួន (**៣**) ។

---

[125] សូមមើល មាត្រា ១៧ កថាខណ្ឌទី ៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ, អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ។

[126] សូមមើល មាត្រា ៣១៨ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ប្រកាសឲ្យប្រើនាថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។

[127] សូមមើល មាត្រា ១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[128] សូមមើល មាត្រា ១៧១ កថាខណ្ឌទី១, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[129] សូមមើល ទំព័រ ២២១, ភូឡាយស៊ុន និង ភូ វួចចេង "វចនានុក្រមច្បាប់ខ្មែរ-អង់គ្លេស", ត្រួតពិនិត្យ និង អធិប្បាយពាក្យច្បាប់ជាភាសាខ្មែរដោយ ហ៊ីង ធិប្បទ្ធិ, ត្រួតពិនិត្យ និងផ្តល់យោលបល់ដោយ លោក ភូ លីវុឌ្ឍ [...], បោះពុម្ពលើកទី១ ឆ្នាំ ២០១២ ។

**១.ការបើកការស៊ើបអង្កេតបឋម**

ការបើកការស៊ើបអង្កេតបឋម អាចយកមកអនុវត្តបានក្នុងករណីបទល្មើសមិនជាក់ស្តែង ចំណែកក្នុងករណីបទល្មើសជាក់ស្តែងវិញ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបើកការស៊ើបអង្កេតករណីជាក់ស្តែងតាមអំណាចដូចដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។[130] កាលណាបានដឹងឬសង្ស័យថាមានបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា ។[131]

នៅក្នុងការស៊ើបអង្កេតបឋមក៏មានលក្ខណៈស្រដៀងគ្នា ទៅនឹងការស៊ើបអង្កេតជាក់ស្តែងផងដែរ ព្រោះនីតិវិធីមួយចំនួនក្នុងការស៊ើបអង្កេតជាក់ស្តែង ក៏ត្រូវបានយកមកអនុវត្តក្នុងការស៊ើបអង្កេតបឋមផងដែរ ដូចជាកំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ (មាត្រា ៩០), ការត្រួតពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ (មាត្រា ៩៥), ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯង ជាអាទិ៍ (មាត្រា ១០៥), កាបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា (មាត្រា ១០៧) និងនិទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ (មាត្រា ១០៨) ។[132]

**២.ការឆែកឆេរ**

ការឆែកឆេរ និងចាប់យកវត្ថុតាងអាចអនុវត្តបាននៅក្នុងការស៊ើបអង្កេតបឋម ចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិម ។[133] សូមបញ្ជាក់ផងថា ការឆែកឆេរក្នុងការស៊ើបអង្កេតបឋម មានគោលដៅចាប់យកតែវត្ថុតាងដែលមានដូចជាគ្រាប់កាំភ្លើង ឬកាំបិ ជាដើម។ ដោយហេតុថាការឆែកឆេរក្នុងការស៊ើបអង្កេតបឋមមិនបានប្រព្រឹត្តទៅក្រោយ រយៈពេលកើតហេតុថ្មីៗទេ ។ ក្នុងករណីនេះ ភស្តុតាងដែលមានដូចជា ស្លាកស្នាម ឬឈាម ដែលបន្សល់ទុកនៅកន្លែងកើតហេតុអាចនឹងត្រូវបាត់បង់ដោយប្រការណាមួយ។ ផ្ទុយទៅវិញ ការឆែកឆេរក្នុងការស៊ើបអង្កេតករណីជាក់ស្តែងមានគោលដៅប្រមូលយកភស្តុតាងទាំងអស់រួមទាំងការចាប់យកវត្ថុតាង ព្រោះការឆែកឆេរនេះត្រូវអនុវត្តភ្លាមៗក្រោយការប្រព្រឹត្តបទល្មើស ។

ជាគោលការណ៍ ការឆែកឆេរក្នុងការស៊ើបអង្កេតបឋម ត្រូវគោរពធាតុពីរគឺ ការព្រមព្រៀងពិតប្រាកដ និងច្បាស់លាស់ពីបុគ្គលកាន់កាប់ទីកន្លែងហើយការព្រមព្រៀងនោះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។[134]ការយល់ព្រមជាលាយលក្ខណ៍អកក្សរនេះ ត្រូវសរសេរដោយផ្ទាល់ដៃដោយអ្នកកាន់កាប់ទីកន្លែងនោះ ដោយពុំអាចឲ្យបុគ្គល

[130] សូមមើល មាត្រា ៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[131] សូមមើល មាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[132] សូមមើល មាត្រា ១១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[133] សូមមើល មាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[134] សូមមើល មាត្រា ១១៣ កថាខណ្ឌទី២ និងទី៣,នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី១០ខែសីហាឆ្នាំ២០០៧ ។

ណាមួយសរសេរជំនួសបានឡើយ ។ ក្នុងករណីអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងកំណត់ហេតុថា " អ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរហើយយល់ព្រមឲ្យឆែកឆេរ " ។[135] ដូចនេះ ការឆែកឆេរក្នុងករណីការស៊ើបអង្កេតបឋម ពុំសូវផ្តល់អំណាចបង្ខិតបង្ខំដល់មន្ត្រីនគរបាលយុត្តិធម៌ ដូចការឆែកឆេរក្នុងករណីការស៊ើបអង្កេតជាក់ស្តែងឡើយ ។

ផ្ទុយទៅវិញ បើសិនជាមានការបដិសេធ ឬមិនយល់ព្រមឲ្យឆែកឆេរពីអ្នកកាន់កាប់ទីកន្លែង អវត្តមាននៃអ្នកកាន់កាប់ទីកន្លែងនោះ " ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដីអាចចេញដីកាអនុញ្ញាតឲ្យឆែកឆេរតាមការសុំរបស់ព្រះរាជអាជ្ញា " ។[136] ដីកានេះ ជាប្រភេទដីកាសម្រេច ដូចនេះត្រូវតែមានសំអាងហេតុ និងសំអាងច្បាប់ជាលាយលក្ខណ៍អក្សរ ទោះបីជាមិនមានសរសេរក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក៏ដោយ ។[137] ក្រោយការសុំរបស់ព្រះរាជអាជ្ញា នោះព្រះរាជអាជ្ញាត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ ហើយការឆែកឆេរនេះត្រូវប្រព្រឹត្តទៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ដែលចាត់ដោយព្រះរាជអាជ្ញាចំពោះការឆែកឆេរអំឡុងពេលអវត្តមានអ្នកកាន់កាប់ទីកន្លែង ។ សាក្សីទាំងនោះមិនអាចជ្រើសរើសចេញពីនគរបាល ឬកងរាជអាវុធហត្ថ ដែលចូលរួមក្នុងការឆែកឆេរឡើយ ។

ម៉្យាងវិញទៀត ម៉ោងដែលច្បាប់បានបញ្ញត្តិនៃការឆែកឆេរក្នុងករណីស៊ើបអង្កេតបឋមនេះ មិនអាចប្រព្រឹត្តទៅមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ល្ងាចឡើយ ។ ការបិទស្លាកបោះត្រាលើវត្ថុតាងដោយយោងតាមមាត្រា៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្តក្នុងការចាប់យកវត្ថុតាងក្នុងការស៊ើបអង្កេតបឋមដែរ។

**៣.ការបញ្ជាឲ្យចូលខ្លួន**

ការបញ្ជាខ្លួនឲ្យចូលខ្លួនអាចត្រូវបានអនុវត្តចំពោះបុគ្គលគ្រប់រូប ដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ តាមរយៈការកោះហៅរបស់មន្ត្រីនគរបាលយុត្តិធម៌ ។ មន្ត្រីនគរបាលយុត្តិធម៌អាចស្តាប់ចម្លើយបុគ្គលទាំងនោះ និងធ្វើកំណត់ហេតុរាល់ការស្តាប់ចម្លើយរបស់ខ្លួន ។ អ្នកបកប្រែអាចត្រូវបានហៅដោយមន្ត្រីនគរបាលយុត្តិធម៌ បើមានការចាំបាច់ ។ អ្នកបកប្រែមិនអាចជ្រើសរើសចេញពីនគរបាល ឬកងរាជអាវុធហត្ថបានឡើយ ។

គ្រប់បុគ្គលដែលបានទទួលការកោះហៅ ត្រូវតែចូលមកបង្ហាញខ្លួន។ ក្នុងករណីរឹងទទឹងព្រះរាជអាជ្ញាអាចចេញបញ្ជាតាមការជូនដំណឹងរបស់មន្ត្រីនគរបាលយុត្តិធម៌ ហើយការបញ្ជានេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ

[135] សូមមើល មាត្រា ១១៣ កថាខណ្ឌទី៣, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[136] សូមមើល មាត្រា ១១៣ កថាខណ្ឌទី៤, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[137] សូមមើល ការផ្សព្វផ្សាយរបស់សមាគមសាលាជូ ខែ កញ្ញា ឆ្នាំ ២០១៦, ស្តីពី "ការចុះទៅលំនៅឋាន ការឆែកឆេរ និងការចាប់យកវត្ថុតាង" របស់ ចក សម្បត្តិhttps://salatraju.org/post/35 ។

ដោយមានចុះហត្ថលេខា និងបោះត្រាព្រះរាជអាជ្ញា ដើម្បីបញ្ជាក់អំពីឆន្ទៈក្នុងការអនុញ្ញាត ។ ដូចនេះ ការបញ្ជាឲ្យចូលខ្លួនលើកនេះអនុញ្ញាតឲ្យមន្ត្រីនគបាលយុត្តិធម៌ប្រើប្រាស់កម្លាំងនគរបាលសាធារណៈ ដើម្បីបង្ខំឲ្យមានការបង្ហាញខ្លួនបុគ្គលដែលបានកោះហៅនោះ ។

## ផ្នែកទី២៖ អយ្យការក្នុងដំណើរការនៃការជំនុំជម្រះ

សម្រាប់ចំណុចនេះ យើងត្រូវសិក្សាអំពីតួនាទី និងការងារបច្ចេកទេស របស់តំណាងអយ្យការ ក្នុងដំណាក់កាលជំនុំជម្រះ ។ លើសពីនេះ អយ្យការមិនមែនត្រឹមតែជាតួអង្គសំខាន់ក្នុងការធ្វើបណ្តឹងអាជ្ញាទេ គឺនៅពេលសវនាការក៏ត្រូវមានវត្តមានផងដែរ ក្នុងនាមជាតួអង្គតំណាងឲ្យផលប្រយោជន៍សង្គម ។

### កថាខណ្ឌទី១៖ នីតិវិធីមុនពេលកិច្ចពិភាក្សាដេញដោល

នីតិវិធីមុនពេលកិច្ចពិភាក្សាដេញដោល គឺតុលាការនិងត្រូវបើកការជំនុំជម្រះតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ឬដីកាសម្រេច របស់ចៅក្រមស៊ើបសួរឲ្យបញ្ជូនទៅជំនុំជម្រះ ។ ហេតុដូចនេះហើយ នៅរាល់មុនពេលសវនាការ ព្រះរាជអាជ្ញាមានតួនាទីជួយសម្រួលដល់ការបង្ហាញខ្លួនរបស់ជនជាប់ចោទ ភាគីដែលពាក់ព័ន្ធ ព្រមទាំងត្រូវបំពេញលក្ខណៈសម្បត្តិរបស់ខ្លួនផងដែរ ។

❖ **ចំណុចទី១** ៖ នៅក្នុងនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ជាការបង្ហាញខ្លួនរបស់ជនជាប់ចោទនៅមុខតុលាការ ។ ហេតុនេះហើយ ព្រះរាជអាជ្ញាត្រូវ ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឲ្យខ្លួន
- ឲ្យដំណឹងដល់ជននោះ អំពីរឿងហេតុដែលចោទប្រកាន់ និងឈ្មោះបទល្មើស
- ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីអំពីការបង្គាប់ឲ្យចូលខ្លួនភ្លាម ។

ក្រៅពីនេះ ព្រះរាជអាជ្ញាប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងពាក់មេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

❖ **ចំណុចទី២** ៖ ទាក់ទងទៅនឹងបច្ចេកទេសរបស់តំណាងអយ្យការ ក្នុងតំណាក់កាលមុនពេលសវនាការ ។ ជាក់ស្តែងក្នុងការអនុវត្តនីតិវិធី ព្រះរាជអាជ្ញាត្រូវបានកំណត់ឲ្យអនុវត្តកិច្ចការមួយចំនួន ដូចជារៀបចំឯកសារសំណុំរឿង ដើម្បីធ្វើការពិភាក្សាដេញដោលនៅចំពោះមុខតុលាការ ។ ការរៀបចំនេះក៏ត្រូវមានឯកសារភស្តុតាងដាក់បន្ទុករបស់ខ្លួនដែលជាមូលដ្ឋាននៃការចោទប្រកាន់ ឬការពារដល់ការចោទប្រកាន់របស់ខ្លួន ។ លើសពីនេះទៅទៀត ព្រះរាជអាជ្ញាត្រូវគោរពផងដែរនូវពេលវេលាកំណត់សវនាការ និងគោរពលើឯកសណ្ឋាន ជាដើម ។

### កថាខណ្ឌទី២. អំឡុងពេល និងការបញ្ចប់កិច្ចពិភាក្សាដេញដោល

នៅពេលដែលកិច្ចពិភាក្សាដេញដោល ព្រះរាជអាជ្ញាអាចត្រូវបានអនុញ្ញាតឲ្យលើកសំណួរដល់ជនចាប់ចោទ គ្រប់ការលើកសំណួរទាំងអស់ ត្រូវតែទទួលបានការអនុញ្ញាតពីប្រធានសវនាការជាមុនសិន ។ សិទ្ធិអំណាច ព្រះរាជអាជ្ញាក៏អាចធ្វើចំពោះការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញផងដែរ ។

ម្យ៉ាងវិញទៀត ព្រះរាជអាជ្ញាអាចជំទាស់នឹងការស្តាប់សាក្សី ដែលខ្លួនយល់ឃើញថា ចម្លើយនេះគ្មានប្រយោជន៍អ្វីដល់ការសំដែងឲ្យឃើញការពិត ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្តថា តើត្រូវស្តាប់ ឬមិនស្តាប់ចម្លើយសាក្សីនេះ ។ ចំណែកឯ ការបញ្ចប់កិច្ចពិភាក្សាដេញដោល ព្រះរាជអាជ្ញា មានសិទ្ធិក្នុងការនិយាយស្តី ឬក៏ធ្វើការសន្និដ្ឋានសរុប ឲ្យចោទប្រកាន់ ឬផ្តន្ទាទោសទៅលើជនជាប់ចោទ ទៅតាមសិទ្ធិអំណាច និងការយល់ឃើញថាសមស្របទៅនឹងផលប្រយោជន៍ល្អនៃយុត្តិធម៌ ។

## ផ្នែកទី៣. អយ្យការក្នុងដំណើរការនៃការអនុវត្តទោស

នៅពេលដែលសេចក្តីសម្រេច ឬសាលក្រមរបស់តុលាការ បានចូលជាស្ថាពរហើយនោះតំណាងអយ្យការត្រូវតែធ្វើការអនុវត្តទោស ។ ចំពោះការអនុវត្តទោសនេះទៀតសោត ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាអាចសុំកងកម្លាំងសាធារណៈ ដើម្បីធានារ៉ាប់រងក្នុងការអនុវត្តទោស ។[138]

នៅក្នុងករណីដែលភាគីណាមួយដែលមិនសុខចិត្តនឹងសេចក្តីសម្រេច ឬសាលក្រមមិនទាន់ចូលជាស្ថាពរ អាចធ្វើការប្តឹងឧទ្ធរណ៍បាន ។ បុគ្គលដែលអាចប្តឹងឧទ្ធរណ៍បានមានដូចខាងក្រោម ៖

- ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ពិរុទ្ធជន
- ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ។[139]

រយៈពេលនៃការប្តឹងឧទ្ធរណ៍នេះ ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចធ្វើការប្តឹងក្នុងរយៈពេល ១ ខែ គិតចាប់ពីពេលប្រកាសសាលក្រម ចំពោះសាលក្រមចាត់ទុកថាចំពោះមុខ ផ្តើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីជាការឲ្យដំណឹងនោះតាមវិធីណាក៏ដោយ ។[140] ចំណែកឯរយៈពេល

---

[138] សូមមើល មាត្រា ៤៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[139] សូមមើល មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[140] សូមមើល មាត្រា ៣៨២ កថាខណ្ឌទី១, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

នៃការប្តឹង ឧទ្ធរណ៍ របស់ព្រះរាជអាជ្ញាត្រូវតែធ្វើឡើងក្នុងរយៈពេល ១ ខែ និងការប្តឹងឧទ្ធរណ៍របស់អង្គព្រះរាជអាជ្ញា ត្រូវតែធ្វើឡើងក្នុងរយៈពេល ៣ ខែ ដោយគិតចាប់ពីពេលប្រកាសសាលក្រម ។ ប៉ុន្តែប្រសិនបើភាគីណាមួយមិនបានធ្វើការប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១ ខែទេនោះ នាំឲ្យសាលក្រមរបស់តុលាការនោះនឹងចូលជាស្ថាពរ ហើយព្រះរាជអាជ្ញានឹងធ្វើការអនុវត្តទោសចំពោះទណ្ឌិត តាមសាលក្រមស្ថាពរ ។

ចំពោះនីតិវិធីនៃការអនុវត្តទោសនេះ ត្រូវបានបែងចែកជាបីគឺ វិធានទាក់ទងនឹងការឃុំខ្លួន (**កថាខណ្ឌទី១**) ការដោះលែងដោយមានលក្ខខណ្ឌ (**កថាខណ្ឌទី ២**) និងការបង្ខំរូបកាយ (**កថាខណ្ឌទី ៣**)។

### កថាខណ្ឌទី១៖ វិធានទាក់ទងនឹងការឃុំខ្លួន

ជាគោលការណ៍ការឃុំខ្លួនបុគ្គលណាម្នាក់ ដាច់ខាតត្រូវតែមានលិខិតដែលចេញដោយអាជ្ញាធរតុលាការ ។ មានន័យថា មុននឹងទទួលយកជនជាប់ឃុំខ្លួនចូលពន្ធនាគារ ប្រធានពន្ធនាគា ឬ មន្ត្រីពន្ធនាគារដែលទទួលបានការចាត់តាំង ត្រូវត្រួតពិនិត្យអត្តសញ្ញាណរបស់ជនជាប់ឃុំឲ្យបានត្រឹមត្រូវ តាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរ តុលាការ ។[141] ប្រសិនបើ " ភ្នាក់ងាររដ្ឋបាលពន្ធនាគារណាដែលទទួល និងឃុំខ្លួនបុគ្គលណាដែលគ្មានលិខិតចេញដោយអាជ្ញាធរតុលាការទេនោះ ត្រូវជាប់ពិរុទ្ធពីបទបង្ខាំងមនុស្សដោយខុសច្បាប់ "។[142] ផ្អែកតាមមាត្រា ៥០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ញត្តិអំពីថិរវេលានៃការដាក់ពន្ធនាគារដែរ ដោយទោសដាក់ពន្ធនាគារក្នុង ១ ថ្ងៃ មានថិរវេលា ២៤ ម៉ោង ទោសដាក់ពន្ធនាគារក្នុង ១ខែ មានថិរវេលា ៣០ ថ្ងៃ និងទោសដាក់ពន្ធនាគារលើសពី ១ខែ ត្រូវគិតតាមលេខរៀងនៃថ្ងៃក្នុងខែទី១ ទៅលេខរៀងនៃថ្ងៃក្នុងខែមួយទៀត ។ ចំណែកឯ ទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ ត្រូវបានដោះលែងនៅក្នុងចន្លោះពីម៉ោង ៦ព្រឹក ដល់ម៉ោង ១៨ ល្ងាច ។

#### ១. ការគ្រប់គ្រងពន្ធនាគារ

សម្រាប់គោលដៅក្នុងការគ្រប់គ្រងជនជាប់ឃុំ គឺជាការអប់រំកែប្រែ និងស្តារនីតិសម្បទារបស់ជនជាប់ឃុំដែលជាស្នូលនៃក្របខណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារ ។[143] ចំណែកឯការដាក់វិន័យដល់ជនជាប់ឃុំ ត្រូវបានធ្វើឡើងក្នុងកម្រិតអប្បបមាដែលចាំបាច់ ដើម្បីធ្វើការធានាសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់

[141] សូមមើល ទំព័រទី ៧០ "នៃសន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ", ដែលរៀបចំដោយ គណៈកម្មការបណណ្ឌិតសភាទទួលបន្ទុក អនុម័តពាក្យច្បាប់, បោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី, បោះពុម្ពលើកទី១ ឆ្នាំ ២០១១ ។

[142] សូមមើល មាត្រា ៥០២ កថាខណ្ឌទី២, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[143] សូមមើល ៤២ នៃច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១, ប្រកាសឲ្យប្រើនាថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ។

ប៉ុណ្ណោះ ។ ប្រធានពន្ធនាគារត្រូវទទួលខុសត្រូវក្នុងការអនុវត្តនីតិវិធី និងបទបញ្ជាផ្ទៃក្នុងនៅក្នុងពន្ធនាគារ ។ " ពន្ធនាគារនីមួយៗ ត្រូវមានបញ្ជីជនជាប់ឃុំដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ជនជាប់ឃុំ ហើយចុះក្នុងទិដ្ឋាការដោយតំណាងអយ្យការនៅគ្រប់ទំព័រ " ។[144] ចំពោះជនជាប់ឃុំ ជាស្ត្រី និងជនជាប់ឃុំជាអនីតិជន ត្រូវមានបញ្ជីដោយឡែក ហើយត្រូវយកចិត្តទុកដាក់ជាពិសេសដល់ការគ្រប់គ្រងជនជាប់ឃុំទាំងពីប្រភេទនេះ ។ យ៉ាងណាមិញ ចំពោះការត្រួតពិនិត្យបញ្ជីជនជាប់ឃុំ ត្រូវបានធ្វើឡើងដោយតំណាងអង្គការអយ្យការ និងត្រូវជូនទៅចៅក្រមដើម្បីពិនិត្យមើលតាមការស្នើសុំ និងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលបានបំពេញភារកិច្ចតាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។[14] លើសពីនេះទៅទៀត ការបញ្ជូនទណ្ឌិតពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀត ប្រធានពន្ធនាគារត្រូវតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងជូនដំណឹងភ្លាមៗ ឬយ៉ាងយូរបំផុត ៣ថ្ងៃ ទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងសមត្ថកិច្ចខាងដែនដីទទួល ។ ដូចគ្នាដែរនឹងការផ្ទេរជនជាប់ឃុំក្រៅពីទណ្ឌិតពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀត ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីទទួល ឬអង្គព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចកំពុងចាត់ការរឿងក្តី ។ ក្នុងករណីចាំបាច់នៃការផ្ទេរជនជាប់ឃុំក្រៅពី ទណ្ឌិត ពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀត អង្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាអាចចេញដីកាបង្គាប់ឲ្យផ្ទេរបានតាមតម្រូវការនៃនីតិវិធី ។[146]

**២.ការធ្វើអធិការកិច្ចពន្ធនាគារ**

ចំណែកឯការធ្វើអធិការកិច្ចពន្ធនាគារវិញនោះ ដោយអនុលោមតាមមាត្រា ៥០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរត្រូវធ្វើអធិការកិច្ចលើពន្ធនាគារជាប្រចាំ ។ យន្តការបង្ការថ្នាក់ជាតិ ត្រូវបានអនុញ្ញាតឲ្យធ្វើទស្សនកិច្ចតាមពន្ធនាគារនានា គ្រប់ពេលវេលា និងធ្វើការសម្ភាសន៍ជាសម្ងាត់ជាមួយនឹងជនជាប់ឃុំដើម្បីអាចត្រួតពិនិត្យមើលលក្ខខណ្ឌនៃការឃុំខ្លួន និងការប្រព្រឹត្តចំពោះជនជាប់ឃុំ ផ្តល់អនុសាសន៍កែលម្អ សំដៅបង្ការទារុណកម្ម អំពើឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក។[147]

---

[144] សូមមើល ២១ នៃច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១, ប្រកាសឲ្យប្រើនៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ។

[145] សូមមើល ២២ នៃច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១, ប្រកាសឲ្យប្រើនៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ។

[146] សូមមើល ៦២ កថាខណ្ឌទី៣, នៃច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១, ប្រកាសឲ្យប្រើនៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ។

[147] សូមមើល ៥៤ កថាខណ្ឌទី២, នៃច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១, ប្រកាសឲ្យប្រើនៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ។

ការចុះត្រួតពិនិត្យពន្ធនាគារ ជនដែលអាចចូលក្នុងពន្ធនាគារបានមានដូចជា ៖[148]

- តំណាងព្រះមហាក្សត្រ
- សមាជិករដ្ឋសភាជាតិ
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ជនទាំងឡាយ ដែលអនុញ្ញាតពីក្រសួងមហាផ្ទៃ
- ចៅក្រម ឬព្រះរាជអាជ្ញា
- អភិបាលខេត្ត-ក្រុង
- ជនណាម្នាក់ ឬអង្គការណាមួយ ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីប្រធានពន្ធនាគារ ។

**កថាខណ្ឌទី២៖ ការដោះលែងដោយមានលក្ខខណ្ឌ**

ជាក់ស្តែង មាត្រា ៧៩ នៃច្បាប់ស្តីពីពន្ធនាគារ បានចែងថា "គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបានបង្ហាញឲ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ មិនមានសម្បទាដែលអាចបញ្ជូនខ្លួនទៅក្នុងសង្គមវិញបាន ។ ត្រង់ចំណុចនេះក៏បានបញ្ជាក់ឲ្យយើងឃើញថា ការដោះលែងទណ្ឌិតនេះអាចប្រព្រឹត្តទៅបានលុះត្រាតែទណ្ឌិតដែលត្រូវទទួលទោសនោះ មានការកែប្រែចិត្តគំនិត អត្តចរិតក៏ដូចជាគំនិតមារយាទ ដែលរាងចោលលែងប្រព្រឹត្តបទល្មើសផ្សេងៗតទៅទៀត ។ ម៉្យាងវិញទៀត បន្ទាប់ពីប្រធានពន្ធនាគារទទួលបានលិខិតសម្រេចពីអាជ្ញាធរតុលាការរួចមក នោះប្រធានពន្ធនាគារត្រូវតែធ្វើការដោះលែងជនដែលជាប់ ។ ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបានបញ្ចប់នៅថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកផ្សេងៗទៀត ដែលត្រូវបានកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ត្រូវតែធ្វើការដោះលែងឲ្យមានសេរីភាពវិញ នៅមុខថ្ងៃដែលឈប់សម្រាកនោះ ។[149]

អ្នកទោសដែលត្រូវបានដោះលែងជាបន្ទាន់ ក្នុងកាលៈទេសៈដូចតទៅ ៖

- នៅពេលផុតកំណត់ទោស ។
- នៅពេលអនុញ្ញាតឲ្យដាក់ប្រាក់ធានាឲ្យនៅក្រៅឃុំ ដោះលែងដោយមានលក្ខខណ្ឌដោះលែងបណ្តោះអាសន្ន ។

[148] សូមមើល ប្រការ ៤ ចំណុចទី២៦ (ក), នៃប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ, លេខ ២១៧ របស់ក្រសួងមហាផ្ទៃ ។

[149] សូមមើល ៨០ នៃច្បាប់ស្តីពីពន្ធនាគារ, នស/រកម/១២១១/០២១, ប្រកាសឲ្យប្រើនាថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ។

- នៅពេលលើកលែងការចោទប្រកាន់ ។
- នៅពេលនិរទេសខ្លួនទៅឲ្យអាជ្ញាធរមានសមត្ថកិច្ច ដោយមានការវិនិច្ឆ័យសម្រេចត្រឹមត្រូវតាមច្បាប់ តុលាការមានសមត្ថកិច្ច ។
- នៅពេលលើកលែងទោសដោយព្រះមហាក្សត្រ ចំពោះទោសដែលនៅសេសសល់ ។[150]

**១.លក្ខខណ្ឌផ្សេងៗក្នុងការដោះលែងទណ្ឌិត**

ដូចដែលបានរៀបរាប់ពីខាងលើរួចមកហើយថា ការដោះលែងទណ្ឌិតអាចធ្វើទៅបានលុះត្រាតែបានគោរពទៅតាមលក្ខខណ្ឌមួយចំនួន ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ទើបទណ្ឌិតអាចត្រូវបានដោះលែងឲ្យមានសេរីភាពវិញ ការដោះលែងទណ្ឌិតដោយមានលក្ខខណ្ឌនេះត្រូវបានបែងចែកជា ២ លក្ខខណ្ឌដែលមានដូចខាងក្រោមនេះ ៖

➢ **លក្ខខណ្ឌទាក់ទងទៅនឹងគំនិតមារយាទ ៖** សំដៅលើគ្រប់ទណ្ឌិតដែលត្រូវបានទទួលទោសណាមួយ ឬច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនេះបានបង្ហាញឲ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំខ្លួន មិនមែនសំដៅលើសម្បទាដែលមាំមួនអាចបញ្ជូនខ្លួនទៅក្នុងសង្គមវិញបាន ។[151]

➢ **លក្ខខណ្ឌទាក់ទងទៅនឹងថិរវេលានៃទោសដែលត្រូវបានទទួលរួចហើយ ៖** សម្រាប់កល្ខខណ្ឌនេះ ការដោះលែងអាចត្រូវបានផ្តល់ជូនឲ្យដល់ទណ្ឌិត ដែលទទួលរងទោសជាប់ពន្ធនាគារ ៖

- ចំនួនពាក់កណ្តាលនៃទោស ប្រសិនបើទោសនេះអាចតិចជាង ឬស្មើ ១ ឆ្នាំ
- ចំនួនពីរភាគបីនៃទោសក្នុងករណីផ្សេងទៀត ។

រីឯទណ្ឌិតដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត អាចទទួលការដោះលែងដោយមានលក្ខខណ្ឌប្រសិនបើ ទណ្ឌិតបានទទួលទោសជាប់ពន្ធនាគារយ៉ាងតិចបំផុត ២០ ឆ្នាំរួចមកហើយ ។[152]

អាស្រ័យហេតុនេះហើយ អាជ្ញាធរមានសមត្ថកិច្ច សម្រាប់ផ្តល់ការដោះលែងដោយមានលក្ខខណ្ឌទាំង ២ ខាង លើនេះត្រូវផ្តល់ដោយអនុប្រធានតុលាការជាន់ដំបូងនៃទីតាំងឃុំខ្លួន បន្ទាប់ពីប្រធានតុលាការសម្រេចក្រោយពីបានទទួលយោបល់ពីគណៈកម្មការជាតិដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌ ។

---

[150] សូមមើល ប្រការ ៤ ចំណុចទី ៤ (ក), នៃប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ, លេខ ២១៧ របស់ក្រសួងមហាផ្ទៃ ។

[151] សូមមើល មាត្រា ៥១២ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខ សីហា ឆ្នាំ ២០០៧ ។

[152] សូមមើល មាត្រា ៥១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

## ២. សេចក្តីសម្រេចទាក់ទងទៅនឹងការដោះលែងដោយមានលក្ខខណ្ឌ

ជាទូទៅបន្ទាប់ពីទទួលបានយោបល់ពីគណៈកម្មការជាតិរួចមក " ប្រធានតុលាការសម្រេចតាមដីកាដោយមានសំអាងហេតុ ហើយសេចក្តីសម្រេចរបស់ប្រធានតុលាការនេះដែរ អាចត្រូវបានតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បានក្នុងរយៈពេល ៥ ថ្ងៃ ។ ចំពោះបណ្តឹងតវ៉ា គឺមានតែព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញានៃតុលាការសាមីតែប៉ុណ្ណោះដែលអាចធ្វើបណ្តឹងតវ៉ានេះបាន ។ នៅពេលដែលសេចក្តីសម្រេចរបស់ប្រធានតុលាការជាន់ដំបូង បង្គាប់ឲ្យដោះលែងដោយមានលក្ខខណ្ឌ នាំឲ្យសេចក្តីសម្រេចនោះគ្មានអានុភាពអនុវត្តទេនៅក្នុងរយៈពេល ៥ ថ្ងៃបន្ទាប់ពីចេញសេចក្តីសម្រេច ។ ប្រសិនបើមានការតវ៉ា សេចក្តីសម្រេចនោះគ្មានអានុភាពអនុវត្តទេ រហូតដល់មានដីកាបស់ប្រធានសាលាឧទ្ធរណ៍" ។[153] ត្រង់នេះសបញ្ជាក់ឲ្យឃើញថា ប្រសិនបើគ្មានបណ្តឹងតវ៉ាទេនោះសេចក្តីសម្រេចមានអានុភាពចាប់ពីពេលផុតរយៈពេល ៥ថ្ងៃនៃការប្តឹងតវ៉ា ប៉ុន្តករណីមានការប្តឹងតវ៉ាទៅប្រធានសាលាឧទ្ធរណ៍ សេចក្តីសម្រេចនេះគ្មានអានុភាពទៀតឡើយ ហើយសេចក្តីសម្រេចនឹងមានអានុភាពវិញនៅពេលមានដីកាបស់ប្រធានសាលាឧទ្ធរណ៍ ។

គួរកត់សម្គាល់ផងដែរថា ក្រោយពីបានទទួលយោបល់ពីគណៈកម្មការជាតិរួចមក ប្រធានតុលាការត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ ទើបព្រះរាជអាជ្ញាចេញដីកាមួយប្រភេទដែលគេបានហៅថា " ដីកាដោះលែងទណ្ឌិត" ។ នៅក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញានៃតុលាការសាមីអាចបង្គាប់ឲ្យចាប់ខ្លួនទណ្ឌិតដែលបានដោះលែងនោះបាន ដោយព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់ប្រធានតុលាការជាន់ដំបូងភ្លាម ។[154]

### កថាខណ្ឌទី៣៖ ការបង្ខំដល់រូបកាយ

ការបង្ខំរូបកាយ ត្រូវអនុវត្តដោយពេញលេញលក្ខណៈច្បាប់ ទៅលើបុគ្គលដែលផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ដែលមិនបង់ ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង និងជម្ងឺចិត្ត ដែលត្រូវបង់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។ ពោលគឺ ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធីទេ អង្គភាពរតនាគារជូនដំណឹងដល់ព្រះរាជអាជ្ញានៃតុលាការអមសាលាដំបូង ។ ក្រៅពីនេះទៀត " ព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយដល់ទណ្ឌិត ដែលរយៈពេលនេះមិនអាចតិចជាង ១០ថ្ងៃទេ ដើម្បីបង់ប្រាក់នោះហើយត្រូវឲ្យដំណឹងថាប្រសិនបើខ្លួនមិនបង់ទេនោះ សាមីខ្លួនត្រូវបង្ខំដល់រូបកាយ ។ ការឲ្យជាដំណឹងនេះត្រូវតែធ្វើកំណត់ហេតុស្តីពីការឲ្យដំណឹង ហើយការឲ្យដំណឹងនេះទៀតសោត អាចធ្វើទៅបានតាមរយៈ ៖

[153] សូមមើល មាត្រា ៥១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[154] សូមមើល មាត្រា ៥១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

- ដោយផ្ទាល់មាត់ ឬ
- តាមផ្លូវរដ្ឋបាល ឬ
- តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។[155]

ប្រសិនបើទណ្ឌិតមិនបានបង់ប្រាក់តាមរយៈពេលដែលបានកំណត់ទេនោះ ព្រះរាជអាជ្ញាចេញបញ្ជាឲ្យបង្ខំ និឲ្យឃុំខ្លួន ដោយមានចុះហត្ថលេខាដោយព្រះរាជអាជ្ញាផ្ទាល់ និងមានបោះត្រាផងដែរ ។ " ព្រះរាជអាជ្ញាអាចបង្អង់សេចក្តីសម្រេចនេះបាន ដោយមូលហេតុមនុស្សធម៌ជាអាទិ៍ ដូចជាស្ថាប័ននៃសុខភាពរបស់ទណ្ឌិត " ។[156] នៅការ ក្នុងចុះអន្តរាគមន៍បែបនេះ ព្រះរាជអាជ្ញាអាចសុំឲ្យកម្លាំងសាធារណៈ ចាប់ និងឃុំខ្លួនទណ្ឌិត ។

**១.ថិរវេលានៃការបង្ខំដល់រូបកាយ**

យោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌថិរវេលានៃការបង្ខំដល់រូបកាយត្រូវបានកំណត់ដូចខាងក្រោមនេះ ៖

- ១០ (ដប) ថ្ងៃ កាលណាទឹកប្រាក់ដែលមិនបោះបង់នោះមានចំនួនមិនលើសពី ២៥០.០០០ (ពីរសែនប្រាំម៉ឺន ) រៀល ។
- ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើទឹកប្រាក់នេះចំនួន ២៥០.០០១ (ពីរសែនប្រាំម៉ឺនមួយ ) រៀលដល់ ៥០០.០០០ (ប្រាំសែន) រៀល ។
- ១ (មួយ) ខែ ប្រសិនបើទឹកប្រាក់នេះចំនួន ៥០០.០០១ (ប្រាំសែនមួយ) រៀលដល់ ១.០០០.០០០ (មួយលាន) រៀល ។
- ២ (ពីរ) ខែ ប្រសិនបើទឹកប្រាក់នេះចំនួន ១.០០០.០០១ (មួយលានមួយ) រៀលដល់ ២.៥០០.០០០ (ពីរលានប្រាំសែន )រៀល ។
- ៣ (បី) ខែ ប្រសិនបើទឹកប្រាក់នេះចំនួន ២.៥០០.០០១ (ពីរលានប្រាំសែនមួយ) រៀលដល់ ៥.០០០.០០០ (ប្រាំលាន) រៀល ។
- ៦ (ប្រាំមួយ) ខែ ប្រសិនបើទឹកប្រាក់នេះចំនួន ៥.០០០.០០១ (ប្រាំលានមួយ) រៀលដល់
- ១០.០០០.០០០ (ដបលាន) រៀល ។
- ១ (មួយ) ឆ្នាំ ប្រសិនបើទឹកប្រាក់នេះចំនួន ១០.០០០.០០១ (ដបលានមួយ) រៀលដល់ ២០.៥០០.០០០ (ម្ភៃលានប្រាំសែន) រៀល ។

[155] សូមមើល មាត្រា ៥២៥ កថាខណ្ឌទី៣, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[156] សូមមើល មាត្រា ៥២៦ វាក្យខណ្ឌទី២, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

- ១៨ (ដប់ប្រាំបី) ខែ ប្រសិនបើទឹកប្រាក់នេះចំនួន ២០.៥០០.០០១ (ម្ភៃលានប្រាំសែនមួយ) រៀលដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ។
- ២(ពីរ)ឆ្នាំប្រសិនបើទឹកប្រាក់នេះមានចំនួនលើសពី ៥០.០០០.០០០ (ហាសិបលាន)រៀល។[157]

កាលណាការបង្ខំរូបកាយ ធានាការប្រមូលតណទេយ្យច្រើននោះ ថិរវេលានៃការបង្ខំនេះ ត្រូវកំណត់ដោយគិតគូរតាមចំនួនសរុបនៃទណ្ឌកម្ម ។

**២.ការរួចផុតពីការបង្ខំដល់រូបកាយ**

ជាការពិតណាស់ ការបង្ខំដល់រូបកាយ មិនអាចធ្វើទៅលើទណ្ឌិតដែលជាអនីតិជននៅពេលប្រព្រឹត្តបទល្មើសទៅលើស្ត្រីដែលមានអាយុចាប់ពី ៦៥ ឆ្នាំឡើងទៅ និងទៅលើបុរសអាយុចាប់ពី ៧០ឆ្នាំឡើងទៅបានឡើយ ។ មួយវិញទៀតនោះ ការបង្ខំដល់រូបកាយមិនអាចធ្វើបានព្រមជាមួយគ្នាទៅលើប្តី ប្រពន្ធបានទេ ទោះបីជាការបង្ខំនោះធ្វើឡើងដើម្បីប្រមូលធនទណ្ឌផ្សេងគ្នាក៏ដោយ ។[158]

[157] សូមមើល មាត្រា ៥៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[158] សូមមើល មាត្រា ៥៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ប្រកាសឲ្យប្រើនាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

ក្រោយពេលដែលយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវកន្លងមកនេះ យើងអាចយល់បានថា យន្តការនីតិវិធីអយ្យការត្រូវបានបង្កើតឡើង ដើម្បីឲ្យតំណាងអយ្យការដែលជាភាគីរដ្ឋត្រូវដើរតួក្នុងការប្រមូលភស្តុតាងដាក់បន្ទុក និងធ្វើបណ្តឹងក្នុងនាមជាអ្នកតំណាងឲ្យរដ្ឋ ។ អយ្យការជាតួអង្គយ៉ាងសំខាន់ក្នុងការដំណើរការរឿងក្តីព្រហ្មទណ្ឌដែលត្រូវមាននៅគ្រប់ទីកន្លែងនៃរដ្ឋបាលរាជធានី និង ខេត្ត នៃព្រះរាជាចក្រកម្ពុជា ។ អយ្យការមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើបណ្តឹងអាជ្ញា និងជាអ្នកថ្លឹងថ្លែង ត្រួតពិនិត្យបណ្តឹងនេះក្នុងនាមជាអ្នកតំណាងឲ្យផលប្រយោជន៍សាធារណៈ ។

ព្រះរាជអាជ្ញាមានសិទ្ធិធំធេងក្នុងការចូលរួមកិច្ចនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌ តាំងតែពីពេលចាប់ផ្តើមរហូតដល់ការអនុវត្តទោស ។ ក្រសួងដែលមានយុត្តិធម៌ជាសេនាធិការ បានព្យាយាមក្នុងការជ្រើសរើសបេក្ខភាពចូលរួមប្រឡងប្រជែងដើម្បីធ្វើការដកស្រង់នូវទំពាំងស្នងឬស្សីគ្រប់រូបណាដែលមាននូវប្រាជ្ញា ស្មារតី និង សម្ថភាព ផ្នែកច្បាប់ដែលមានគុណភាពខ្ពស់សម្រាប់ចូលរួមបំរើការក្នុងវិស័យយុត្តិធម៌នេះ ។ ដោយសារតែតម្រូវការធនធានចៅក្រម ព្រះរាជអាជ្ញា មានការកើនឡើងខ្លាំងបានជា រាជបណ្ឌិតវិជ្ជាជីវៈតុលាការបានរៀបចំឲ្យមានការប្រឡងប្រជែងជារៀងរាល់ឆ្នាំក្នុងគោលបំណងបំពេញនូវតម្រូវការរបស់សង្គម និង ផ្នែកយុត្តិធម៌ ។ នៅពេលដែលមានការប្រឡងប្រជែងចេញនូវលទ្ធផលមកឃើញថាជាប់ជាស្ថាពរហើយ និស្សិតនោះត្រូវបានតម្រូវឲ្យសិក្សានៅសាលារាជបណ្ឌិតវិជ្ជាជីវៈតុលាការក្នុងរយៈពេល១ឆ្នាំ សម្រាប់ការអនុវត្តជាក់ស្តែងនៅតាមអង្គការអយ្យការនានាក្នុងដែនដីនៃព្រះរាជាចក្រ កម្ពុជា ។

ជាក់ស្តែងគ្រប់ ចៅក្រម-ព្រះរាជអាជ្ញាគ្រប់រូបត្រូវតែឆ្លងកាត់នូវការបណ្តុះបណ្តាលយ៉ាងយកចិត្តទុកដាក់ហើយដាច់ខាតបុគ្គលនោះត្រូវតែជាធនធានដែលមានចំណេះដឹងខ្ពស់ ផ្នែកនីតិសាស្ត្រ រួមជាមួយនឹងផ្នែកវិទ្យាសាស្ត្រសង្គម ដើម្បីធានាដល់ការអនុវត្តប្រកបដោយយុត្តិធម៌ ភាពត្រឹមត្រូវ និងមាននូវប្រសិទ្ធិភាពយ៉ាងច្បាស់លាស់ និង ប្រកបដោយសេចក្តីថ្លៃថ្នូ បើមិនដូចនេះទេអាចនឹងមាននូវកំហុសខុសឆ្គងក្នុងការសម្រេចអ្វីមួយក្នុងការអនុត្តនីតិវិធីដោយមិនបានស្វែងយល់ឲ្យបានត្រឹមត្រូវនិងច្បាស់លាស់ ។

សរុបមកយើងខ្ញុំយល់ឃើញថា អង្គការអយ្យការ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការអនុវត្តនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលជាតួអង្គក្នុងការស្វែងរកនូវយុត្តិធម៌ក្នុងការកាពារផលប្រយោជន៍សាធារណៈ ដល់ជនគ្រប់គ្រប់ស្រទាប់វណ្ណៈ មិនថាជននោះជាអ្នកមានទ្រព្យសម្បត្តិ ឬក្រីក្រឡើយ សុទ្ធតែទទួលបាននៅភាពយុត្តិធម៌ ។ មិនត្រឹមតែប៉ុណ្ណោះក៏សបញ្ជាក់ឲ្យឃើញថាឆន្ទៈក្នុងការបំពេញវិជ្ជាជីវៈត្រូវតែ ស្វែងយល់ឲ្យច្បាស់និងប្រកាន់ភ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ ព្យាយាមសិក្សាបន្ថែមឲ្យបានគ្រប់ពេលវេលា ការសិក្សាស្រាវជ្រាវគ្មានទីបញ្ចប់នោះទេ ត្រូវប្រកាន់ភ្ជាប់នូវមនសិការរបស់ខ្លួន បំពេញកាតព្វកិច្ចឲ្យបានល្អ ត្រូវតែជាមនុស្សដែលមានទំនួលខុសត្រូវឲ្យបានខ្ពស់។

# ឯកសារយោង

## ១.លិខិតបទដ្ឋានគតិយុត្ត

### ក.រដ្ឋធម្មនុញ្ញ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ១៩៩៣ ។

### ខ.សន្ធិសញ្ញាអន្តរជាតិ

១. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ ។

២. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ។

៣. អនុសញ្ញាក្រុងវីយ៉េនស្តីពីទំនាក់ទំនងការទូត អនុម័តដោយសន្និសិទអង្គការសហប្រជាជាតិចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៦១ ស្តីពីការប្រាស្រ័យទាក់ទងការទូត និង អភ័យឯកសិទ្ធិការទូត ។

៤. គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី ៨ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ១៩៩០ , ចំណុចទី១៣ ស្តីពីការបង្ការបទឧក្រិដ្ឋនិងការគ្រប់គ្រងជនល្មើស ។

### គ. ក្រម

១. ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧ ប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ ។

២. ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ២០០៩ ប្រកាសឲ្យប្រើក្រមព្រហ្មទណ្ឌ ។

៣. ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ក្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី ។

### ឃ. ច្បាប់

១. ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

២. ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ។

៣. ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ។

៤. ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធធនាគារ ។

៥. ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះនៅដល់ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំក្រសួងយុត្តិធម៌ ។

៦. ព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៨ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងនិងភេរវកម្ម ។

៧. ព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

៨. ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥ ប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

**ខ. បទបញ្ញា**

១. ព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

២. ព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៥៨ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការផ្ទេររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

៣. អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ របស់រាជរដ្ឋាភិបាល កម្ពុជាស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌។

៤. ប្រកាសលេខ ២១៧ អនក្រ. ចុះថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ១៩៩៨ របស់ក្រសួងមហាផ្ទៃស្តីពីការគ្រប់គ្រងពន្ធនាគារ។

**២).ឯកសារជាសៀវភៅ និង អត្ថបទ**

**ក).សៀវភៅមេរៀន**

១. ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អង្គ វង្ស វឌ្ឍនា,មគ្គុទ្ទេសក៍ ស្តីពីនីតិវិធីព្រហ្មទណ្ឌខ្មែរ(ការស៊ើបអង្កេត និងការស៊ើបសួរត្រៀម),ឆ្នាំ២០០៥។

២. លោកសាស្ត្រាចារ្យ ហ៊ាង ឡេង,មេរៀននីតិព្រហ្មទណ្ឌទូទៅ សម្រាប់ឆ្នាំទី២។

៣. លោកសាស្ត្រាចារ្យ ឆឹង ស៊ីនៀង,មេរៀនសិទ្ធិមនុស្ស សម្រាប់ឆ្នាំទី៣,ឆ្នាំ២០១៥។

៤. សហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ និង រាជបណ្ឌិតវិជ្ជាជីវតុលាការ,មេរៀននីតិវិធីព្រហ្មទណ្ឌ,ឆ្នាំ២០០៧។

៥. លោក កុយ នាម និង ឡុងបញ្ញាវុឌ្ឍ,អង្គការអយ្យការ(ប្រវត្តិនិងការសិក្សាប្រៀបធៀប),ភ្នំពេញ,

បោះពុម្ពលើកទី១,ឆ្នាំ២០០៦។

៦. អនុប្រធានសាលាឧទ្ធរណ៍ លោក សេង ស៊ីវត្ថា,នីតិវិធីព្រហ្មទណ្ឌខ្មែរសម្រាប់ថ្នាក់ឧត្តមសិក្សា។

៧. លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,ឆ្នាំ២០១២។

៨. លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត (មេរៀននីតិវិធីព្រហ្មទណ្ឌ),ឆ្នាំសិក្សា២០១៣-២០១៤។

៩. កញ្ញា បេអាទ្រី បាលីវេ[...] សេចក្តីផ្តើមនៃនីតិកម្ពុជា,ឆ្នាំ២០០៥។

១០. នាយកក្រឡាបញ្ជីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោក ជួន សុរាសី,នីតិវិធីសង្ខេបរដ្ឋប្បវេណី និង ព្រហ្មទណ្ឌ,បោះពុម្ពលើកទី១ ខែមេសា ឆ្នាំ២០០៩។

**ខ.ឯកសារជាអត្ថបទ**

១. លោក ផុន វណ្ណា, «ការតម្កល់រឿងទុកឥតចាត់ការ»,ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, http://salatraju.com/index.php/post?p=33 ។

២. លោក ចក សម្បត្តិ,«បទល្មើសជាក់ស្តែងក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា»,ការផ្សព្វផ្សាយរបស់សមាគមសាលាត្រា, http://salatraju.com/index.php/post?p=162 ។

៣. លោក ចក សម្បត្តិ,«ការចុះទៅលំនៅឋាន ការឆែកឆេរ និង ការចាប់យកវត្ថុតាង»,ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, http://salatraju.com/index.php/post?p=162 ។

៤. Ministe`re de la Justice ,«The French Legal System»,ខែវិច្ឆិកា ឆ្នាំ២០១២។

**៣.វចនានុក្រម និង សន្ទានុក្រម**

**ក.វចនានុក្រម**

១. សម្តេចសង្ឃរាជ ជួនណាត ,វចនានុក្រមខ្មែរ,បោះផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ,ភ្នំពេញ,ឆ្នាំ១៩៦៧។

២. លោក ភូ ឡាយស៊ុន និង លោក ភូ រួចចេង,វចនានុក្រមច្បាប់ខ្មែរ-អង់គ្លេស,បោះពុម្ពលើកទី១,ឆ្នាំ២០១២។

**ខ.សន្ទានុក្រម**

១. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សុខ អាន , សន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ, បោះពុម្ពផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី, បោះពុម្ពលើក ទី១, ឆ្នាំ២០១១ ។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
ឧបសម្ព័ន្ធទី២ ៖ ដីកាតម្កល់រឿងទុកឥតចាត់ការ
ឧបសម្ព័ន្ធទី៣ ៖ ដីកាសន្និដ្ឋានស្ថាពរ
ឧបសម្ព័ន្ធទី៤ ៖ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់
ឧបសម្ព័ន្ធទី៥ ៖ ដីកាកោះហៅជនជាប់ចោទឲ្យចូលសវនាការ
ឧបសម្ព័ន្ធទី៦ ៖ ដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឲ្យចូលសវនាការ
ឧបសម្ព័ន្ធទី៧ ៖ លិខិតអញ្ជើញមេធាវី
ឧបសម្ព័ន្ធទី៨ ៖ ដីកាកោះហៅសាក្សីឲ្យចូលសវនាការ

**ឧបសម្ព័ន្ធទី១**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ..... អក

ចុះថ្ងៃទី ... ខែ... ឆ្នាំ ២០២២

លេខ: ....... ដកសស

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

**យើង** ............ **តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល**

- បានឃើញ របាយការណ៍សរុបលេខ.... របក ចុះថ្ងៃទី ... ខែមីនា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលក្រុងតាខ្មៅ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ... អក ចុះថ្ងៃទី ... ខែមីនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**យល់ឃើញថា** មានតម្រុយសន្ទត់បានលើះ

ឈ្មោះ ... ភេទប្រុស អាយុ ... ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ កើតឆ្នាំ ...ទីកន្លែងកំណើតភូមិ.... ឃុំ... ស្រុក... ខេត្ត... ទីលំនៅបច្ចុប្បន្ននៅភូមិ.... ឃុំ... ស្រុក... ខេត្ត... មុខរបរ ...កម្រិតវប្បធម៌ ថ្នាក់ទី.. កាន់សាសនា ព្រះពុទ្ធ ឪពុកឈ្មោះ ...(ស្លាប់) ម្ដាយឈ្មោះ ...(រស់) ប្រពន្ធឈ្មោះ ...មានកូន ០១ នាក់ ជានីតិជន ទោសពីមុន..។

**បានប្រព្រឹត្តដូចតទៅ**

កាលពីថ្ងៃទី .. ខែ... ឆ្នាំ២០២២ វេលាម៉ោង ១៩ និង ៣០ នាទី ចំណុចមុខរោងចក្រខេមបូ ស្ថិតក្នុងភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល ...........................................................

អំពើរបស់ឈ្មោះ ..... ភេទប្រុស អាយុ .... ឆ្នាំ(កើតឆ្នាំ ១៩៨៨) ជាបទៈ .....ប្រព្រឹត្តនៅចំណុចមុខរោងចក្រខេមបូ ស្ថិតក្នុងភូមិ... សង្កាត់.... ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ ២០២២ **បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសមាត្រា .... នៃក្រមព្រហ្មទណ្ឌ។**

**បានឃើញមាត្រា៤៤ និងមាត្រា១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ**

**សម្រេច**

**បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖**

– ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើ ៖

ឈ្មោះ ..... ភេទប្រុស អាយុ .... ឆ្នាំ(កើតឆ្នាំ ១៩៨៨) ពីបទ៖ .....ប្រព្រឹត្តនៅចំណុចមុខរោងចក្រខេមបូ ស្ថិតក្នុងភូមិ... សង្កាត់.... ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ ២០២២ **បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសមាត្រា .... នៃក្រមព្រហ្មទណ្ឌ។**

- ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ៖
- ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នលើ៖

ឈ្មោះ ...ភេទប្រុស អាយុ .... ឆ្នាំ(កើតឆ្នាំ ១៩៨៨) ដើម្បីបញ្ចប់បទល្មើស និងដើម្បីធានារក្សាជននេះជូនតុលាការតាមនីតិវិធីច្បាប់។

ថ្ងៃ............. ខែ............ឆ្នាំ......... ព.ស ២៥៦៥

ធ្វើនៅកណ្តាល,ថ្ងៃទី...... ខែ........ឆ្នាំ ២០២២

**តំណាងអយ្យការ**

ឧបសម្ព័ន្ធទី២

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកណ្ដាល

# ដីកាតម្កល់រឿងទុកឥតចាត់ការ

លេខ .......ដកមច

**យើង.... តំណាងអយ្យការអមសាលាដំបូង ខេត្តកណ្ដាល**

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ.. អ.ក ចុះថ្ងៃទី... ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូង ខេត្តកណ្ដាល និង សំណុំលិខិតភ្ជាប់ជាមួយព្រមទាំងវត្ថុតាងនានា។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**យល់ឃើញថា៖**

១.អវត្តមានបទល្មើស

១.១ អវត្តមានបទល្មើស

២.ធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់

២.១ ធាតុផ្សំ នៃបទល្មើសមិនគ្រប់គ្រាន់

៣.មូលហេតុគតិយុត្ត

៣.១ ការដកពាក្យបណ្ដឹង
៣.២ ការលើកលែងជាទូរទៅ
៣.៣ មរណភាពជនល្មើស
៣.៤ ផុតអាជ្ញាយុកាល
៣.៥ និរាករណ៍ នៃច្បាប់ព្រហ្មទណ្ឌ
៣.៦ អាជ្ញាអស់ជំនុំ
៣.៧ ការសម្របសម្រួលជាមួយរដ្ឋ
៣.៨ ការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្របសម្រួល
៣.៩ អភ័យឯកសិទ្ធិ
៣.១០ អនិយ័តភាព នៃនីតិវិធី
៣.១១ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស

៤. ការចោទប្រកាន់មិនផ្ដល់ប្រយោជន៍

៤.១ ការស្វែងរកមិនបានផល

៤.២ ការបោះបង់ពាក្យបណ្ដឹងរបស់ដើមបណ្ដឹង
៤.៣ ស្ថានភាព វិបល្លាសស្មារតីដែលបន្តយនូវការដឹងខុសត្រូវ
៤.៤ ការខកខានរបស់ដើមបណ្ដឹង
៤.៥ ការកប្បកិរិយារបស់ជនរងគ្រោះ
៤.៦ ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស
៤.៧ និយ័តកម្មដោយឯកឯង
៤.៨ ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

៥.១ ការជួសជុលការខូចខាតដោយ/ដល់អនីតិជន
៥.២ សន្ធានកម្ម
៥.៣ អធិបញ្ញាផ្ដល់ការព្យាបាល
៥.៤ ជនរងគ្រោះ/ដើមបណ្ដឹងបោះបង់បណ្ដឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា
៥.៥ និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា
៥.៦ ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន
៥.៧ ការកំណត់ទិសដៅចំពោះរចនាសម្ព័ន្ធនៃសុខភាព នៃសង្គម ឬវិជ្ជាជីវៈ
៥.៨ ការសម្រុះសម្រួលព្រហ្មទណ្ឌ

៦. នីតិវិធីជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗទៀត

៦.១ ការចោទប្រកាន់ ឬទណ្ឌកម្មផ្សេងទៀតមិនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

៧.១ ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

៨.១ ការផ្ដល់ជំនួយការអប់រំជំនួសការចោទប្រកាន់

## **យល់ឃើញៈ**

កាលពីថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ១៤និង០០ នាទី ស្ថិតនៅភូមិ.. សង្កាត... ក្រុងតាខ្មៅ ខេត្តកណ្ដាល ...

## **បានឃើញៈ**

- ពាក្យបណ្ដឹងចុះថ្ងៃទី២៨ខែឧសភា ឆ្នាំ ២០២១ របស់ឈ្មោះ ...។
- របាយការណ៍សរុបចុះថ្ងៃទី .... ខែធ្នូ ឆ្នាំ២០២១ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល។
- ដីកាអមចុះថ្ងៃទី ... ខែ.. ឆ្នាំ២០២១ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល។
- កំណត់ហេតុស្ដាប់ការបំភ្លឺដើមបណ្ដឹងឈ្មោះ ...ចុះថ្ងៃទី២៨ខែឧសភា ឆ្នាំ២០២១ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល។

- កំណត់ហេតុស្តាប់ការចុងបណ្តឹងឈ្មោះ ...ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០២១ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល។
- កំណត់ហេតុស្តាប់ការបំភ្លឺចុងបណ្តឹងឈ្មោះ ...ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល។

## យល់ឃើញថា៖

- ផ្អែកតាមការពិនិត្យចម្លើយបំភ្លឺរបស់ដើមបណ្តឹងឈ្មោះ ..និងតាមឯកសារ ពាក់ព័ន្ធនានាក្នុងសំណុំរឿង
- តាមការបំភ្លឺរបស់ឈ្មោះ ... បានឆ្លើយថា៖
- ទំនាក់ទំនងគតិយុត្តនៃអង្គហេតុខាងលើនេះកើតចេញពី **ការមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា** ដែលវិវាទនេះមានចរិតលក្ខណៈជាវិវាទផ្នែករដ្ឋប្បវេណីសុទ្ធសាធ។ ត្រង់ចំណុចនេះហើយតំណាងអយ្យការយល់ឃើញថាស្ថាប័នអយ្យការពុំមានសមត្ថកិច្ចពិនិត្យអង្គហេតុនេះឡើយ គប្បីទុកសិទ្ធិឱ្យភាគី ប្តឹងទៅសាលាជម្រះក្តីដែលមានសមត្ថកិច្ចដើម្បីដោះស្រាយវិវាទរបស់គូរភាគី។
- រាល់ទឡ្ហីករណ៍ដែលបានលើកឡើងខាងលើនេះ បានបញ្ជាក់ឱ្យឃើញថាអង្គហេតុដែលប្តឹងមកនេះ ពុំមានចរិតលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ ដែលអាចឲ្យតំណាងអយ្យការ ធ្វើការចោទប្រកាន់ បានឡើយ ហេតុនេះគប្បីតម្កល់សំណុំរឿងព្រហ្មទណ្ឌនេះទុកឥតចាត់ការចាប់ពីពេលនេះតទៅ។
- តំណាងអយ្យការពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់។

## ហេតុដូច្នេះសម្រេច

- តម្កល់សំណុំរឿងព្រហ្មទណ្ឌ**លេខ** ... អ.ក ចុះថ្ងៃទី .. ខែ... ឆ្នាំ**២០២២** របស់អយ្យការអមសាលាដំបូងខេត្តកណ្តាលទុកឥតចាត់ការតទៅ។

ថ្ងៃ............ ខែ..........ឆ្នាំ............ ព.ស.២៥៦៦

ធ្វើនៅកណ្តាល, ថ្ងៃទី.... ខែ.... ឆ្នាំ២០២២

**តំណាងអយ្យការ**

ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ ... អ.ក
ចុះថ្ងៃទី ... ខែ ....ឆ្នាំ...
លេខ ... .. ដកសព

# ដីកាសន្និដ្ឋានស្ថាពរ

**យើង ....... តំណាងអយ្យការអមសាលាដំបូង ខេត្តកណ្តាល**

- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ .... ដកសស ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ .... សស ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល។
- បានឃើញ ដីកាបញ្ជូនព័ត៌មានលេខ ....ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។
- បានឃើញ ដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យលេខ .... ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**យល់ឃើញថា៖**

១. ឈ្មោះ ....ភេទ.... អាយុ ....ឆ្នាំ ជនជាតិ ខ្មែរ កើតនៅភូមិទួលកំរៀង ឃុំថ្មី ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិទួលកំរៀង ឃុំថ្មី ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មុខរបរ លក់ត្រីកម្រិតវប្បធម៌ ថ្នាក់ទី ០៣ កាន់ សាសនា ព្រះពុទ្ធ ឪពុកឈ្មោះ ធូ ជិន (ស្លាប់) ម្តាយឈ្មោះ អាយ រឿន (ស្លាប់) ជានីតិជន ទោសពីមុនគ្មាន។ **(ក្រៅឃុំ)**

**ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖** .....ប្រព្រឹត្តនៅ.... ឃុំ... ស្រុក.... ខេត្តកណ្តាល កាលពីថ្ងៃទី .. ខែ... ឆ្នាំ២០.. បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាម**មាត្រា ... ក្រមព្រហ្មទណ្ឌ ។**

**ឃើញថា៖** កាលពីថ្ងៃទី .... ខែ... ឆ្នាំ២០.. វេលាម៉ោង..... និង ....នាទី នៅចំណុច...... ឃុំ........ ស្រុក....................................... ខេត្តកណ្តាល .......................................

**ឃើញថា៖ ដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌**

- បានឃើញ..................................................................................................................
- បានឃើញ..................................................................................................................
- បានឃើញ..................................................................................................................

**ឃើញថា៖ ដំណាក់កាលស៊ើបអង្កេតរបស់តំណាងអយ្យការ**

- បានឃើញ.........................................................................................................................
- បានឃើញ.........................................................................................................................
- បានឃើញ.........................................................................................................................

**ឃើញថា៖ ជំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ**

- បានឃើញ........................................................................................................................
- បានឃើញ.........................................................................................................................
- បានឃើញ...........................................................................................................................

## យល់ឃើញថា៖

.........................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

## ហេតុដូច្នេះសម្រេច

**ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេច៖**

១.បញ្ជូនជនជាប់ចោទឈ្មោះ ......ភេទ.... កើតឆ្នាំ.... ពីបទល្មើស..............ប្រព្រឹត្តនៅភូមិ... ឃុំ.... ស្រុក............ ខេត្តកណ្តាល បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា... **នៃក្រមព្រហ្មទណ្ឌ។**

២.បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ .... អ.ក ចុះថ្ងៃទី .... ខែ..... ឆ្នាំ..... ទៅលោកចៅក្រមស៊ើបសួរ ដើម្បីចាត់ការតាមនីតិវិធី។

ថ្ងៃ............. ខែ..........ឆ្នាំ........ ព.ស.២៥៦៦

ធ្វើនៅកណ្តាល, ថ្ងៃទី.... ខែ.... ឆ្នាំ២០២២

**តំណាងអយ្យការ**

ឧបសម្ព័ន្ធទី៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តកណ្ដាល

លេខ ......... ដកជរផ

# ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

**យើង ........ តំណាងអយ្យការអមសាលាដំបូង ខេត្តកណ្ដាល។**

- បានឃើញមាត្រា ៤៣, មាត្រា ៤៦, មាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

- បានឃើញ របាយការណ៍សរុបលេខ **២២១ របក** ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០២២ របស់អធិការដ្ឋាននគរបាលក្រុងតាខ្មៅ។

- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ **៦៩៥** អ.ក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

១. ឈ្មោះ ....ភេទ.... អាយុ ....ឆ្នាំ ជនជាតិ ខ្មែរ កើតនៅភូមិទួលកំរៀង ឃុំថ្មី ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិទួលកំរៀង ឃុំថ្មី ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល មុខរបរ លក់ត្រី កម្រិតវប្បធម៌ ថ្នាក់ទី ០៣ កាន់ សាសនា ព្រះពុទ្ធ ឪពុកឈ្មោះ ជូ ជិន (ស្លាប់) ម្ដាយឈ្មោះ អាយ រឿន (ស្លាប់) ជានីតិជនទោសពីមុនគ្មាន។ (**ក្រៅឃុំ**)

**បានប្រព្រឹត្តអំពើដូចតទៅ៖**

កាលពីថ្ងៃទី.....ខែ.......... ឆ្នាំ២០២២ វេលាម៉ោង ១៦ និង ១០ នាទី ស្ថិតនៅចំណុចផ្លូវ ភូមិ... សង្កាត់... ក្រុង.... ខេត្តកណ្ដាល

**យល់ឃើញថា៖**

- រឿងក្ដីនេះជារឿងព្រហ្មទណ្ឌ ដែលត្រូវបានចោទប្រកាន់ពី បទមជ្ឈឹម ជនត្រូវចោទមាន សាវតាជាតិគ្រប់គ្រាន់ សំណុំរឿងមានលក្ខណៈគ្រប់គ្រាន់ដែលបង្ហាញឲ្យឃើញឈ្មោះ ....ភេទប្រុស អាយុ ... ឆ្នាំ បានប្រព្រឹត្តបទល្មើស៖ ..................ដែលជា បទមជ្ឈឹម ដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិ**មាត្រា ... នៃ...** ហើយសំណុំរឿងនេះមានលក្ខណៈគ្រប់គ្រាន់អាចធ្វើការជំនុំជម្រះបាន។

- កាលពីថ្ងៃទី.... ខែ.... ឆ្នាំ២០២២ វេលាម៉ោង ១៦ និង ១០ នាទី ស្ថិតនៅចំណុច ភូមិ...សង្កាត់.... ក្រុង.... ឈ្មោះ ....ភេទប្រុស អាយុ ....ឆ្នាំ ពិតជាបានប្រព្រឹត្ត......... ខាងលើពិតប្រាកដមែន។

- អំពើរបស់ឈ្មោះ... ភេទ.... អាយុ.....ឆ្នាំ ខាងលើជាបទល្មើស៖ .......... ដែលជា បទមជ្ឈឹម ដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិ**មាត្រា ..... នៃ........**។

- មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ ......ភេទ.... អាយុ.....ឆ្នាំ ខាងលើពីបទល្មើស៖ .........ដែលជា បទមជ្ឈិម ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិ**មាត្រា .... នៃ**......។

**ហេតុដូច្នេះសម្រេច**

បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ .... **អក ចុះថ្ងៃទី.... ខែ..... ឆ្នាំ២០២២** ដែលមានជនត្រូវចោទ៖

ឈ្មោះ .....ភេទប្រុស អាយុ ២១ឆ្នាំ ទៅសាលាដំបូងខេត្តកណ្តាល ដើម្បី **ជំនុំជម្រះ** ពីបទ៖ .....ដែលជា បទមជ្ឈិម ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិ**មាត្រា .... នៃ**......។

ថ្ងៃ..............ខែ.............. ឆ្នាំ............ ព.ស.២៥៦៦

ធ្វើនៅកណ្តាល, ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី៥**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តកណ្ដាល**

# ដីកាកោះហៅជនជាប់ចោទឲ្យចូលសវនាការ

លេខ:..............................

**យើង.... តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល**

- បានឃើញ មាត្រា **៤៦៥** នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ .... អ.ក ចុះថ្ងៃទី .... ខែ.... ឆ្នាំ២០២១ របស់អយ្យការអម សាលាដំបូងខេត្តកណ្ដាល។
- បានឃើញ ដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ.... ដកសដជរ ចុះថ្ងៃទី .... ខែ.... ឆ្នាំ២០.. របស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកណ្ដាល។

បង្គាប់ឲ្យឈ្មោះ ............. ភេទ.... អាយុ.... ឆ្នាំ.... ជនជាតិខ្មែរ **ជាជនជាប់ចោទ** ទីលំនៅបច្ចុប្បន្នភូមិ...... ឃុំ........ ស្រុក...... ខេត្តកណ្ដាល។

ដែលជាប់ចោទពីបទ ៖ .............................. ប្រព្រឹត្តនៅ ភូមិ..... ឃុំ..... ស្រុកខ្សាច់..... ខេត្តកណ្ដាល កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០១៤ តាមបញ្ញត្តិ**មាត្រា** ..............**នៃ**................ ។

ឲ្យចូលមកកាន់សាលាដំបូងខេត្តកណ្ដាល **នៅថ្ងៃទី ... ខែ ....ឆ្នាំ២០... វេលាម៉ោង.. និង ០០ នាទីព្រឹក នៅសាលសវនាការ ...** ជាកំហិត ដើម្បីធ្វើការជំនុំជម្រះជាសាធារណៈ ។

**សមាសភាពជំនុំជម្រះ**

| | |
|---|---|
| ១.លោក ........................ | ជាចៅក្រមជំនុំជម្រះ |
| ២.លោក ........................ | ជាតំណាងអយ្យការ |
| ៣.លោក ........................ | ជាក្រឡាបញ្ជីសវនាការ |

សាមីខ្លួនត្រូវចូលខ្លួនតាមដីកាកោះឲ្យបានទាន់ពេលវេលា ដោយយកលិខិតផ្សេងៗដែលទាក់ទងនឹងសំណុំរឿង ខាងលើមកជាមួយផងប្រសិនបើមាន។

ថ្ងៃ...................ខែ........... ឆ្នាំ ........ព.ស.២៥៦៦

ធ្វើនៅកណ្ដាល, ថ្ងៃទី .... ខែ......... ឆ្នាំ២០២២

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តកណ្តាល**

លេខ:..............................

# <u>ដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឲ្យចូលសវនា</u>

**យើង** ....... **តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល**

- បានឃើញ មាត្រា **៤៧៥** នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ... អ.ក ចុះថ្ងៃទី ... ខែ... ឆ្នាំ.... របស់អយ្យការអម សាលាដំបូងខេត្តកណ្តាល។

- បានឃើញ ដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ .... ដកសដជរ ចុះថ្ងៃទី....... ខែ......... ឆ្នាំ២០.. របស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកណ្តាល សម្រេចដាក់ជនជាប់ចោទឈ្មោះ .......... ភេទ.... អាយុ ទៅ**ជំនុំជម្រះ** ពីបទ .................................ប្រព្រឹត្តនៅភូមិ..............ឃុំ.............. ស្រុក............. ខេត្តកណ្តាល កាលពីថ្ងៃទី ....ខែ.....ឆ្នាំ... តាមបញ្ញត្តិ**មាត្រា** ........**នៃ**.......... ។

អញ្ជើញឈ្មោះ ............. ភេទប្រុស អាយុ..... ឆ្នាំ ជនជាតិ ខ្មែរ **ជា ដើមបណ្តឹងរដ្ឋប្បវេណី** ទីលំនៅបច្ចុប្បន្ន ភូមិ.........ឃុំ.........ស្រុក............ ខេត្ត..........។

ឲ្យចូលមកកាន់សាលាដំបូងខេត្តកណ្តាល <u>**នៅថ្ងៃទី ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ០៩ និង ០០នាទីព្រឹក នៅសាលស**</u>ជាកំហិត ដើម្បីធ្វើការជំនុំជម្រះជាសាធារណៈ ។

ឲ្យចូលមកកាន់សាលាដំបូងខេត្តកណ្តាល <u>**នៅថ្ងៃទី ... ខែ ....ឆ្នាំ២០... វេលាម៉ោង.. និង ០០ នាទីព្រឹក នៅសាលសវនាការ ...**</u> ជាកំហិត ដើម្បីធ្វើការជំនុំជម្រះជាសាធារណៈ ។

**សមាសភាពជំនុំជម្រះ**

១.លោក ........................ ជាចៅក្រមជំនុំជម្រះ

២.លោក ........................ ជាតំណាងអយ្យការ

៣.លោក ........................ ជាក្រឡាបញ្ជីសវនាការ

សាមីខ្លួនត្រូវចូលខ្លួនតាមដីកាកោះឲ្យបានទាន់ពេលវេលា ដោយយកលិខិតផ្សេងៗដែលទាក់ទងនឹងសំណុំរឿង ខាងលើមកជាមួយផងប្រសិនបើមាន។

ថ្ងៃ.................ខែ........... ឆ្នាំ ........ព.ស.២៥៦៦

ធ្វើនៅកណ្តាល, ថ្ងៃទី .... ខែ......... ឆ្នាំ២០២២

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី៧**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តកណ្ដាល**

# <u>លិខិតអញ្ជើញមេធាវី</u>

លេខ:.......................

**យើង**........... **តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល**

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ... អ.ក ចុះថ្ងៃទី ... ខែ... ឆ្នាំ.... របស់អយ្យការអម សាលាដំបូងខេត្តកណ្ដាល។
- បានឃើញ ដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ .... ដកសដជរ ចុះថ្ងៃទី....... ខែ......... ឆ្នាំ២០.. របស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកណ្ដាល។
- បានឃើញ ពាក្យសុំការពារក្ដីចុះថ្ងៃទី.... ខែ..... ឆ្នាំ.... របស់មេធាវី .... ។

អញ្ជើញមេធាវី .......... អត្តលេខ ..... ជាមេធាវីការពារក្ដីឱ្យឈ្មោះ ...... ស្ថិតនៅ ផ្ទះលេខ ..... ផ្លូវ..... សង្កាត់...... ខណ្ឌ...... រាជធានីភ្នំពេញ ។

ឲ្យចូលមកកាន់សាលាដំបូងខេត្តកណ្ដាល **<u>នៅថ្ងៃទី...... ខែ.... ឆ្នាំ២០.... វេលាម៉ោង ០៩ និង ០០ នាទីព្រឹក នៅសាលសវនាការលេខ ......។ នៃសាលាដំបូងខេត្តកណ្ដាល។</u>**

ដើម្បីៈ **ចូលរួមសវនាការជំនុំជម្រះជាសាធារណៈ។**

ពីដំណើររឿងៈ ........................................................ ។

**សមាសភាពជំនុំជម្រះ**

| | |
|---|---|
| ១.លោក ........................ | ជាចៅក្រមជំនុំជម្រះ |
| ២.លោក ........................ | ជាតំណាងអយ្យការ |
| ៣.លោក ........................ | ជាក្រឡាបញ្ជីសវនាការ |

សាមីខ្លួនត្រូវចូលខ្លួនតាមដីកាកោះឲ្យបានទាន់ពេលវេលា ដោយយកលិខិតផ្សេងៗដែលទាក់ទងនឹងសំណុំរឿង ខាងលើមកជាមួយផងប្រសិនបើមាន។

ថ្ងៃ..................ខែ........... ឆ្នាំ ........ព.ស.២៥៦៦

ធ្វើនៅកណ្ដាល, ថ្ងៃទី .... ខែ......... ឆ្នាំ២០២២

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី៨**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តកណ្តាល**

លេខ:........................

# ដីកាកោះហៅសាក្សីឲ្យចូលសវនាការ

**យើង** ........... **តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល**

- បានឃើញ មាត្រា **៤៧៧** នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ... អ.ក ចុះថ្ងៃទី ... ខែ... ឆ្នាំ.... របស់អយ្យការអម សាលាដំបូងខេត្តកណ្តាល។
- បានឃើញ ដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ .... ដកសដជរ ចុះថ្ងៃទី....... ខែ......... ឆ្នាំ២០.. របស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកណ្តាល សម្រេចដាក់ជនជាប់ចោទឈ្មោះ ........... ភេទ.... អាយុ ទៅ**ជំនុំជម្រះ** ពីបទ ....................................ប្រព្រឹត្តនៅភូមិ...............ឃុំ............... ស្រុក.............. ខេត្តកណ្តាល កាលពីថ្ងៃទី ....ខែ..... ឆ្នាំ... តាមបញ្ញត្តិ**មាត្រា** ........**នៃ**.......... ។

អញ្ជើញឈ្មោះ ................... ភេទ.... អាយុ.... ឆ្នាំ សញ្ជាតិ....... **ជា សាក្សី** ទីលំនៅបច្ចុប្បន្ន ភូមិ..........ឃុំ.......... ស្រុក............. ខេត្ត...........។

ឲ្យចូលមកកាន់សាលាដំបូងខេត្តកណ្តាល **<u>នៅថ្ងៃទី ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ០៩ និង ០០នាទីព្រឹក នៅសាលស</u>**ជាកំហិត ដើម្បីធ្វើការជំនុំជម្រះជាសាធារណៈ ។

ឲ្យចូលមកកាន់សាលាដំបូងខេត្តកណ្តាល **<u>នៅថ្ងៃទី ... ខែ ....ឆ្នាំ២០... វេលាម៉ោង.. និង ០០ នាទីព្រឹក នៅសាលសវនាការ ...</u>** ជាកំហិត ដើម្បីធ្វើការជំនុំជម្រះជាសាធារណៈ ។

**សមាសភាពជំនុំជម្រះ**

| | |
|---|---|
| ១.លោក ........................ | ជាចៅក្រមជំនុំជម្រះ |
| ២.លោក ........................ | ជាតំណាងអយ្យការ |
| ៣.លោក ........................ | ជាក្រឡាបញ្ជីសវនាការ |

សាមីខ្លួនត្រូវចូលខ្លួនតាមដីកាកោះឲ្យបានទាន់ពេលវេលា ដោយយកលិខិតផ្សេងៗដែលទាក់ទងនឹងសំណុំរឿង ខាងលើមកជាមួយផងប្រសិនបើមាន។

ថ្ងៃ.............ខែ........... ឆ្នាំ ........ព.ស.២៥៦៦

ធ្វើនៅកណ្តាល, ថ្ងៃទី .... ខែ......... ឆ្នាំ២០២២

**តំណាងអយ្យការ**